កាកបាទក្រហមកម្ពុជា
CAMBODIAN RED CROSS

# ការពង្រឹងសមត្ថភាពត្រៀមបង្ការនិងឆ្លើយតបផ្នែកអនាម័យ

## ទឹកស្អាត ក្នុងគ្រាអាសន្ន



# សៀវភៅមគ្គុទ្ទេសក៍

សហព័ន្ធអន្តរជាតិកាកបាទក្រហម និងអឌ្ឍចន្ទក្រហម (IFRC)

សម្រាប់

## ការលើកកម្ពស់អនាម័យ ក្នុងគ្រាអាសន្ន

ឧបត្ថម្ភថវិកាដោយ៖

IFRC

日本赤十字社
Japanese Red Cross Society

# មាតិកា


គោលការណ៍ណែនាំរបស់ IFRC ស្តីអំពី ការលើកកម្ពស់អនាម័យក្នុងគ្រាអាសន្ន ...................................... 3

**សេចក្តីផ្តើម** ....................................................................................................3

**ឯកសារនេះសម្រាប់អ្នកណា**? ...........................................................................3

តើត្រូវធ្វើការផ្សព្វផ្សាយ និងលើកកម្ពស់អនាម័យនៅពេលមានគ្រោះមហន្តរាយយ៉ាងដូចម្តេច?...................... 10

***ជំហានទី១៖ ការកំណត់បញ្ហា***.......................................................................... 12

***ជំហានទី២ :ការកំណត់ក្រុមគោលដៅ***................................................................. 16

***ជំហានទី ៣: ការទតាតរកឧបសគ្គ និង ការលើកទឹកចិត្ត ឱ្យមានការផ្លាស់ប្តូរនយោបាយ***18

***ជំហានទី៤ : ការបង្កើតគោលបំណងនយោបាយអនាម័យ***......................................... 23

***ជំហានទី៥: ការធ្វើផែនការ*** ............................................................................. 24

**ជំហានទី ៦** : **ការអនុវត្តន៍** ...................................................................................... 35

**ជំហានទី៧ : ការត្រួតពិនិត្យ និងការវាយតំលៃ**.......................................................... 43

**ជំហានទី៨** : **ពិនិត្យ និងកែតម្រូវឡើងវិញ**.................................................. 47

**References**.............................................................................................. 48

ឧបសម្ព័ន្ធ**........................................................................................................... 50**

១.១ សេចក្តីសង្ខេបនៃគោលការណ៍ណែនាំរបស់ **IFRC** ក្នុងការផ្សព្វផ្សាយលើកកម្ពស់អនាម័យនៅពេលមានគ្រោះមហន្តរាយ ................................................................................ 50

**១.២. គោលការណ៍ណែនាំរបស់** IFRC **ក្នុងការលើកកម្ពស់អនាម័យ ការដោះស្រាយបញ្ហា - ភ្លាមៗ**60

# គោលការណ៍ណែនាំរបស់ IFRC ស្តីអំពី ការលើកកម្ពស់អនាម័យក្នុងគ្រាអាសន្ន

## សេចក្តីផ្តើម

គោលបំណងសំខាន់របស់គោលការណ៍ណែនាំនេះ ធ្វើឡើងដើម្បីធានាថា រាល់កម្មវិធីទឹកស្អាតនិងអនាម័យរបស់កាកបាទក្រហមអឌ្ឍចន្ទក្រហម ដែលរួមមានការផ្សព្វផ្សាយអនាម័យប្រកបដោយប្រសិទ្ធភាព គឺពាក់ព័ន្ធនឹងបរិបទជាក់ស្តែង។ កាកបាទក្រហម អឌ្ឍចន្ទក្រហម ក៏ដូចជា អង្គការជាច្រើនទៀតដែរ គឺមានបុគ្គលិកនិងអ្នកស្ម័គ្រចិត្តនៅតាមសហគមន៍ ដើម្បីធ្វើការជាមួយសហគមន៍ ក្នុងការផ្សព្វផ្សាយអនាម័យទៅដល់សហគមន៍។ ទោះយ៉ាងណាក៏ដោយ បទពិសោធន៍បានបង្ហាញថា ក្នុងអំឡុងពេលឆ្លើយតបពេលគ្រោះមហន្តរាយ គឺតែងតែផ្តោតទៅលើការ ផ្តល់សារលើកកម្ពស់អនាម័យ។ គោលការណ៍ណែនាំនេះ ជួយបុគ្គលិកនិងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាធ្វើការងារជាប្រព័ន្ធដោយឆ្លងកាត់គ្រប់ជំហានសំខាន់ៗសម្រាប់រៀបចំផែនការអនុវត្តនិងតាមដានការលើកកម្ពស់អនាម័យដោយចាប់ផ្តើមពីការយល់ដឹងអំពី **បញ្ហា ឧបសគ្គ និងកត្តាជម្រុញទឹកចិត្ត** សម្រាប់ការផ្លាស់ប្តូរអាកប្បកិរិយា - ដោយសហគមន៍ចូលរួមគ្រប់ដំណាក់កាល។ - ស្តាប់និងធ្វើការជាមួយសហគមន៍ដែលរងផលប៉ះពាល់ធានាថា ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពនិងសមស្របទៅនឹងតម្រូវការ។

ឯកសារនេះត្រូវបានសង្ខេបជាឯកសារខ្លីមានចំនួន ៦ ទំព័រ និងសង្ខេបជាឯកសារ ១ទំព័រផងដែរ (ដើម្បីអានបានរហ័ស)។ ឯកសារ សម្ភារ ប្រពភពធនធាននិងឯកសារយោងដែលបានលើកឡើងនៅក្នុងឯកសារនេះ គឺបានដកស្រង់ចេញពីគេហ៍កទំព័រ *http://watsanmissionassistant.org*

### ឯកសារនេះសម្រាប់អ្នកណា?

ឯកសារនេះគឺសម្រាប់បុគ្គលិកនិងអ្នកស្ម័គ្រចិត្តកាកបាទក្រហម អឌ្ឍចន្ទក្រហមទាំងអស់ ប្រើឆ្លើយតបទៅនឹងពេលមានគ្រោះមហន្តរាយ ទាំងអ្នកស្ម័គ្រចិត្តនៅតាមសហគមន៍ បុគ្គលិករដ្ឋាភិបាល ក្រុមឆ្លើយតបគ្រោះមហន្តរាយជាតិ ក្រុមឆ្លើយតបគ្រោះមហន្តរាយតាមតំបន់ (RDRTs) និងអង្គភាពឆ្លើយតបគ្រោះមហន្តរាយ ជាពិសេសអ្នកដែលធ្វើការក្នុងវិស័យអនាម័យ និងទឹកស្អាត។

គោលការណ៍ណែនាំនេះសម្រាប់ក្រុមមនុស្សគោលដៅដែលជាអ្នកផ្សព្វផ្សាយអំពីអនាម័យមានបទពិសោធន៍សមល្មម និងអ្នកមានសមត្ថភាពខ្ពស់ក្នុងការឆ្លើយតបទៅនឹងអនាម័យនិងទឹកស្អាតពេលមានគ្រោះមហន្តរាយ។ គោលបំណង របស់គោលការណ៍ណែនាំនិងសម្ភារៈបណ្តុះបណ្តាល គឺសម្រាប់ឱ្យអ្នកផ្សព្វផ្សាយអនាម័យទាំងអស់ប្រើបាននៅក្នុងស្ថានភាពផ្សេងៗគ្នា។ ផ្តល់ការណែនាំដល់អ្នកដែលមានបទពិសោធន៍មធ្យមនិងសម្រាប់អ្នកដែលមានបទពិសោធន៍ច្រើនដែលធ្វើការក្នុងស្ថានភាពផ្សេងគ្នា ដែលត្រូវស្របទៅតាមបរិស្ថានដែលមានបញ្ហាប្រឈម។

# ចំណាំ

ការផ្សព្វផ្សាយអំពីអនាម័យក្នុងពេលមានគ្រាអាសន្ន មានដូចខាងក្រោម:

**១. គោលការណ៍ណែនាំ IFRC ស្តីពីការផ្សព្វផ្សាយអនាម័យក្នុងពេលមានគ្រាអាសន្ន** ***(នៅក្នុងឯកសារនេះ)***

- ឯកសារនេះបានភ្ជាប់មកជាមួយនឹងបណ្តាញព័ត៌មានស្តីពីការណែនាំវិធីរៀបចំផែនការនិងការអនុវត្តផ្សព្វផ្សាយអំពីការលើកកម្ពស់អនាម័យនៅពេលមានគ្រាអាសន្ន។

**២.មានសេចក្តីសង្ខេបចំនួន ៦ ទំព័រពីគោលការណ៍ណែនាំរបស់ IFRC ក្នុងការលើកកម្ពស់អនាម័យក្នុងពេលមានគ្រាអាសន្ន**

- សេចក្តីសង្ខេបពិពណ៌នាអំពីជំហានសំខាន់ៗទាំងអស់ *(នៅក្នុងឧបសម្ព័ន្ធ ១.១)*

**៣.សេចក្តីសង្ខេបខ្លីចំនួន ១ ទំព័រអំពីគោលការណ៍ណែនាំរបស់ IFRC ក្នុងការលើកកម្ពស់អនាម័យក្នុងពេលមានគ្រាអាសន្ន។**

- ទិដ្ឋភាពទូទៅ *(នៅក្នុងឧបសម្ព័ន្ធ ១.២)*



## តើការផ្សព្វផ្សាយអនាម័យ គឺជាអ្វីហើយហេតុអ្វីវាសំខាន់ក្នុងពេលមានគ្រោះមហន្តរាយ?

***ភាគបាទក្រហមអឡ្សច័ន្ទក្រហម បានឱ្យនិយមន័យ ការផ្សព្វផ្សាយអនាម័យក្នុងពេលគ្រោះមហន្តរាយថា***

> ការលើកកម្ពស់អនាម័យក្នុងពេលគ្រោះមហន្តរាយៈ ជាវិធីសាស្ត្រដែលបានគ្រោងទុក និងមានលក្ខណៈជាប្រព័ន្ធធ្វើឡើងដោយបុគ្គលិកនិងអ្នកស្ម័គ្រចិត្តកាកបាទក្រហម។ ដើម្បីឱ្យប្រជាជនមានសកម្មភាពប្រយុទ្ធប្រឆាំងនឹងការពារជំងឺទាក់ទងនឹងទឹកស្អាត និងអនាម័យដោយការកៀងគរការចូលរួមពីប្រជាជនដែលរងផលប៉ះពាល់ឱ្យមានចំណេះដឹង និងទទួលបានធនធាន ហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈបរិក្ខារនានាសម្រាប់ទឹកស្អាតនិងអនាម័យ។

គោលបំណងចម្បងនៃអន្តរាគមន៍លើវិស័យទឹកស្អាត និងអនាម័យ គឺដើម្បីការពារនិងកាត់បន្ថយការឆ្លងជំងឺទាក់ទងនឹងទឹកស្អាតនិងអនាម័យ។ ការលើកកម្ពស់អនាម័យ គឺជាផ្នែកសំខាន់មួយក្នុងការអន្តរាគមន៍ដោយជោគជ័យនៅក្នុងវិស័យទឹកស្អាត និងអនាម័យ។

សុខភាពរបស់សហគមន៍ និងគ្រួសារសហគមន៍អាចជះឥទ្ធិពលដោយកត្តាជាច្រើនដូចជា ***បរិស្ថាន ស្ថានភាព សេដ្ឋកិច្ចសង្គម ប្រព័ន្ធសុខាភិបាល និងឥរិយាបថ*** ។ វាចាំបាច់ណាស់ក្នុងការធានាថា មនុស្សគ្រប់រូបមានមធ្យោបាយ ដើម្បីទទួលបានសុខភាពល្អជាជាងការផ្តោតលើអាកប្បកិរិយារបស់មនុស្សម្នាក់ៗ។ ដើម្បីធានាបាននូវហេដ្ឋារចនាសម្ព័នទឹកស្អាតនិងអនាម័យ គឺជាផ្នែកមួយក្នុងការផ្សព្វផ្សាយនិងលើកកម្ពស់អនាម័យ គឺមានឥទ្ធិពលក្នុងផ្លាស់ប្តូរអាកប្បកិរិយា និងទម្លាប់អនាម័យនៅតាមសហគមន៍។

ស្ថានភាពគ្រោះមហន្តរាយ អាចជះឥទ្ធិពលដល់សុខភាពតាមរបៀបផ្សេងៗគ្នា។ ហេដ្ឋារចានាសម្ព័ន្ធទឹកស្អាតនិងអនាម័យ អាចត្រូវបានប្រើប្រាស់មានកំណត់ ឧទាហរណ៍ ប្រសិនបើមនុស្សម្នាក់ បានផ្លាស់ទីលំនៅទៅរស់នៅក្នុងជម្រកបណ្តោះអាសន្នដោយគាត់បានចាកចេញពីផ្ទះសម្បែងរបស់ពួកគាត់ (ឧទាហរណ៍ ដោយសារជម្លោះ ឬគ្រោះមហន្តរាយធម្មជាតិ) ហេដ្ឋារចនាសម្ព័ន្ធត្រូវបានខូចខាត (ឧទាហរណ៍ បន្ទាប់ពីមានការរញ្ជួយដី ទឹកជំនន់) កង្វះខាតធនធាន (ឧទាហរណ៍ សាប៊ូ) ។ កន្លែងថែទាំសុខភាព កង្វះស្បៀងអាហារ កង្វះទីជម្រក ដូចនេះចំនួនអ្នករស់នៅលើសកម្រិត។ល។ ទាំងនេះអាចនាំឱ្យមានការកើនឡើងនូវហានិភ័យពីការឆ្លងជំងឺដែលទាក់ទងនឹងប្រព័ន្ធទឹក និងអនាម័យមិនស្អាត។

ការផ្សព្វផ្សាយ និងលើកកម្ពស់អនាម័យទាក់ទងនឹងការធានាថា ហេដ្ឋារចនាសម្ព័ន្ធត្រូវបានប្រើប្រាស់បានល្អបំផុតនៅតាមកន្លែងប្រើប្រាស់ទឹកស្អាតនិងអនាម័យដែលត្រូវបានផ្តល់ជូន។ តាមរយៈបទពិសោធន៍បានបង្ហាញថា ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធទៅនឹងទឹកស្អាតនិងអនាម័យមិនបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនិងមិនមាននិរន្តរភាពទេបើគ្មានការផ្សព្វផ្សាយនិងលើកកម្ពស់អនាម័យ។ ការទទួលបានផ្នែកហេរដ្ឋារចនាសម្ព័ន្ធ (ឧទាហរណ៍ បង្គន់អនាម័យ ឧបករណ៍ផលិតទឹកស្អាតសម្រាប់ផឹកនិងកន្លែងលាងដៃ) ដោយមានការលាយបញ្ចូលនូវបរិស្ថានសមស្រប ការផ្សព្វផ្សាយនិងការលើកកម្ពស់អនាម័យបានធ្វើឱ្យប្រសើរឡើងនូវអនាម័យដូចបានបង្ហាញក្នុងចំណុចធ្វើឱ្យប្រសើរស្ថានភាពអនាម័យក្នុងពេលមានគ្រោះមហន្តរាយ (ចំណុចទី១) គោលបំណងទូទៅនៃការកែ

លម្អអនាម័យ គឺដើម្បីបង្ការ ឬកាត់បន្ថយផលប៉ះពាល់ពីជំងឺទាក់ទងនឹងប្រព័ន្ធទឹកស្អាត និងអនាម័យមិនស្អាត។ ប្រភព៖ *Hygiene Promotion in Emergencies, WASH Cluster Briefing Paper.*

ការផ្តោតលើការផ្សព្វផ្សាយ និងការលើកកម្ពស់អនាម័យត្រូវបានកំណត់ដោយផ្អែកលើហានិភ័យសុខភាពសាធារណៈ។ ចំណុចចសំខាន់ៗរួមមាន៖

- ការបោះចោលកាកសំណល់លាមកដោយសុវត្ថិភាព
- ការលាងដៃឱ្យស្អាតប្រកបដោយប្រសិទ្ធភាព
- ការកាត់បន្ថយមេរោគ នៅក្នុងទឹកផឹកនៅតាមគ្រួសារសហគមន៍

បើផ្តោតតែទៅលើចំនុចទាំងបីខាងលើ នៅមិនទាន់ល្អបំផុតនោះទេតែត្រូវរាប់បញ្ចូលនូវការគ្រប់គ្រងសត្វចង្រៃ ការគ្រប់គ្រងកាកសំណល់ពេលបង្គន់អនាម័យពេញ និងការគ្រប់គ្រងអនាម័យពេលមានរដូវនៅពេលមានគ្រោះមហន្តរាយ ។

ចំណុចសំខាន់ធ្វើយ៉ាងណាឱ្យប្រជាជននៅក្នុងសហគមន៍ជៀសផុតពីការរងផលប៉ះពាល់ និងហានិភ័យសុខភាពសាធារណៈតាមរយៈការអនុវត្តអនាម័យប្រកបដោយសុវត្ថិភាព ប្រើប្រាស់ហេដ្ឋារចនា និងសេវាទឹកស្អាត និងអនាម័យឱ្យបានល្អបំផុត រួមទាំងបន្តការថែទាំ និងជួសជុលផងដែរ ។

**ការបង្ការជំងឺតាមរយៈទឹកស្អាត និងអនាម័យ**




*ចំណុចទី១ :ក្របខណ្ឌកែលម្អអនាម័យ (ប្រភព :Sphere Handbook 2011)*

វិធីសាស្ត្រ 'យុទ្ធនាការ' ត្រូវបានកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហមប្រើយ៉ាងទូលំទូលាយបំផុតសម្រាប់ការលើកកម្ពស់អនាម័យក្នុងពេលមានគ្រោះមហន្តរាយ។ យុទ្ធនាការត្រូវបានរៀបចំឡើងទៅតាមគោលការណ៍ការអប់រំអនាម័យ

តាមរយៈសកម្មភាពបង្រៀនផ្សេងៗ និងការពន្យល់ពីផ្លូវចម្លងមេរោគ និងវិធីទប់ស្កាត់មេរោគ ឧទាហរណ៍ ដោយការឈរនៅពីមុខក្រុមអ្នកទទួលផល និងពន្យល់ពីគំនូសបំព្រួញការផ្លូវចម្លងជំងឺ (ដ្យាក្រាមអេហ្វ) ដោយមានផ្ទាំងរូបភាពមកបង្ហាញដោយសារពិបាកពន្យល់ឱ្យក្រុមបានយល់ពីរបៀបចូលរួមក្នុងសកម្មភាពបែបចូលរួមផ្សេងៗទៀត។ *ឧទាហរណ៍* ក្រុមស្ត្រីអាចពិភាក្សាអំពីដ្យាក្រាមអេហ្វ និងយល់ពីផ្លូវទប់ស្កាត់ផ្លូវចម្លងមេរោគ និងដាក់រូបភាពទៅតាមគំនិតដែលពួកគាត់យល់ឃើញ។

## សមាសធាតុសំខាន់ៗនៃការផ្សព្វផ្សាយអនាម័យគឺ:

| | |
|---|---|
| **ការចូលរួមពីសហគមន៍** | **ពិគ្រោះយោបល់ជាមួយបុរស ស្ត្រី និងកុមារដែលរងផលប៉ះពាល់រួមទាំងជនពិការ លើការរចនាទីកន្លែង សម្ភារៈអនាម័យនិងប្រព័ន្ធផ្សព្វផ្សាយដែលកំណត់អត្តសញ្ញាណជនងាយរងគ្រោះនិងពិនិត្យទៅលើរចនាសម្ព័ន្ធសហគមន៍ដែលមានស្រាប់។** |
| **ការប្រើប្រាស់និងថែទាំហេដ្ឋារចនាសម្ព័ន្ធ** | មតិយោបល់ពី /វិស្វករ ឬសហគមន៍លើគំរូប្លង់ ភាពអាចទទួលយកបាន និងភាពងាយស្រួលដែលនាំឱយមានការលើកទឹកចិត្តដល់ភាពជាម្ចាស់របស់សហគមន៍ និងមានទំនួលខុសត្រូវចំពោះការសំអាត និងថែទាំជួសជុលហេដ្ឋារចនាសម្ព័ន្ធ។ |
| **ការជ្រើសរើស និងការចែកចាយសម្ភារៈអនាម័យ** | ធ្វើការជាមួយសហគមន៍លើប្រភេទសម្ភារៈអនាម័យដែលត្រូវការ។ |
| **សកម្មភាពសហគមន៍និង គ្រូសារសហគមន៍** | ការប្រើប្រាស់គោលការណ៍ការទំនាក់ទំនងនឹងផ្លាស់ប្តូរអាកប្បកិរិយាការ បណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តតាមសហគមន៍ឱ្យក្លាយជាអ្នកផ្សព្វផ្សាយអនាម័យដោយមានសកម្មភាពការសម្តែងរបស់សហគមន៍និងតាមរយៈការចុះសួរសុខទុក្ខតាមផ្ទះ។ |
| **ការទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធនឹងទឹកស្អាតនិងអនាម័យ (WASH)** | សហការជាមួយរដ្ឋាភិបាលអង្គការផ្សេងៗ (ទាំងអន្តរជាតិនិងជាតិ) ដែលធ្វើការនៅតំបន់គោលដៅឱយចូលរួមក្នុងយន្តការសម្របសម្រួលក្នុងក្រុមទឹកស្អាតនិងអនាម័យ។ |
| **ការត្រួតពិនិត្យ** | ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងការពេញចិត្តរបស់សហគមន៍ជាមួយនឹងកម្មវិធីទឹកស្អាតនិងអនាម័យដែលមាន។ |

*សម្រាប់ព័ត៌មានបន្ថែមទៅលើចំណុចខាងលើសូមពិនិត្យមើលលើឯកសារ* WASH Cluster Hygiene Promotion Briefing Paper *រាល់កម្មវិធីរបស់កាកបាទក្រហម និងអឌ្ឍចន្ទក្រហម ត្រូវតែមានរាល់ចំនុចទាំងអស់នោះ។*

## គោលការណ៍ និងបទដ្ឋាន

បុគ្គលិក និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមអឌ្ឍចន្ទក្រហមទាំងអស់ដែលចូលរួមក្នុងសកម្មភាពលើកកម្ពស់អនាម័យចាំបាច់ត្រូវស្គាល់ និងប្រកាន់ខ្ជាប់នូវគោលការណ៍ និងបទដ្ឋានមនុស្សធម៌រួមមាន:

- គោលការណ៍គ្រឹះកាកបាទក្រហម អឌ្ឍចន្ទក្រហម
- បទដ្ឋាននៅក្នុងសៀវភៅណែនាំស្វែរ Sphere
- ការចូលរួមរបស់សហគមន៍ និងគណនេយ្យភាព។

សៀវភៅស្វែរ Sphere

គោលបំណងសំខាន់នៃសៀវភៅណែនាំស្វែរ Sphere គឺដើម្បីលើកកម្ពស់គុណភាពនៃការឆ្លើយតបផ្នែកមនុស្សធម៌នៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជម្លោះ ដើម្បីបង្កើនគណនេយ្យភាពនៃប្រព័ន្ធមនុស្សធម៌ដល់ប្រជាជនក្នុងសហគមន៍ដែលងាយរងគ្រោះដោយគ្រោះមហន្តរាយ។

មានស្តង់ដារចំនួនបីសម្រាប់ការផ្សព្វផ្សាយ និងលើកកម្ពស់អនាម័យនៅក្នុងសៀវភៅណែនាំស្វែរ (ឆ្នាំ ២០១៨) ដែលបានលើកនៅក្នុងសកម្មភាព និងសូចនាករសំខាន់ៗដូចខាងក្រោម:

### *បទដ្ឋានផ្សព្វផ្សាយ និងលើកកម្ពស់អនាម័យ 1.1: ការផ្សព្វផ្សាយ និងលើកកម្ពស់អនាម័យ*

ប្រជាជនយល់ដឹងអំពី ហានិភ័យសុខភាពសាធារណៈសំខាន់ៗ ដែលទាក់ទងនឹងទឹកស្អាត និងអនាម័យ ហើយអាចការពារសមាជិកគ្រួសារ និងចាត់វិធានការដើម្បីឱ្យសហគមន៍ទាំងមូលបន្ថយនូវហានិភ័យទាំងនោះ។

### *បទដ្ឋានផ្សព្វផ្សាយ និងលើកកម្ពស់អនាម័យ 1.2: ការកំណត់អត្តសញ្ញាណ លទ្ធភាពប្រើប្រាស់ និងប្រើប្រាស់សម្ភារអនាម័យ*

សម្ភារៈទាំងឡាយណា ដែលអាចគាំទ្រអនាម័យសុខភាព សេចក្តីថ្លៃថ្នូរ និងសុខុមាលភាព ហើយអាចរកបានដោយប្រជាជនដែលរងផលប៉ះពាល់។

### *បទដ្ឋានផ្សព្វផ្សាយ និងលើកកម្ពស់អនាម័យ 1.3: ការគ្រប់គ្រងអនាម័យ និងការមិនមានរដូវ*

ស្ត្រី និងក្មេងស្រីដែលមានអាយុមករដូវ ព្រមទាំងបុរស និងស្ត្រី មិនសូវនិយាយពីបញ្ហាអនាម័យពេលមានរដូវនោះទេដូចនេះ លទ្ធភាពទទួលបានផលិតផលអនាម័យ និងសម្ភារៈអនាម័យដែលគាំទ្រដល់សេចក្តីថ្លៃថ្នូរ និងសុខុមាលភាពរបស់ពួកគេក៏ទទួលបានមិនគ្រប់គ្រាន់ដែរ។

នៅក្នុងសៀវភៅស្វែរ ចែងថាការលើកកម្ពស់អនាម័យផ្តល់ឱ្យសហគមន៍ដែលរងផលប៉ះពាល់នូវឱកាស ដើម្បីចូលរួម ហើយធានាថា បរិក្ខានានាសមស្របទៅនឹងហានិភ័យ តម្រូវការ និងប្រើប្រាស់យ៉ាងសមរម្យសម្រាប់ពួកគាត់ ។

បទពិសោធន៍បានបង្ហាញថា ក្នុងអំឡុងពេលឆ្លើយតបបន្ទាន់ កាកបាទក្រហម និងអឌ្ឍចន្ទក្រហមជាទូទៅបានប្រើ "វិធីសាស្ត្រយុទ្ធនាការ" ដោយផ្តោតលើការផ្តល់សារជាមួយសម្ភារៈអប់រំ និងការទំនាក់ទំនងព័ត៌មាន (IEC) ក្នុងគោលបំណងផ្លាស់ប្តូរឥរិយាបទ។ វិធីសាស្ត្រនេះមិនមានប្រសិទ្ធិភាពទេប្រសិនបើយើងមិនធ្វើការរួមគ្នាជាមួយប្រជាជនដែលរងផលប៉ះពាល់ក្នុងការស្វែងយល់អំពីបញ្ហា ការលើកទឹកចិត្ត និងឧបសគ្គនានាដើម្បីឱ្យសហគមន៍ (សមាជិកគ្រួសារ និងសហគមន៍ទាំងមូល) អាចដោះស្រាយបញ្ហាសុខភាពសាធារណៈរួមគ្នា។ មានតែការបង្កើន

ចំណេះដឹងដល់សហគមន៍ដែលរងផលប៉ះពាល់តែមួយមុខមិនអាចនាំឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា និងទម្លាប់ទាំងស្រុងនោះទេ។

| បញ្ហានានាដែលតែងតែជួបប្រទះនៅពេលផ្សព្វផ្សាយ និងការលើកកម្ពស់អនាម័យ<br>របាយការណ៍ស្តីពីអនាម័យ ការត្រួតពិនិត្យ និងគោលការណ៍ណែនាំបានរកឃើញភាពខុសគ្នាជាច្រើន នៅក្នុងការអនុវត្តពេលផ្សព្វផ្សាយ និងការលើកកម្ពស់អនាម័យ | |
|---|---|
| **ផ្តោតខ្លាំងពេក:**<br>▪ ផ្សព្វផ្សាយសារតែមួយដោយមិនបានស្តាប់គ្រួសារសហគមន៍ផ្សេងៗទៀត។<br>▪ ធ្វើសម្ភារៈផ្សព្វផ្សាយដូចជាផ្ទាំងរូបភាព និងខិត្តប័ណ្ណមុនពេលស្វែងយល់ពីបញ្ហាឱ្យបានត្រឹមត្រូវ។<br>▪ មិនធ្វើអនាម័យផ្ទាល់ខ្លួននិងមិនមានការថែទាំជួសជុលហេដ្ឋារចនាសម្ព័ន្ធអនាម័យឱ្យបានល្អ។ | **មិនបានផ្តោតគ្រប់គ្រាន់:**<br>▪ សកម្មភាពជាក់ស្តែងដែលគ្រួសារសហគមន៍អាចអនុវត្តបាននិងមានវិធីទំនាក់ទំនងបានល្អ<br>▪ វិធីកំណត់រកទម្លាប់និងអ្នកត្រូវមកទទួលការផ្សព្វផ្សាយអំពីការលើកកម្ពស់អនាម័យក្នុងពេលជាមួយគ្នា។<br>▪ លើកទឹកចិត្តដើម្បីឱ្យសហគមន៍យល់ឱ្យគាត់មានភាពខ្មើមអើមនិងចង់បានសុខភាពជាចំណុចសំខាន់ដែលចង់បាន។<br>▪ ស្តាប់ និងផ្តល់ការពិភាក្សាដល់សហគមន៍ ដើម្បីស្វែងរកបញ្ហានានា និងវិធី ដើម្បីសម្របខ្លួនក្នុងការផ្លាស់ប្តូរដែលស្របទៅនឹងស្ថានភាពរបស់ពួកគេ។<br>▪ កំណត់រកសេចក្តីត្រូវការរបស់ក្រុមដែលត្រូវបានគេមើលរំលងនៅក្នុងសហគមន៍ដែលរងផលប៉ះពាល់។ |

ការគៀងគរសហគមន៍នៅពេលមានគ្រោះមហន្តរាយព្រោះផ្តោតលើការលើកទឹកចិត្តប្រជាជនឱ្យចាត់វិធានការដើម្បីការពារសុខភាពរបស់ពួកគេ។ សកម្មភាពផ្សព្វផ្សាយគួរតែបញ្ចូលរបៀបផ្សព្វផ្សាយសារ (សៀវភៅស្វែរឆ្នាំ ២០១១) ផង។ វិធីសាស្ត្រមានការឆ្លើយតបទៅនឹងសមាជិកសហគមន៍ទាំងអស់ (បុរស ស្ត្រី កុមារជនពិការ ក្រុមដែលបាត់ឱកាស)ដោយមានឱកាសដើម្បីចែករំលែកព័ត៌មានពិភាក្សា និងមានឱកាសសួរសំណួរ វាជាចំណេះដឹងស៊ីជម្រៅមានឥទ្ធិពលទៅលើអ្វីដែលសហគមន៍គិតពិចារណ ហើយនឹងធ្វើ។

## គណនេយ្យភាព

គណនេយ្យភាព ជាជំនួយការដែលមានសារៈសំខាន់ណាស់។ រាល់សកម្មភាពរបស់កាកបាទក្រហម និងអឌ្ឍចន្ទក្រហមទាក់ទងនឹងទឹកស្អាត និងអនាម័យត្រូវតែបញ្ជាក់៖ ពីការផ្តល់ព័ត៌មាន ការស្តាប់យ៉ាងសកម្មដល់អ្នកដែលរងផលប៉ះពាល់ បង្ហាញអាកប្បកិរិយាគោរព និងការយល់ចិត្តចំពោះអ្នកដែលយើងជួយ។

**គម្រោងគណនេយ្យភាពទឹកស្អាត និងអនាម័យ** បានបង្កើតឧបករណ៍ងាយៗមួយចំនួនដើម្បីជួយបុគ្គលិកនៅតាមមូលដ្ឋានឱ្យយល់ពីទិដ្ឋភាពជាក់ស្តែងនៃគណនេយ្យភាព។ គណនេយ្យភាពត្រូវមាន ៥ចំណុចសំខាន់ៗ៖

*ការចូលរួមពីសហគមន៍ យន្តការផ្តល់មតិត្រលប់ និងការវាយតម្លៃ សមត្ថភាព អាកប្បកិរិយាបុគ្គលិក និង ព្រមទាំងការត្រួតពិនិត្យនិងវាយតម្លៃ។*

មានការលើកទឹកចិត្តយ៉ាងខ្លាំងដល់អ្នកផ្សព្វផ្សាយអនាម័យឱ្យអានសៀវភៅគណនេយ្យភាព សៀវភៅនេះបានបង្ហាញពីសកម្មភាពសំខាន់ៗ តាំងពីដំណាក់កាលដំបូង ដំណាក់កាលទី១ និងដំណាក់កាលទី២ ជាបន្តបន្ទាប់របស់គ្រោះមហន្តរាយ។ សៀវភៅនេះរៀបរាប់លម្អិតអំពីគណនេយ្យភាព។ ទិដ្ឋភាពសំខាន់ៗនៃគណនេយ្យភាពចំពោះអ្នកទទួលផលរួមមានការពន្យល់និងការទទួលខុសត្រូវចំពោះអ្វីដែលអ្នកធ្វើ និងមិនបានធ្វើក្នុងការផ្តល់ព័ត៌មានទាន់ពេលវេលា ធានាបាននូវយន្តការផ្តល់យោបល់ត្រឡប់ និងការចង់ដឹង ដើម្បីជួយឱ្យសមាជិកសហគមន៍ដែលរងផលប៉ះពាល់ធ្វើការសម្រេចចិត្តលើអន្តរាគមន៍ទៅលើវិស័យទឹកស្អាត និងអនាម័យ។

<u>បទដ្ឋានមនុស្សធម៌</u> (CHS) ស្តីពីគុណភាព និងគណនេយ្យភាពកាកបាទក្រហម និងអឌ្ឍចន្ទក្រហម បានកំណត់ពីការសម្រេចឱ្យបាន៩ចំណុច ដើម្បីលើកកម្ពស់គុណភាពនិងគណនេយ្យភាពចំពោះសហគមន៍និងប្រជាជនដែលរងផលប៉ះពាល់ដោយវិបត្តិសេដ្ឋកិច្ច ដូចជា បទដ្ឋានមនុស្សធម៌បានដាក់សហគមន៍ និងប្រជាជនដែលរងផលប៉ះពាល់ដោយវិបត្តិនៅកណ្តាលសកម្មភាពមនុស្សធម៌ និងលើកកម្ពស់ការគោរពសិទ្ធិមនុស្សជាមូលដ្ឋានរបស់ពួកគេដែលចំណុចនេះបានផ្សាភ្ជាប់ទៅនឹងគោលការណ៍គ្រឹះរបស់កាកបាទក្រហម និងអឌ្ឍចន្ទក្រហមដែលផ្តោតទៅលើមនុសជាតិ ភាពមិនលំអៀង ឯករាជ្យភាព និងអព្យាក្រឹតភាព។

| Q : តើមានភស្តុតាងណាមួយដែលបង្ហាញថា ការលើកកម្ពស់អនាម័យក្នុងពេលមានគ្រោះមហន្តរាយជាកិច្ចការមានប្រសិទ្ធភាព? |
| --- |
| ខណៈពេលដែលយើងអាចខ្វះការសិក្សាស្រាវជ្រាវ ដើម្បីបង្ហាញថា ការលើកកម្ពស់អនាម័យក្នុងពេលមានគ្រោះមហន្តរាយ(ជាពិសេសក្នុងករណីបន្ទាន់) មិនត្រឹមតែជួយឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយានោះទេ (ឧទាហរណ៍ ការឱ្យសហគមន៍ប្តូរទៅលាងដៃ) គឺត្រូវការចូលរួមពីសមាជិកសហគមន៍ ហើយពួកគាត់ត្រូវតែអនុវត្តឱ្យបានសកម្ម។ គេរកឃើញថា នៅពេលដែលមនុស្សកាន់តែច្រើនចូលរួមកម្មវិធី គម្រោងកាន់តែមានប្រសិទ្ធភាព។ |

## **តើត្រូវធ្វើការផ្សព្វផ្សាយ និងលើកកម្ពស់អនាម័យនៅពេលមានគ្រោះមហន្តរាយយ៉ាងដូចម្តេច ?**

ដើម្បីអនុវត្តកម្មវិធីលើកកម្ពស់អនាម័យប្រកបដោយប្រសិទ្ធភាព ត្រូវផ្តោតសំខាន់លើការបោះចោលកាកសំណល់លាមកឱ្យមានសុវត្ថិភាព ការលាងដៃសាប៊ូឱ្យស្អាត និងកាត់បន្ថយការចម្លងមេរោគក្នុងទឹកផឹកនៅតាមគ្រួសារសហគមន៍ សំខាន់ចំណុចទាំងនេះ ត្រូវកើតឡើងជាប្រព័ន្ធ និងបានរៀបចំផែនការយ៉ាងល្អ ដើម្បីឱ្យសហគន៍ធ្វើសកម្មភាពទប់ស្កាត់ការឆ្លងជំងឺពីការកង្វះអនាម័យ ដោយកំណត់ពីតម្រូវការ (ផ្សាភ្ជាប់ជាមួយនឹងផលប៉ះពាល់នៃគ្រោះមហន្តរាយ) និងពិចារណាលើឧបសគ្គ និងការលើកទឹកចិត្តដល់ការផ្លាស់ប្តូរអាកប្បកិរិយា។ ចំណុចសំខាន់ទាំងនេះ អាចជាការពិបាកក្នុងការអនុវត្តផងដែរនៅពេលមានគ្រោះមហន្តរាយ ឬស្ថិតនៅក្នុងស្ថានភាពប្របូកប្របល់។

ការអនុវត្តកម្មវិធីលើកកម្ពស់អនាម័យដែលធ្វើទៅតាមវដ្តនៃគម្រោង គឺចាប់ផ្តើមពីការវាយតម្លៃ ហើយបញ្ចប់ដោយការពិនិត្យឡើងវិញជាដំណើរការដដែលៗ មតិយោបល់ត្រឡប់ ហើយការរៀនពីអ្វីដែលកើតឡើងត្រូវបញ្ចូលផងដែរ ដើម្បីធានាថា កម្មវិធីនេះតែងតែសមស្របទៅនឹងតម្រូវការរបស់សហគមន៍ដែលរងផលប៉ះពាល់។ ដំណើរការចាប់ផ្តើមដំបូងត្រូវធ្វើដូចខាងក្រោម:




*ចំនុចទី២ : វដ្តនៃដំណើរការគម្រោងលើកកម្ពស់អនាម័យ (ប្រភព: WASH Cluster, Hygiene Promotion – A Briefing Paper)*

## ៨ ជំហានក្នុងការផ្សព្វផ្សាយលើកកម្ពស់អនាម័យ ក្នុងពេលមានគ្រោះមហន្តរាយ

ដំណើរការមួយជំហានៗត្រូវបានជ្រើសរើសមកធ្វើការសម្របសម្រួលពេលអនុវត្តសកម្មភាពលើកកម្ពស់អនាម័យពេលធ្វើប្រតិបត្តិការឆ្លើយតបនឹងគ្រោះមហន្តរាយ។ ក្រុមអ្នកផ្សព្វផ្សាយអនាម័យ ទាំងអ្នកស្ម័គ្រចិត្តមូលដ្ឋានឬបុគ្គលិកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ធ្វើតាមដំណើរការ ៨ជំហាននេះ។ អ្នកស្ម័គ្រចិត្ត និងបុគ្គលិកអនុវត្តតាមជំហាននិមួយៗដោយងាយស្រួល និងទៅតាមរបៀបដែលមាននៅក្នុងសកម្មភាពលើកកម្ពស់អនាម័យមូលដ្ឋាន ហើយអ្នកគ្រប់គ្រងនិង/ឬប្រធានក្រុមអ្នកស្ម័គ្រចិត្ត និងអ្នកស្ម័គ្រចិត្តអាចគាំទ្រ ហើយណែនាំក្រុមរបស់ពួកគេឱ្យស្គាល់ពីជំហានដែលត្រូវអនុវត្ត។

សរុបសេចក្តីមក មានជំហាន៨ សម្រាប់ការលើកកម្ពស់អនាម័យក្នុងពេលមានគ្រោះមហន្តរាយសម្រាប់កាកបាទក្រហម និងអឌ្ឍចន្ទក្រហម។ ជំហានទាំងនេះ មានជំហានបន្ថែមមួយចំនួនទៀតទាក់ទងនឹងវដ្តគម្រោងក្នុងរូបភាពទី២ គឺធ្វើឱ្យដំណើរការកាន់តែពាក់ព័ន្ធនឹងប្រព័ន្ធឆ្លើយតបគ្រោះមហន្តរាយរបស់កាកបាទក្រហមនិងអឌ្ឍចន្ទក្រហម ដើម្បីធានាថា អ្នកទទួលផលបានចូលរួមដោយពេញលេញ។

1. **កំណត់បញ្ហា**
2. **កំណត់ក្រុមគោលដៅ**
3. **ការវិភាគឧបសគ្គ និងការលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា**
4. **ការបង្កើតគោលបំណងផ្លាស់ប្តូរឥរិយាបថអនាម័យ**
5. **ការធ្វើផែនការ**
6. **ការអនុវត្ត**
7. **ការត្រួតពិនិត្យ និងវាយតម្លៃ**
8. **ពិនិត្យ និងធ្វើការកែសម្រួសឡើងវិញ**

ជំហានទាំងនេះ ត្រូវបានពិពណ៌នាលម្អិតបន្ថែមទៀតនៅខាងក្រោម ដោយភ្ជាប់មកជាមួយនឹងវិធីសាស្ត្រ និងឧបករណ៍។ ដើម្បីធ្វើឱ្យជំហានទាំង៨នេះ ត្រូវបានអ្នកផ្សព្វផ្សាយអនាម័យរបស់កាកបាទក្រហម និងអឌ្ឍចន្ទក្រហមយកទៅអនុវត្តនឹងធ្វើសកម្មភាពលើកកម្ពស់អនាម័យតាមលំដាប់ និងជាលក្ខណៈប្រព័ន្ធ។ នៅចុងបញ្ចប់នៃជំហានទី៥ (រៀបចំផែនការ) ក្រុមផ្សព្វផ្សាយអនាម័យនឹងមានផែនការផ្លាស់ប្តូរឥរិយាបទជាប្រព័ន្ធក្នុងការអនុវត្តសកម្មភាពរបស់ខ្លួន។ យុទ្ធនាការនឹងមានគោលបំណងច្បាស់លាស់ ដើម្បីផ្លាស់ប្តូរអាកប្បកិរិយា ហើយឧបករណ៍ផ្សព្វផ្សាយនឹងត្រូវបានជ្រើសរើសយោងទៅតាមក្រុមគោលដៅ។

ផ្អែកលើបរិបទ ប្រពន្ធ័លើកកម្ពស់អនាម័យពេលមានគ្រោះមហន្តរាយ ពេលអនុវត្តជំហានទី១ ដល់ទី៥ អាចចំណាយពេលអស់ពី៧ ទៅ ១០ថ្ងៃដោយប្រើប្រាស់ព័ត៌មាន ទិន្នយ ដែលមានមុនពេលមានគ្រោះមហន្តរាយតាមរយៈការវាយតម្លៃយ៉ាងឆាប់រហ័ស និងព័ត៌មានជាក់លាក់ពីការពិគ្រោះយោបល់ជាមួយស្ថាប័នសង្គមថ្នាក់ជាតិ សហគមន៍ និងអ្នកដែលពាក់ព័ន្ធសំខាន់។ ចាប់ពីសប្តាហ៍ទី២ នៃការឆ្លើយតបគ្រោះមហន្តរាយ ការអនុវត្តជុំទី១ (ជំហានទី៦) និងការត្រួតពិនិត្យនិងវាយតម្លៃ (ជំហានទី៧) ចាំបាច់ត្រូវប្រតិបត្តិ ដើម្បីទប់ទល់នឹងហានិភ័យ និងតម្រូវការសំខាន់ៗ។ ជំហានទី៨ ពិតជាមានសារៈសំខាន់ណាស់នៅក្នុងខែ១ នៅពេលដែលស្ថានភាពអាចនឹងមានស្ថេរភាពដូច្នេះការកែសម្រួលឡើងវិញកាន់តែមានសារៈសំខាន់។ នៅដំណាក់កាលនេះវាមានសារៈសំខាន់សម្រាប់អ្នកផ្សព្វផ្សាយអនាម័យឱ្យយល់ពីតម្រូវការដើម្បីត្រឡប់ទៅជំហានទី១ ជាមួយនឹងការវាយតម្លៃដ៏ទូលំទូលាយបន្ថែមទៀត (ជំហានទី១ ដល់ទី ៣) ឬការស្ទង់មតិគោរពទៅតាមដំណើរការ នៃការធ្វើផែនការត្រឹមត្រូវ (ជំហាន៤ ដល់ ៥)។ រយៈវេលាពីជំហាននិមួយៗគ្រាន់តែដាក់បណ្តោះអាសន្ននិងជាគោលការណ៍ណែនាំតែប៉ុណ្ណោះ។



## ជំហានទី១៖ ការកំណត់បញ្ហា

គោលបំណងនៃការវាយតម្លៃកំណត់រកបញ្ហា គឺដើម្បីស្វែងយល់ពីស្ថានភាពជាក់ស្តែង ដើម្បីកំណត់បញ្ហា ប្រភពនៃបញ្ហា ផលលំបាកដែលកើតចេញពីបញ្ហា តម្រូវការ និងសមត្ថភាពរបស់ប្រជាជនដែលរងផលប៉ះពាល់ពីគ្រោះមហន្តរាយ។ នៅពេលដែលទទួលបានព័ត៌មានល្អ មិនអាច

ធានាថាយកទៅអនុវត្តកម្មវិធីបានល្អនោះទេ បើព័ត៌មានដែលទទួលបានមិនល្អមិនរឹតធ្វើឱ្យការអនុវត្តកម្មវិធីកាន់តែមិនទទួលបានលទ្ធផលល្អថែមទៀត។

ពេលមានគ្រោះមហន្តរាយ ការវាយតម្លៃកំណត់រកបញ្ហា ត្រូវបានរៀបចំទុកមុន : ពិចារណាលើព័ត៌មានសំខាន់ៗដែលចាំបាច់ ប្រភពព័ត៌មាននេះ និងវិធីសាស្ត្រប្រមូលទិន្នន័យពីព័ត៌មាន។ ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយជាញឹកញាប់មានភាពច្របូកច្របល់ ការសម្របសម្រួលអាចពិបាកប្រសិនមានអង្គការច្រើន របៀបទំនាក់ទំនងអាចមានបញ្ហាប្រឈមប្រសិនបើបណ្តាញទូរស័ព្ទ / ការផ្គត់ផ្គង់អគ្គសនីមិនដំណើរការ។ ពេលឆ្លើយតបនឹងគ្រោះមហន្តរាយអាចខ្វះបុគ្គលិកសង្គម និងអ្នកស្ម័គ្រចិត្ត ព្រោះពួកគេអាចនឹងរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយខ្លួនឯងដែរ។

ការវាយតម្លៃកំណត់រកបញ្ហាភ្លាមៗ និងដំបូងគឺមានភាពចាំបាច់ណាស់ក្នុងរយៈពេលពីរបីថ្ងៃដំបូង ដើម្បីបញ្ជាក់ពីវិធីសាស្ត្រចុះធ្វើអន្តរាគមន៍អទិភាពដែលត្រូវការហើយបន្ទាប់មកអាចស្វែងរកព័ត៌មានបន្ថែមទៀត នឹងធ្វើការវាយតម្លៃស៊ីជម្រៅតែម្តង។

នៅពេលដែលការវាយតម្លៃត្រូវបានធ្វើរួចរាល់ ការស្ទង់មតិជាមូលដ្ឋានត្រូវបានធ្វើឡើង ដើម្បីកត់ត្រាអំពីស្ថានភាពបច្ចុប្បន្ន (សូមមើលជំហានទី៥) ។

### តើគួរប្រមូលព័ត៌មានអ្វីខ្លះ?

ការវាយតម្លៃកំណត់រកបញ្ហាភ្លាមៗ គួរតែមានព័ត៌មានអំពីអ្វីខ្លះ៖

- ស្ថានភាពសុខភាពសាធារណៈ
- រចនាសម្ព័ន្ធសហគមន៍
- ការទឹកផឹកស្អាត និងមានសុវត្ថិភាព
- ការបោះចោលកាកសំណល់លាមកដោយសុវត្ថិភាព
- ការលាងដៃ
- ការអនុវត្តអនាម័យផ្ទាល់ខ្លួនល្អ
- ការគ្រប់គ្រងសត្វចង្រៃ
- ការគ្រប់គ្រងសំណល់សំរាម ទឹកស្អុយ
- អនាម័យក្នុងពេលមានរដូវ។
- ក្រុមអាទិភាព និងក្រុមងាយរងគ្រោះ

ព័ត៌មានលម្អិតអំពីសំណួរលើផ្នែកសំខាន់ៗទាំងនេះអាចរកបាននៅក្នុងទម្រង់វាយតម្លៃគំរូ Assessment Form

### តើត្រូវកំណត់បញ្ហាតាមរបៀបណា?

ការវាយតម្លៃកំណត់រកបញ្ហា គួរត្រូវបានធ្វើឡើងរួមគ្នាជាមួយអ្នកផ្សព្វផ្សាយអនាម័យ វិស្វករទឹកស្អាត អនាម័យ និងមន្ត្រីរដ្ឋាភិបាលដោយសហកា រនិងសម្របសម្រួលថ្នាក់ជាតិ RDRT, ERUs និងអ្នកពាក់ព័ន្ធដទៃទៀត ឧទាហរណ៍ ដៃគូរនិងអ្នកធ្វើការងារផ្នែកទឹកស្អាត អនាម័យនិងអ្នកធ្វើការក្នុងផ្នែកផ្សេងៗទៀត (សុខភាព ទីជម្រក ។ល។)។ ក្រុមអ្នកវាយតម្លៃកំណត់រកបញ្ហា គួរតែឱ្យតំណាងមកពីសហគមន៍ដែលរងគ្រោះចូលរួមដោយមានតុល្យភាពចំនួន បុរស និងស្ត្រី និងបុគ្គលិកផ្នែកផ្សេងៗ អ្នកស្ម័គ្រចិត្តមកពីតំបន់ផ្សេងៗដែលយល់ដឹង និងគោរព

វប្បធម៌របស់សហគមន៍ដែលរងផលប៉ះពាល់ និងមានជំនាញសង្កេត និងស្តាប់បានល្អចូលរួមទាំងអស់គ្នា។ ការលើកកម្ពស់អនាម័យរួមបញ្ចូលទាំងចំណេះដឹងផ្នែកខាងក្នុង /ចំណេះដឹងផ្នែកខាងក្រៅ (អ្វីដែលមនុស្សដឹង ធ្វើ និងចង់បាន) របស់ប្រជាជនដែលរងផលប៉ះពាល់ (ឧ. មូលហេតុនៃជំងឺរាគ) វាចាំបាច់ណាស់ដែលឱ្យប្រជាជនដែលរងផលប៉ះពាល់បានចូលរួមជាមួយក្នុងគម្រោងសកម្មភាពកំណត់រកបញ្ហានេះ។

ការវាយតម្លៃពីបញ្ហា គួរតែប្រើវិធីសាស្រ្តតាមបែបចូលរួម ដើម្បីឱ្យគ្រប់ផ្នែកទាំងអស់របស់សហគមន៍បានចូលរួមទាំងអស់គ្នា មានដូចជា បុរស ស្រ្តី និងកុមារនិងក្រុមមនុស្សផ្សេងៗទៀតដែលមានក្នុងភូមិ(ហើយវាជាការសំខាន់ណាស់ដែលមិនត្រូវទុកចោល ក្រុមដែលគេមើលរំលង និងក្រុមងាយរងគ្រោះ រួមទាំងជនពិការផងដែរ) ដើម្បីប្រមូលផ្តុំព័ត៌មាន និងលើកទឹកចិត្តសហគមន៍ឱ្យមានការចូលរួមជាមួយគ្នាក្នុងការកំណត់បញ្ហា និងជួយឱ្យពួកគេរកដំណោះស្រាយសម្រាប់បញ្ហាទាំងនោះផងដែរ។ ការជ្រើសរើសវិធីសាស្រ្ត អាស្រ័យលើបរិបទ លទ្ធភាពទទួលបានធនធាន និងពេលវេលា។ ការលាយបញ្ចូលគ្នានូវវិធីសាស្រ្តផ្សេងៗ ដូចជា ទិន្នន័យបរិមាណ (ឧទាហរណ៍ ចំនួនបង្គន់ដែលអាចប្រើបានក្នុងសហគមន៍) និងទិន្នន័យបែបគុណភាព (ឧទាហរណ៍ ថាតើប្រជាជនទាំងអស់កំពុងប្រើប្រាស់បង្គន់អនាម័យដោយពេញចិត្តនឹងគំរូប្លង់ ទីតាំងមានលទ្ធភាពប្រើប្រាស់។ល។ ដែរឬទេ? )។ កុំធ្វើការសន្មត់តាមរយៈ ការសង្កេត និងការនិយាយជាមួយប្រជាជន។

ទិន្នន័យទាំងអស់គួរតែត្រូវបានបែងចែកតាមអាយុ ភេទ និងពិការភាព។ យេនឌ័រ និងកត្តាសង្គម និងវប្បធម៌ផ្សេងៗទៀត (រាប់បញ្ចូលទាំងអាយុ ពិការភាព ស្ថានភាពសង្គម ជនជាតិភាគតិចជាដើម) បង្ហាញពីទំហំ និងកម្រិតរងគ្រោះ និងរងផលប៉ះពាល់ពីគ្រោះមហន្តរាយ។ យោងតាមការប្តេជ្ញាចិត្តស្តង់ដាអប្បបរិមារបស់ IFRC ចំពោះ យេនឌ័រ និងភាពចម្រុះនៅក្នុងកម្មវិធីគ្រោះមហន្តរាយ *IFRC Minimum Standard Commitments to Gender and Diversity in Emergency Programmes* ដើម្បីធានាថា ការប្តេជ្ញាចិត្តចំពោះសេចក្តីថ្លៃថ្នូរ ការទទួលបានការចូលរួម និងសុវត្ថិភាពរបស់សហគមន៍ដែលរងផលប៉ះពាល់ត្រូវបានដោះស្រាយនៅក្នុងការវាយតម្លៃ ក្នុងការធ្វើផែនការ ការអនុវត្ត និងការត្រួតពិនិត្យកម្មវិធីទឹកស្អាត និងអនាម័យ។

**ការវាយតម្លៃក្នុងការកំណត់រកបញ្ហា ត្រូវតែពិចារណាលើផ្នែកទាំងអស់នៃសហគមន៍ដោយមិនបំភ្លេចក្រុមដែលគេមើលរំលង និងក្រុមជនងាយរងគ្រោះ។**

### ទិន្នន័យបឋម និងមធ្យម

ទិន្នន័យបឋម (ត្រូវបានប្រមូលជាផ្នែកនៃការវាយតម្លៃផងដែរ) ដែលត្រូវតែពាក់ព័ន្ធនឹង ការយល់ដឹងអំពីឥរិយាបទអនាម័យ និងការផ្លាស់ប្តូរឥរិយាបទអនាម័យ។ កុំប្រមូលព័ត៌មានដែលមានរួចទៅហើយ - ដែលធ្វើឱ្យខ្ជះខ្ជាយពេលវេលា ធនធាន និងអាចរំខានដល់សហគមន៍ដែលធ្វើឱ្យពួកគាត់មានអារម្មណ៍ថា ពួកគេត្រូវបានគេសួរសំណួរដដែលៗ។ ប្រមូលទិន្នន័យបន្ទាប់បន្សំពីប្រភពផ្សេងៗគ្នា ថ្នាក់ជាតិ (បុគ្គលិក និងអ្នកស្ម័គ្រចិត្ត) ស្ថាប័នដែលធ្វើការក្នុងវិស័យទឹកស្អាត និងអនាម័យ ទីភ្នាក់ងាររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក។ បំពេញព័ត៌មានទាំងអស់ រួចប្រៀបធៀបគ្នា និងបំពេញចន្លោះខ្វះខាត។ ព័ត៌មានបន្ថែមស្តីពីបច្ចេកទេស និងឧបករណ៍វាយតម្លៃទឹកស្អាតអាចរកបាន here.

បច្ចេកទេសវាយតម្លៃអនាម័យដែលត្រូវបានប្រើភាគច្រើននៅក្នុងកាកបាទក្រហមអឌ្ឍចន្ទក្រហម គឺការសង្កេត និងការសម្ភាសន៍ផ្ទាល់ជាមួយអាជ្ញាធរមូលដ្ឋាន និងសមាជិកសហគមន៍ ជាពិសេសក្នុងដំណាក់កាលដំបូងនៃការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ។ ឧបករណ៍ផ្សេងទៀតត្រូវបានប្រើជាញឹកញាប់បន្ទាប់ពីការចាប់ផ្តើមនៃការឆ្លើយតបគ្រោះមហន្តរាយ ដូចជា កាតតំរៀបកាតជាបីជួរ គំនូសផែនទី តារាងការបោះឆ្នោតការស្ទង់មតិជាដើម គួរត្រូវបានប្រើភ្លាមៗពេលដែរសហគមន៍កំពុងត្រូវបានជម្រុញលើកទឹកចិត្ត និងយល់ព្រមធ្វើសកម្មភាពក្នុងពេលជាមួយគ្នានោះតែ ម្តង។ ឧបករណ៍មួយចំនួនអាចប្រើប្រាស់នៅក្នុងក្រុមមនុស្សតែមួយ មានដូចជា ការតម្រៀបកាតជាបីជួដោយមានការពិភាក្សាគ្នាជាក្រុមផ្តោតលើបរិបទ ពេលវេលាដែលមាន។ល។ វិធីសាស្ត្រឱ្យមានការចូលរួមជាក្រុមបែបនេះ មិនងាយស្រួលប្រើប្រាស់ក្នុងជំហានដំបូងនៃការឆ្លើយតបគ្រោះមហន្តរាយ ប៉ុន្តែអាចប្រើវិធីសាស្ត្រទាំងនេះតាមដែលអាចធ្វើទៅបានក្នុងពេលចាប់ផ្តើមដំបូងនៃការវាយតម្លៃកំណត់រកបញ្ហាដោយធ្វើការជាមួយបុគ្គលិកតាមមូលដ្ឋាន និងសហគមន៍។

ទិន្នន័យបន្ទាប់បន្សំអាចត្រូវបានប្រមូលពីប្រភពផ្សេងៗគ្នាដូចជាតាមមូលដ្ឋាន និងតាមក្រសួងរពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន គ្លីនិក សុខភាព នៅតាមស្រុក ឬសហគមន៍ និងភ្នាក់ងារផ្សេងទៀតដែលធ្វើការនៅក្នុងសហគមន៍។ ការប្រមូលទិន្នន័យបន្ទាប់បន្សំពីប្រភពដែលអាចទុកចិត្តបាន គឺមានសារៈសំខាន់ណាស់។

នៅពេលទិន្នន័យប្រមូលរួចរាល់ហើយ នឹងត្រូវយកទៅវិភាគ ប្រៀបធៀបព័ត៌មានទិន្នន័យពីប្រភពផ្សេងៗគ្នា ពិនិត្យមើលព័ត៌មានដែលបានប្រមូលថាតើមានភាពពាក់ព័ន្ធ និងមានប្រយោជន៍ក្នុងការឆ្លើយតបនឹងសំនួរសំខាន់ៗពីបញ្ហារបស់ប្រជាជនដែលរងផលប៉ះពាល់ ពីសមត្ថភាព និងតម្រូវការរបស់ពួកគេដែរឬ។ ការវិភាគគឺ ជាជំហានចាំបាច់បំផុតដែលនឹងជួយឱ្យស្វែងយល់ពីស្ថានភាព និងឆ្លើយតបឱ្យកាន់តែមានប្រសិទ្ធភាព។ កុំទុកការវិភាគរហូតដល់ចុងបញ្ចប់នៃការវាយតម្លៃ។ រៀបចំព័ត៌មាន វិភាគទិន្នន័យព័ត៌មានពីប្រភពផ្សេងៗគ្នាជាមួយវិធីសាស្ត្រផ្សេងៗគ្នា ដើម្បីពិនិត្យមើលគម្លាត និងភាពមិនស៊ីចង្វាក់គ្នានៃទិន្ន័យ។

របាយការណ៍វាយតម្លៃច្បាស់លាស់មានសារៈសំខាន់ណាស់ ក្នុងការផ្តល់ព័ត៌មានមូលដ្ឋានសម្រាប់ការរៀបចំផែនការកម្មវិធី និងការតាមដាន។

**កំណត់ចំណាំ: កត់ត្រា ចែករំលែក ហើយយកពត៍មាននោះមកប្រើ!**

| **Q: តើមានបញ្ហាអ្វីខ្លះនៅពេលធ្វើការវាយតម្លៃកំណត់រកបញ្ហាក្នុងពេលភ្លាមៗ ?** |
|---|
| ១. ពេលមានគ្រោះមហន្តរាយជាទ្រង់ទ្រាយធំ មានការលំបាកក្នុងការកំណត់ក្រុមដែលមានហានិភ័យ និងងាយរងគ្រោះបំផុត។ ការសម្របសម្រួល និងការសហការជាមួយអង្គការដទៃទៀតគឺចាំបាច់ដើម្បីធានាថាមិនមានចន្លោះប្រហោង និងជៀសវាងការជាន់ព័ត៌មានគ្នា។ បំណងសំខាន់ក្នុងការប្រមូលព័ត៌នេះ គឺចេញពីតំបន់ដែលរងផលប៉ះពាល់ខ្លាំងបំផុត។<br>២. ដោយសារការវាយតម្លៃភ្លាមៗ ទើបនឹងចាប់ផ្តើមដំបូង អញ្ចឹងគឺផ្តោតតែទៅលើក្រុមដែលងាយរងគ្រោះបំផុត ដូច្នេះមិនអាចអាចប្រមូលព័ត៌មានទូទៅសម្រាប់តំបន់ដែលរងផលប៉ះពាល់ទាំងស្រុងនោះទេ។<br>៣. ទិន្នន័យអាចក្លាយទៅជាហួសកាលបរិច្ឆេទ ឬលែងពាក់ព័ន្ធ ជាពិសេសក្នុងពេលមានគ្រោះមហន្តរាយដែលពាក់ព័ន្ធនឹងចលនាប្រជាជនដែលការផ្លាស់ប្តូរ។ |

| |
|---|
| ៤. ការវាយតម្លៃភ្លាមៗពីការកំណត់រកបញ្ហារពេលមានគ្រោះមហន្តរាយ ត្រូវការចំណាយពេលវេលាច្រើនដើម្បីបញ្ចប់ជាពិសេសក្នុងពេលមានបរិយាកាសរឹករវរ ដូច្នេះត្រូវយកចិត្តទុកដាក់កុំចំណាយពេលវេលាយូរពេកលើការវាយតម្លៃនេះ និងពន្យាពេលការអនុវត្តដើម្បីឆ្លើយតបទៅនឹងតម្រូវការអាទិភាព។ |
| **Q: ក្រុមគួររង់ចាំរហូតដល់ការវាយតម្លៃត្រូវបានបញ្ចប់មុននឹងឆ្លើយតបនឹងគ្រោះមហន្តរាយ?** |
| ប្រសិនបើមានតម្រូវការគ្រោះមហន្តរាយកើតឡើងភ្លាមៗ ត្រូវតែឆ្លើយតប ឧទាហរណ៍ ដើម្បីឆ្លើយតបទៅនឹងការផ្ទុះឡើងនៃជំងឺអាសន្នរោគ ប្រជាជនត្រូវការការជួយ និងផ្តល់ព័ត៌មានស្តីពីការបន្សុទ្ធទឹកសម្រាប់ផឹក ប៉ុន្តែត្រូវធ្វើការវាយតម្លៃកំណត់រកបញ្ហាភ្លាមៗ ដើម្បីប្រាកដថាការឆ្លើយតបប្រកបដោយប្រសិទ្ធភាព។ ឧទាហរណ៍ក្នុងពេលមានការផ្ទុះជំងឺអាសន្នរោគ ការផ្សព្វផ្សាយតាមរយៈផ្ទាំងអក្សរធំៗ មិនមានប្រសិទ្ធិភាពបើប្រជាជនមិនអាចអានអក្សរបាន ហើយបើគ្មានការវាយតម្លៃកំណត់រកបញ្ហារឱ្យបានត្រឹមត្រូវទេ ព័ត៌មាននេះប្រហែលជាមិនត្រូវបានគេដឹងទេ។ លើសពីនេះទៀតការធ្វើសកម្មភាពលើកកម្ពស់អនាម័យពីរទៅបីដងនៅក្នុងសហគមន៍នឹងធ្វើឱ្យអ្នកផ្សព្វផ្សាយទទួលបានការណែនាំពីអ្វីដែលត្រូវធ្វើ និងដឹងពីអ្វីដែលប្រជាជនអាចទទួលយកនិងចូលចិត្តចង់ធ្វើពេលមានគ្រោះមហន្តរាយ។ |

## ជំហានទី២ :ការកំណត់ក្រុមគោលដៅ



ជំហានទី២ នៃដំណើរការអភិវឌ្ឍផែនការលើកកម្ពស់អនាម័យគឺការកំណត់ក្រុមគោលដៅ។ ចំពោះហានិភ័យឬបញ្ហាអនាម័យនិមួយៗដែលបានកំណត់នៅក្នុងការវាយតម្លៃ (ជំហានទី១) វាចាំបាច់ត្រូវកំណត់រកថាតើអ្នកណាដែលត្រូវផ្តល់ អាទិភាពមុនគេ។

ចាំបាច់ត្រូវពិចារណាចំនុចដូចខាងក្រោម:

- កំណត់អត្តសញ្ញាណអ្នកដែលមានគ្រោះថ្នាក់បំផុត។ ដើម្បីធានាថាសកម្មភាពទឹកស្អាត និងអនាម័យទាំងអស់បានដល់អ្នកដែលងាយរងគ្រោះបំផុត ការវិភាគយេនឌ័រនិងភាពចម្រុះគួរ តែត្រូវបានធ្វើឡើងសម្រាប់ការជ្រើសរើសក្រុមគោលដៅនិងការកំណត់របៀបចូលរួមរបស់ក្រុមគោលដៅ។
- ប្រសិនបើធ្វើការនៅក្នុងជំរុំជនភៀសខ្លួនឬជំរុំសម្រាប់ប្រជាជនដែលផ្លាស់ប្តូរទីលំនៅ ត្រូវគិតពីប្រជាជនដែលរស់នៅជុំវិញនោះទៅតាមបរិបទជាក់ស្តែង។
- កំណត់អត្តសញ្ញាណអ្នកដែលមានឥទ្ធិពល (ឧ. សហគមន៍ និងអ្នកដឹកនាំសាសនា) នៅក្នុងសហគមន៍ធ្វើការវិភាគអ្នកពាក់ព័ន្ធ។

- កំណត់រកផ្នែកផ្សេងៗដែលនាំឱ្យរងផលប៉ះពាល់នៅក្នុងសហគមន៍ ត្រូវគិតពិចារណាលើតម្រូវការផ្សេងៗរបស់ពួកគេ ដោយរាប់បញ្ចូលទាំងកុមារ មនុស្សចាស់ ជនពិការ ក្រុមជនដែលគេមើលរំលង ក្រុមលាក់ខ្លួន និងអ្នកពាក់ព័ន្ធផ្សេងទៀត។
- ត្រូវយកចិត្តទុកដាក់ឱ្យបានខ្លាំងខ្លាពីតម្រូវការរបស់ទារក កុមារតូចៗ ដោយសារតែពួកគេត្រូវការហេដ្ឋារចនាសម្ព័ន្ធអនាម័យដែលមានលក្ខណៈពិសេសផ្សេងៗគ្នា។
- ធានាថាក្រុមដែលទទួលរងផលប៉ះពាល់ពីការកខ្វះអនាម័យខ្លាំងមានដូច ការគ្រប់គ្រងអនាម័យពេលមានរដូវសម្រាប់ស្ត្រី និងក្មេងជំទង់ត្រូវបានគេគិតគូរពិចារណា។

ការសម្រេចចិត្តរបស់មនុស្សគឺអាស្រ័យលើព័ត៌មានដែលពួកគេមាន និងសមត្ថភាពរបស់ពួកគេក្នុងការចូលរួមនិងការលើកទឹកចិត្តពីកម្មវិធីនេះ។ ការចូលរួមពេញលេញរបស់ពួកគេអាចនឹងមិនបានច្រើននៅពេលចាប់ផ្តើមមានគ្រោះមហន្តរាយ និងជាពិសេសពេលមាន ពេលគ្រោះមហន្តរាយធ្ងន់ធ្ងរ ដោយមានការបំផ្លិចបំផ្លាញមានការបាត់បង់មនុស្ស និងមានការរងរបួស ប៉ុន្តែក៏ត្រូវមានការពិគ្រោះយោបល់និងព័ត៌មានចាំបាច់កម្រិតមូលដ្ឋានត្រូវបានធ្វើឡើងតាំងពីការចាប់ផ្តើមដំបូងនៃប្រតិបត្តិការ។ ពេលដែលស្ថានភាពគ្រោះមហន្តរាយចាប់ផ្តើមមានស្ថេរភាព សហគមន៍ដែលរងផលប៉ះពាល់ចាំបាច់ត្រូវចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការរៀបចំផែនការនិងការជ្រើសរើសគោលដៅដើម្បីការផ្លាស់ប្តូរឥរិយាបទ។

ធ្វើការជាមួយវិស្វករនៅពេលកំណត់រកក្រុមគោលដៅ ចុះទៅមើលសហគមន៍ជាមួយគ្នា ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងចំណេះដឹងត្រូវតែផ្សាភ្ជាប់ជាមួយគ្នា។

គោលគំនិតសំខាន់ត្រូវគិតអំពីការវាយតម្លៃថាតើក្រុមផ្សេងគ្នានៅក្នុងក្រុមគោលដៅទំនាក់ទំនងគ្នាយ៉ាងដូចម្តេច រួមទាំងវិធី ដែលសមាជិកនៅក្នុងសហគមន៍ពិការ គ ថ្លង់ ទំនាក់ទំនងគ្នា។ ការដឹងពីទម្លាប់នៃការប្រាស្រ័យទាក់ទងរបស់ពួកគេមុនពេលមានគ្រោះមហន្តរាយ និងរបៀបដែលពួកគេប្រាស្រ័យទាក់ទងគ្នាធ្វើឱ្យយើងងាយស្រួលក្នុងការជ្រើសរើសរបៀបប្រាស្រ័យទាក់ទងពេលមានគ្រោះមហន្តរាយនៅពេលបន្តបន្ទាប់ទៀត។ ការយល់ដឹងបែបនេះក៏ជាផ្នែកមួយនៃការវាយតម្លៃកំណត់បញ្ហាផងដែរ។ ស្វែងយល់អំពីជីវិតរស់នៅប្រចាំថ្ងៃរបស់ក្រុមផ្សេងៗគ្នា ថាតើពួកគាត់មានអ្វីខ្លះ សម្រាប់ឆ្លើយតប និងទំនាក់ទំនងគ្នាទៅវិញទៅមក ហើយតើបណ្តាញណាខ្លះដែលមានប្រសិទ្ធភាពខ្លាំងក្នុងការផ្តល់ព័ត៌មានពីការលើកកម្ពស់អនាម័យ។

| Q: នៅពេលមានការផ្ទុះជំងឺអាសន្នរោគមនុស្សគ្រប់គ្នានៅក្នុងសហគមន៍គឺបានរងផលប៉ះពាល់រួចទៅហើយ? |
| --- |
| ពិតណាស់នៅពេលមានការផ្ទុះឡើងជំងឺអាសន្នរោគ ការលើកកម្ពស់អនាម័យគឺមានសារៈសំខាន់សម្រាប់សមាជិកសហគមន៍ទាំងអស់ ប៉ុន្តែវិធីសាស្ត្រដែលយកមកធ្វើការផ្សព្វផ្សាយអនាម័យមានភាពខុសគ្នាៗសម្រាប់ក្រុមផ្សេងៗគ្នា - ក្រុមគោលដៅចម្បងគឺសមាជិកគ្រួសារនៅក្នុងសហគមន៍ ឧទាហរណ៍ កុមារ ឪពុកម្តាយ ជីដូនជីតា និងអ្នកថែទាំកុមារ។ ក្រុមគោលដៅនីមួយៗត្រូវតែចែកក្រុមផ្សេងពីគ្នាព្រោះវិធីសាស្ត្រដើម្បីផ្សព្វផ្សាយ (ដើម្បីផ្តល់ព័ត៌មាន និងឱ្យមានការចូលរួម) នឹងខុសគ្នា។ ក្រុមទី២ ជាក្រុមមនុស្សដែលមានឥទ្ធិពលក្នុងការធ្វើសកម្មភាព និងជួយក្រុមផ្សេងទៀតបាន (ឧទាហរណ៍មេដឹកនាំសហគមន៍មូលដ្ឋានដែលអាចជួយផ្សព្វផ្សាយព័ត៌មានស្តីពីវិធីសាស្ត្រអនាម័យត្រឹមត្រូវ) |

## ជំហានទី ៣: ការទតាតរកឧបសគ្គ និង ការលើកទឹកចិត្ត ឱ្យមានការផ្លាស់ប្តូរឥរិយាបថ



ក្នុងជំហានទី១ ហានិភ័យសុខភាពសាធារណៈសំខាន់ៗ និងតម្រូវការ ត្រូវបានកំណត់រក។ ក្នុងជំហានទី២ អ្នកទាំងឡាយណាដែលមានហានិភ័យខ្ពស់បំផុតចាំបាច់ត្រូវផ្តល់អាទិភាពក្នុងការបញ្ចូលទៅក្នុងការកំណត់អត្តសញ្ញាណក្នុងពេលមានគ្រោះមហន្តរាយ។ **ជំហានទី២** ក៏បានជួយឱ្យយល់ពីរបៀបដែលអាចលើកទឹកចិត្តពួកគាត់ឱ្យចូលរួមក្នុងសកម្មភាព និងរបៀបក្នុងការផ្សព្វផ្សាយព័ត៌មានដល់ពួកគាត់។

**ជំហានទី៣** នឹងជួយអ្នកផ្សព្វផ្សាយអនាម័យឱ្យយល់ពីអាកប្បកិរិយារបស់ប្រជាជនតាមរយៈការស្តាប់ និងពិភាក្សាជាមួយគ្រប់ផ្នែកទាំងអស់នៃសហគមន៍។ ស្វែងយល់ពីអាកប្បកិរិយារបស់ពួកគេនិងអ្វីដែលជម្រុញអាកប្បកិរិយាទាំងនេះ។ ទាំងនេះត្រូវបានជះឥទ្ធិពលដោយបរិបទ ជំនឿតម្លៃ និងសម្ពាធសង្គម ។ ក្នុងពេលមានគ្រោះមហន្តរាយ មានឧបសគ្គ និងផលពិបាកជាច្រើន។

មានព័ត៌មានជាច្រើនដែលបានបង្ហាញអំពីបញ្ហាស្មុគស្មាញនៃការផ្លាស់ប្តូរអាកប្បកិរិយា។ ការសិក្សាពីតម្រូវការមុនពេលមានគ្រោះមហន្តរាយ ដើម្បីធ្វើការផ្សព្វផ្សាយអនាម័យ ត្រូវជៀសវាងការសន្មត់ថាចំណេះដឹងទាក់ទងនឹងមេរោគនិងជំងឺជំងឺឆ្លងអាចផ្លាស់ប្តូរអាកប្បកិរិយារបស់សហគមន៍។ ដើម្បីផ្លាស់ប្តូរអាកប្បកិរិយា គឺមានភាពស្មុគស្មាញជាងការផ្តល់ព័ត៌មានទៅទៀត ឧទាហរណ៍ ប្រាប់នរណាម្នាក់ឱ្យលាងដៃហើយរំពឹងថាគេនឹងធ្វើវា។

វិធីសាស្ត្រផ្លាស់ប្តូរអាកប្បកិរិយា ជាដំបូងត្រូវទទួលស្គាល់ថាប្រជាជនដែលរស់នៅក្នុងស្ថានភាពគ្រោះមហន្តរាយធ្ងន់ធ្ងរអាចធ្វើឥរិយាបថអនាម័យដូចដែលគាត់ធ្លាប់មានមុនពេលមានគ្រោះមហន្តរាយ។ អញ្ចឹងចាំបាច់ណាស់ក្នុងការស្វែងរកអាកប្បកិរិយាទាំងនេះនៅពេលធ្វើការវាយតម្លៃកំណត់រកបញ្ហា ពេលកំណត់រកមធ្យោបាយជួយសហគមន៍គឺត្រូវរកអ្វីដែលសមស្រប ហើយមាននិរន្តភាពឱ្យសហគមន៍ដែលរងផលប៉ះពីគ្រោះមហន្តរាយនៅបន្តធ្វើសកម្មភាពនោះទៀត។

មួយវិញទៀត ចាំបាច់ត្រូវពិនិត្យមើលឧបសគ្គ និងកត្តាលើកទឹកចិត្ត - ពួកគេមិនអាចមានគំនិតដូចអ្វីដែលអ្នកគិតនោះទេ!

ក្នុងអំឡុងពេលនៃការវាយតម្លៃកំណត់បញ្ហា ក្រុមអ្នកប្រមូលព័ត៌មានអំពីការលើកទឹកចិត្តផ្សេងៗគ្នា ដែលអាចជួយឱ្យប្រជាជនដែលរងផលប៉ះពាល់ផ្លាស់ប្តូរក្នុងជំហាននេះគឺជាផ្នែកមួយនៃការវាយតម្លៃកំណត់បញ្ហា។

*កត្តាលើកទឹកចិត្ត* : អ្វីដែលនឹងជម្រុញឱ្យមនុស្សអនុវត្តទម្លាប់អនាម័យត្រឹមត្រូវ។ មានការបង្ហាញថា មនុស្សភាគច្រើន មិនចង់ចែករំលែកពីអ្វីដែលគាត់ធ្វើ ពីបរិបទ រូបវន្តវប្បធម៌ និងសង្គម ដែលជាកត្តាជម្រុញចិត្ត និងអារម្មណ៍សំខាន់ៗដល់ជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេឡើយ។ កត្តាជម្រុញទាំងអស់នោះ ត្រូវបានគេស្គាល់ថាជាកត្តាជម្រុញសកល ហើយអាចត្រូវបានចាត់ថ្នាក់ដូចខាងក្រោម:

| កត្តាជម្រុញទឹកចិត្ត | ចំនោរ | ឧទាហរណ៍ |
|---|---|---|
| ការស្អប់ខ្ពើម | ទំនោរដើម្បីជៀសវាងពីអ្វីមួយ និង ស្ថានភាពណាមួយដែលនាំឱ្យមានហានិភ័យនាំឱ្យកើតជំងឺផ្សេងៗ | លាមក ទឹកនោម វត្ថុរាវចេញរាងកាយ និង វត្ថុរលួយ ឬងាប់ត្រូវបានគេរកឃើញថាមានលក្ខណៈទូរទៅគួរឱ្យស្អប់ខ្ពើម។ សម្រាប់អ្នកខ្លះក្លិនឬការមើលឃើញលាមក គឺគ្រប់គ្រាន់ជម្រុញឱ្យគាត់ធ្វើការលាងដៃ។ |
| ភាពខ្ពង់ខ្ពស់ | ទំនោរក្នុងការស្វែងរកធ្វើឱ្យប្រសើរឡើងនូវឋានៈសង្គម | ការមើលឃើញថាស្អាតអាចនាំឱ្យមានការកោតសរសើរនិងការគោរព បើត្រូវបានគេដាក់ថា "កខ្វក់" ត្រូវបានគេគិតថាគួរឱ្យខ្មាស់អៀននិងត្រូវបានគេជៀសវាងនៅគ្រប់ប្រការទាំងអស់។ |
| ភាពជាប់ទាក់ទងគ្នា | ទំនោរក្នុងការស្វែងរកការស្របតាមដើម្បីទទួលបានអត្ថប្រយោជន៍នៃការរស់នៅក្នុងសង្គម | ជាប្រជាជនល្អនៅក្នុងសង្គម តាមរយៈការចូលរួមនិងធ្វើអ្វីដែលអ្នកទាំងអស់គ្នាយល់ពីអ្វីកំពុងធ្វើ ថាមានសារៈសំខាន់ក្នុងការលើកទឹកចិត្តឱ្យអនុវត្តទម្លាប់អនាម័យល្អ។ ប្រការនេះជួយធានាឱ្យមានសមាជិកភាពនៅក្នុងក្រុមសង្គម។ អនុលោមទៅតាមបទដ្ឋានតាមតំបន់និមួយៗ ត្រូវបានគេដឹងថាជាកត្តាជម្រុញឥរិយាបទដ៏មានឥទ្ធិពល។ |
| ភាពទាក់ទាញ | ទំនោរត្រូវបានធ្វើឱ្យទាក់ទាញ និង ចង់ឱ្យចាប់អារម្មណ៍ និងអ្នកដែលឱ្យតម្លៃខ្ពស់ | នៅក្នុងវប្បធម៌ខ្លះ ភាពស្អាតគឺជាសិល្បៈដែលទាក់ទាញចិត្ត។ ចំណាំថា វប្បធម៌ដែលឱ្យតម្លៃទៅលើភាពថ្លៃថ្នូរ និងភាពបរិសុទ្ធកត្តាជម្រុញលើកទឹកចិត្តនេះមិនអាចយក មកពិភាក្សាយ៉ាងងាយស្រួលនោះទេ។ |
| ការចិញ្ចឹមបីបាច់ | ទំនោរចង់ថែរក្សាកូនចៅ។ | ឪពុកម្តាយ ជាពិសេសម្តាយ តែងតែគិតពីកូនៗមុនគេ។ ម្តាយមានអារម្មណ៍ថាមានការទទួលខុសត្រូវនិងមានកាតព្វកិច្ចខ្ពស់ក្នុងការធានាឱ្យមានដំណើរការល្អដើម្បីឱ្យកូនលូតលាស់បានល្អ។ អារម្មណ៍ទាំងនេះអាចរឹតតែធ្ងន់ធ្ងរថែមទៀតនៅពេលមានគ្រោះមហន្តរាយ។ |
| មានផាសុខភាព | ទំនោរក្នុងការដាក់នណាមនុស្សម្នាក់នៅក្នុងភាពស្រស់ស្អាតខាងក្រៅ និង ភាពល្អបំផុតនៅខាងក្នុង<br>. | មនុស្សឱ្យតម្លៃលើស្បែកដែលមិនមានសារធាតុគួរឱ្យស្អប់ខ្ពើមនិងមានអារម្មណ៍ស្រស់ថ្លា ៖ ភាពស្អាតស្អំបង្កប់នូវផាសុខភាពពីខាងក្នុង ភាពស្រស់ស្រាយ ការត្រៀមខ្លួនជាស្រេច ភាពជឿជាក់ និងភាពបរិសុទ្ធ។ |

| | | |
|---|---|---|
| <u>ការភ័យខ្លាច</u> | ទំនោរក្នុងការជៀសវាងពីអ្វីមួយ និងស្ថានភាពដែលមានហានិភ័យពីការរងរបួសឬការស្លាប់ (ការភ័យខ្លាចពីសុខភាពត្រូវបានប្រើក្នុងពេលកន្លងមកក្នុងកំឡុងពេលឆ្លើយតបទៅនឹងគ្រោះមហន្តរាយជុំវិញជំងឺដែលគំរាមកំហែងដល់អាយុជីវិត ដូចជាអាសន្នរោគ និងមេរោគអ៊ីបុឡា និងជំងឺផ្សេងៗទៀត) | ឧទាហរណ៍របាយការណ៍បានលើកឡើងថាការលាងដៃបានកើនឡើងក្នុងកំឡុងពេលមានជំងឺរាគត្បាត (អ៊ូហ្គង់ដាសេណេហ្គាល់កេនយ៉ានិងប៉េរូ) ប៉ុន្តែប្រជាជនបានរាយការណ៍ថាពួកគេបានត្រឡប់ទៅទម្លាប់លាងដៃធម្មតារបស់ពួកគេវិញនៅពេលដែលគ្រោះមហន្តរាយនេះបានកន្លងផុតទៅ។ |

បច្ចេកទេសវាយតម្លៃដូចជាការពិភាក្សាជាក្រុម និងការសម្ភាសន៍ព័ត៌មានសំខាន់ៗអាចស៊ើបអង្កេតពីអ្វីដែលជាកត្តាជម្រុញទឹកចិត្ត និងជម្រុញអារម្មណ៍អាចត្រូវបានដាក់បញ្ចូលក្នុងផែនការផ្លាស់ប្តូរឥរិយាបទ ដើម្បីជះឥទ្ធិពលដល់ការជ្រើសរើសសកម្មភាពផ្សព្វផ្សាយ និងការបង្កើតសារអនាម័យ។

បច្ចេកទេសវាយតម្លៃដូចគ្នាដែលបានលើកឡើងខាងលើក៏គួរតែផ្តល់នូវភស្តុតាងនូវអ្វីដែលរារាំងមនុស្សមិនឱ្យធ្វើសកម្មភាពបានដោយៈ

- **ឧបសគ្គ** ៈអ្វីដែលនឹងរារាំងមនុស្សពីការអនុវត្តអាកប្បកិរិយាអនាម័យត្រឹមត្រូវ ឧទាហរណ៍ឧបសគ្គរូបវន្ត - មានរបស់ប្រើប្រាស់សម្រាប់ការធ្វើអនាម័យ ដូចជាសាប៊ូ ទឹក បង្គន់សមរម្យ ឧបសគ្គសង្គម - បទដ្ឋាន និងទំនៀមទម្លាប់ ការខ្វះការជឿទុកចិត្តលើការងារសុខភាពនិងព័ត៌មានសុខភាព ឧបសគ្គខាងជីវសាស្រ្ត - ស្ថានភាពផ្លូវចិត្ត ឧបសគ្គព័ត៌មាន - កង្វះព័ត៌មានជាភាសាមូលតាមតំបន់ ឬភាសាសញ្ញា។ តារាងខាងក្រោមពន្យល់ពីឧបសគ្គផ្សេងៗគ្នាលម្អិតៈ

| | |
|---|---|
| **ឧបសគ្គវប្បធម៌សង្គម** | • នៅក្នុងវប្បធម៌ខ្លះការអនុវត្តអនាម័យដូចជាការលាងដៃជាមួយសាប៊ូអាចត្រូវបានជៀសវាងដោយសារទំនៀមទម្លាប់និងជំនឿក្នុងតំបន់ផ្សេងៗគ្នា។ ដូចជាសាប៊ូមិនត្រូវបានគេប្រើនោះទេព្រោះវាត្រូវបានគេចាត់ទុកថានាំមកនូវសំណាងអាក្រក់ កាត់បន្ថយអាយុ ចុះខ្សោយភាពធន់នៃរាងកាយទៅទប់ទល់នឹងជំងឺខាងក្រៅ និងមានអាបធ្មប់មកធ្វើបាប ឬគ្រោះថ្នាក់ដល់ស្ត្រីមានផ្ទៃពោះឬប៉ះពាល់នៅពេលមានរដូវ។<br>• ជំនឿទាំងនេះមានភាពចម្រុះ និងខុសគ្នាៗទៅតាមវប្បធម៌តាមតំបន់ខុសគ្នា។ ទោះយ៉ាងណាមនុស្សទូទៅមិនចែករំលែកជំនឿបែបនេះដល់អ្នកសម្ភាសន៍ទេលើកលែងតែមានការបំផុសគំនិតសម្រាប់ហេតុផលដែលពួកគេគិតថាជាអបិយជំនឿ។<br>• ការអនុវត្តអនាម័យមួយចំនួនដូចជាការលាងដៃពេលខ្លះអាចត្រូវបានគេចាត់ទុកថាជាអ្វីមួយដែលធ្វើដោយខ្លួនឯងបានដូច្នេះមិនត្រូវបានគេយល់ថាជាបទដ្ឋានសង្គមទេ។ |

| | |
|---|---|
| | • ទំនាក់ទំនងយេនឌ័រជះឥទ្ធិពលទៅលើមធ្យោបាយបែងចែកទឹកទៅឱ្យសមាជិកគ្រួសារនីមួយៗ ដែមិនអាចទទួលបានចំណែកស្មើៗគ្នាទេដូចជាស្ត្រី កុមារ ជនពិការ ចាស់ជរាជាដើម ។ |
| **ឧបសគ្គរូបវន្ត** | • កត្តាររូបវ័ន្តដែលជះឥទ្ធិពលដល់ការអនុវត្តន៍ឥរិយាបថអនាម័យសំខាន់ៗក្នុងពេលមានគ្រោះមហន្តរាយរួមមានទឹកសាប៊ូ និងបង្គន់។<br>• ការទទួលបានទឹកគ្រប់គ្រាន់គឺជាឧបសគ្គសំខាន់ក្នុងពេលមានគ្រោះមហន្តរាយ។ នៅពេលដែលសេវាកម្មទឹកស្អាត ត្រូវបានផ្តល់ឱ្យមិនគ្រប់គ្រាន់គឺនៅតែជាបញ្ហាសម្រាប់មនុស្សមួយចំនួននៅពេលមានគ្រោះមហន្តរាយ។ ប្រភពទឹកពិសេសសម្រាប់លាងដៃត្រូវការទីតាំងនៅជិតបង្គន់។<br>• សាប៊ូ មិនអាចប្រើបាននៅពេលចាប់ផ្តើមនៃគ្រោះមហន្តរាយ។ នៅពេលចែកចាយសាប៊ូដុំ នៅតែមានការពិបាកក្នុងការប្រើប្រាស់ដោយសារតែសមាជិកគ្រួសារទុក និងខ្ចប់វាដើម្បីការពារភាពខ្ជះខ្ជាយ ឬការកខ្វក់ ឬពីការបរិសត្វចិញ្ចឹមស៊ី។ គួរកត់សម្គាល់ថាភាពងាយស្រួលនៃការប្រើប្រាស់គឺសំខាន់ត្រូវមានសាប៊ូនៅជិតបង្គន់អនាម័យនិងនៅជិតផ្ទះបាយជម្រុញឱ្យមនុស្សលាងដៃឱ្យបានច្រើនជាជាងមិនមាននៅជុំវិញឬត្រូវទៅកន្លែងផ្សេងដើម្បីរកសាប៊ូលាងដៃ។<br>• មានចំនួនបង្គន់អនាម័យគ្រប់គ្រាន់ និងអាចប្រើប្រាស់បានក្នុងពេលមានគ្រោះមហន្តរាយ គឺជាដំណោះស្រាយដ៏អស្ចារ្យមួយ។ បង្គន់សាធារណៈឬកន្លែងបន្ទោរបង់ដែលបានផ្តល់ឱ្យនៅពេលចាប់ផ្តើមគ្រោះមហន្តរាយអាចនៅឆ្ងាយ ពិបាកថែទាំ និងមិនមែនជាជម្រើសដែលសមស្របសម្រាប់ក្រុមងាយរងគ្រោះដូចជា ស្ត្រី កុមារ និងអ្នកដែលពិបាកបំលាស់ទី។ |
| **ឧបសគ្គ ជីវសាស្ត្រ** | • ម្តាយនិងអ្នកមើលថែរក្មេង តែងតែរវល់ក្នុងពេលមានគ្រោះមហន្តរាយដើម្បីធានាឱ្យមានទីជម្រក និងការផ្គត់ផ្គង់របស់របរសង្គ្រោះ។ បញ្ហាទាំងនោះត្រូវការដោះស្រាយបន្ទាន់ ប្រើពេលច្រើនជាងមុនសម្រាប់អនាម័យផ្ទាល់ខ្លួន និងនៅក្នុងផ្ទះ។<br>• នៅពេលចាប់ផ្តើមមានគ្រោះមហន្តរាយ ម្តាយនិងអ្នកមើលថែអាចអស់កំលាំង ហត់នឿយ និងអស់កំលាំងចិត្តដោយសារផ្តោតលើបញ្ហាដែលមិនមែនជាអាទិភាព ហើយទុកចោលនៅការងារដែលត្រូវធ្វើដើម្បីសង្គ្រោះជីវិត (ដូចជា ទឹក អាហារ និងទីជម្រក) |

ឧបករណ៍ ការធ្វើផែនដូចតារាងខាងក្រោម (តារាងគំរូដើម្បីវិភាគឧបសគ្គនិងកត្តាជម្រុញ) ដែលរកឃើញឧបសគ្គ និងកត្តាជម្រុញសម្រាប់ក្រុមគោលដៅជាក់លាក់ ហេតុផល និងការយល់ដឹងពីទម្លាប់ជាក់ស្តែងត្រូវបានប្រើ ដើម្បីយល់ពីឥរិយាបទផ្សេងគ្នាៗ និងវិភាគពីរឥរិយាបទរបស់ពួកគេទាំងនោះ។

**ឧបករណ៍ គំរូ ដើម្បីវិភាគឧបសគ្គនិងកត្តាជម្រុញ**

| ក្រុមគោលដៅ | អាកប្បកិរិយា | ឧបសគ្គ | កត្តាជម្រុញ លើកទឹកចិត្ត | វិធីសាស្ត្រកាត់បន្ថយឧបសគ្គ | វិធីសាស្ត្របង្កើនកត្តាជម្រុញលើកទឹកចិត្ត |
|---|---|---|---|---|---|
| ស្ត្រីមានផ្ទៃពោះ | អត់ប្រើ សាប៊ូ សម្រាប់ | **ឧបសគ្គ វប្បធម៌-<u>សង្គម</u>**: | **ចិញ្ចឹមបីបាច់**: បំណងប្រាថ្នា | ពន្យល់ឱ្យបានច្បាស់ពីការយល់ច្រឡំនៃការប្រើ | ម្ចាស់ជើងឯកសហគមន៍ - រូបភាព / ខ្សែភាពយន្តរបស់ស្ត្រី |

| | | | | | |
|---|---|---|---|---|---|
| | លាងដៃនិងខ្លួនប្រាណ | ជំនឿថាសាប៊ូនាំមកនូវសំណាងអាក្រក់និងបណ្តាលឱ្យរលូតកូន | ដើម្បីការពារកុមារ | សាប៊ូដោយមានជំនួយពីអ្នកដឹកនាំសហគមន៍ / បុគ្គលិកសុខាភិបាល | ដែលត្រូវបានគេយល់ថាជាម្តាយល្អលាងដៃជាមួយសាប៊ូ |
| | | **ឧបសគ្គរូបវន្ត:** គ្មានសាប៊ូ | **សម្ព័ន្ធភាព៖** មានបំណងចង់ឱ្យអ្នកដទៃមើលឃើញនិងយល់ថាគេជាម្តាយល្អ | ចែកចាយសាប៊ូ | លើកកម្ពស់គំនិតដែលមនុស្សគ្រប់គ្នាកំពុងធ្វើ |

ការវិភាគលើកត្តាដែលរារាំងមិនឱ្យអនុវត្តល្អគួរធ្វើជាមួយសមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀត

*ឧបសគ្គរារាំងការផ្លាស់ប្តូរឥរិយាបទ*

សូមចងចាំថាកត្តាដែលបញ្ឈប់មនុស្សឱ្យមានឥរិយាបទល្អមិនទាក់ទងនឹងការកង្វះចំណេះដឹងអំពីទ្រឹស្តីមេរោគឆ្លងឬផ្លូវចម្លងជំងឺទេ។ ភាគច្រើនឧបសគ្គទាំងនោះទាក់ទងទៅនឹងកត្តាវប្បធម៌សង្គម (ក្នុងវប្បធម៌ខ្លះស្ត្រី និងឪពុកក្មេកមិនអាចប្រើបង្គន់តែមួយបានទេ) សាសនា (សម្ភារៈ និងបង្គន់ត្រូវដាក់នៅកន្លែងមួយជាក់លាក់) ឬរូបវន្ត (អវត្តមានកន្លែងលាងដៃ រឺគ្មានលទ្ធភាពប្រើប្រាស់កន្លែងលាងដៃនោះបាន) ។ កុំធ្វើការសន្មតទៅលើចំណេះដឹង ព្រោះសហគមន៍អាចមានការយល់ដឹងខុសគ្នា។ វាជាភារកិច្ចរបស់អ្នកផ្សព្វផ្សាយអនាម័យក្នុងការពិភាក្សាជាមួយសហគមន៍ និងវិភាគពីរបៀបដែលពួកគាត់គិតរួមជាមួយនឹងអ្វីដែលពួកគេដឹង។

អ្នកផ្សព្វផ្សាយអនាម័យគួរតែព្យាយាមកាត់បន្ថយឧបសគ្គ និងបង្កើនកត្តាជម្រុញលើកទឹកចិត្ត។

| |
|---|
| **Q: <u>វិភាគឧបគ្គ</u> និងកត្តាជម្រុញលើកទឹកចិត្តក្នុងពេលមានគ្រោះមហន្តរាយត្រូវការពេលវេលា ហើយនេះប្រហែលជាមិនមែនជាចំនុចអាទិភាពសម្រាប់អ្នកគ្រប់គ្រង វិស្វករ និងអ្នកដឹកនាំក្រុមទេ។ តើអ្នកផ្សព្វផ្សាយអនាម័យអាចបញ្ចុះបញ្ចូលអ្នកដទៃថា ការវិភាគ ឧបសគ្គ និងកត្តាជម្រុញចិត្តមានសារៈសំខាន់យ៉ាងដូចម្តេច?** |
| ការវិភាគឧបសគ្គ និងការលើកទឹកចិត្តសម្រាប់ការលើកកម្ពស់អនាម័យគួរត្រូវបានអនុវត្តតាមផ្នែកមួយនៃការវាយតម្លៃទូទៅហើយមិនមែនជាផ្នែកសកម្មភាពដាច់ដោយឡែកនោះទេ។ តាមរយៈការចំណាយធនធានដូចគ្នាអ្នកផ្សព្វផ្សាយអនាម័យគួរតែទាញការសន្និដ្ឋានជាមូលដ្ឋានមួយចំនួនពីការវាយតម្លៃ និងវិនិច្ឆ័យថាតើកត្តាណាមួយដែលទំនងជាមានតម្លៃច្រើនជាងកត្តាដទៃទៀតក្នុងការលើកកម្ពស់ឥរិយាបថអនាម័យប្រកបដោយសុវត្ថិភាព។ អ្នកផ្សព្វផ្សាយអនាម័យគួរតែត្រូវបានលើកទឹកចិត្តពីមិត្តរួមការងារនិងអ្នកដឹកនាំក្រុមឱ្យចំណាយពេលវេលា |

សម្រាប់ការវាយតម្លៃនិងរៀបចំផែនការដោយផ្តោតលើគោលគំនិត ដូចជាកត្តាជម្រុញលើកទឹកចិត្ត និងការវិភាគរកឧបសគ្គ។

## ជំហានទី៤ : ការបង្កើតគោលបំណងឥរិយាបថអនាម័យ



ជំហានបន្ទាប់នៅក្នុងដំណើរការ កំណត់គោលបំណង។ បន្ទាប់ពីកំណត់អត្តសញ្ញាណហានិភ័យ និងបញ្ហាសំខាន់ៗ (ជំហានទី ១) កំណត់ក្រុមអាទិភាពនានាពីចំនួនប្រជាជនគោលដៅរួចហើយ ត្រូវស្វែងយល់ថាតើអ្នកណាមានឥទ្ធិពលលើពួកគេ និងរបៀបដែលពួកគេប្រាស្រ័យទាក់ទងគ្នា (ជំហានទី ២) អ្នកផ្សព្វផ្សាយអនាម័យចាំបាច់ត្រូវធ្វើការជាមួយសហគមន៍ វិស្វករ និងអ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀត (ឧទាហរណ៍ រដ្ឋាភិបាល ) និងត្រូវសួរសំណួរដូចខាងក្រោម:

- តើមានយន្តការដោះស្រាយដែលមានស្រាប់ទេ?
- តើសហគមន៍មានសមត្ថភាពអ្វីខ្លះ?
- តើមានអ្នកណាខ្លះកំពុងផ្តល់ជំនួយដល់សហគមន៍នេះ?
- តើមានភាពខ្វះចន្លោះកន្លែងណាខ្លះ?

គោលបំណងសម្រាប់ផែនការលើកកម្ពស់អនាម័យអាចទាក់ទងទៅនឹងអាកប្បកិរិយាអនាម័យ (ដូចជាការបង្កើនការអនុវត្តការលាងដៃនៅពេលវេលាសំខាន់ៗ) ឬកត្តាដែលអាចធ្វើទៅបាន (ឧទាហរណ៍មានកន្លែងលាងដៃ និងមានសាប៊ូ) ដូច្នេះវិស្វករចាំបាច់ត្រូវចូលរួមក្នុងដំណើរការនេះ។ ឧទាហរណ៍ គោលបំណងប្រតិបត្តិការ និងការថែទាំត្រូវតែបានរួមបញ្ចូលនៅក្នុងផែនការ (ឧទាហរណ៍ ការលើកទឹកចិត្តឱ្យមានការចូលរួមពីប្រជាជនដែលរងផលប៉ះពាល់ក្នុងការថែរក្សាបង្គន់អនាម័យ និងប្រព័ន្ធទឹក) ។

ការបង្កើតគោលបំណងឥរិយាបថអនាម័យមានន័យថា បង្កើតទិសដៅជាក់លាក់សម្រាប់សកម្មភាពលើកកម្ពស់អនាម័យដើម្បីផ្តោតលើអ្វីដែលសំខាន់បំផុតដើម្បីឱ្យមនុស្សផ្លាស់ប្តូរអាកប្បកិរិយា។ កាត់បន្ថយឧបសគ្គ និងបង្កើនការជម្រុញទឹកចិត្តដល់ក្រុមគោលដៅផ្សេងៗគ្នា (ពីការវិភាគដែលបានធ្វើក្នុងជំហានទី៤) ដោយកំណត់គោលបំណង និងសកម្មភាពនានាដើម្បីកាត់បន្ថយផ្លូវដែលនាំឱ្យគ្រោះថ្នាក់ដល់សុខភាព និងកាត់បន្ថយការចម្លងជំងឺផ្សេងៗ។

វាជាការល្អក្នុងការភ្ជាប់ការកំណត់គោលបំណងនេះ និង គោលបំណងនៅក្នុង IFRC Emergency Appeal Plan of Action (PoA) template ទៅនឹងបញ្ជីរសកម្មភាពទឹកស្អាត និងអនាម័យពេលមានគ្រោះមហន្តរាយ។ គោលបំណង និងសកម្មភាពដែលជ្រើសរើសដោយអ្នកផ្សព្វផ្សាយអនាម័យប្រហែលជាមិនដូចគ្នានោះទេ ប៉ុន្តែការជ្រើសរើសនេះ អាចផ្តល់គោលការណ៍ និងទម្រង់អនុវត្តផ្សេងៗ ដល់ក្រុមអ្នកផ្សព្វផ្សាយអនាម័យផ្សេងទៀត ដើម្បីអនុវត្តសកម្មភាពនៅតាមមូលដ្ឋាន និងឱ្យដល់អ្នកគ្រប់គ្រងនិង/ឬអ្នកត្រួតពិនិត្យរបស់ពួកគេ។ ពេលខ្លះគោលបំណងសម្រាប់ការលើកកម្ពស់អនាម័យនៅក្នុងផែនការជាតិ IFRC PoAs ឬក្របខណ្ឌឡូជីខល ERU អាចមាន

ទម្រង់ខ្លីៗ ប៉ុន្តែជំហានទី៤ អាចឱ្យអ្នកផ្សព្វផ្សាយអនាម័យប្រើប្រាស់ពេលវេលាសមស្របដើម្បីរៀបចំផែនការតាមគោលបំណងរបស់ខ្លួន និងដើម្បីកំណត់គោលបំណងរៀបចំផែនការ និងធ្វើផែនការលម្អិតថែមទៀត។

| **Q: តើអ្នកត្រូវនឹងធ្វើយ៉ាងម៉េច ប្រសិនបើអ្នកឃើញថា កម្រិតចំណេះដឹងខ្ពស់ ប៉ុន្តែនៅតែអនុវត្តអនាម័យមិនមានសុវត្ថិភាព? ឧទាហរណ៍ មនុស្សដែលដឹងថា ផ្លូវចម្លងជំងឺរាគមកពីអ្វី ប៉ុន្តែមិនបានលាងដៃនៅពេលវេលាសំខាន់ៗ** |
| --- |
| ត្រូវស្វែងរកឱ្យឃើញនូវឫសគុលបុព្វហេតុនាំឱ្យមិនលាងដៃ។ ចំណេះដឹងមិនដូចការធ្វើសកម្មភាពទេ។ វាអាចបណ្តាលមកពីកង្វះធនធាន ឧ. គ្មានសាប៊ូ។ តើមានអ្វីផ្លាស់ប្តូរតាំងពីកើតមានគ្រោះមហន្តរាយដែរឬទេ? ឬអាចមកពីបុរស និងស្ត្រីត្រូវប្រើបង្គន់រួមគ្នាពេលដែលមានគ្រោះមហន្តរាយ ដែលវប្បធម៌របស់ពួកគេមិនអនុញ្ញាតិឱ្យធ្វើបែបនេះ។ ប្រសិនបើព័ត៌មានដែលទទួលបានពីការវាយតម្លៃភ្លាមៗមិនគ្រប់គ្រាន់ ឬមិនច្បាស់លាស់ទេនោះ ព័ត៌មានបន្ថែមត្រូវតែប្រមូលដោយប្រើវិធីសាស្ត្រផ្សេងៗគ្នាជាមួយក្រុមមនុស្សផ្សេងគ្នា និងកែតម្រូវគោលដៅឥរិយាបថ អនាម័យទៅតាមនោះ។ |

## ជំហានទី៥: ការធ្វើផែនការ



ជំហានបន្ទាប់ គឺការបញ្ចប់ផែនការលើកកម្ពស់អនាម័យ ដោយដាក់បញ្ចូលធាតុទាំងអស់ដែលបានកំណត់ក្នុងជំហានមុនៗ៖ បញ្ហា សំខាន់ ៗ (ជំហានទី១) ក្រុមគោលដៅអាទិភាព (ជំហានទី២) កត្តាជម្រុញ និងឧបសគ្គ (ជំហានទី៣) និងការកំណត់គោលបំណង (ជំហានទី៤) ហើយជំហានទី៥ គឺស្តីពីការធ្វើផែនការ គឺជាការចងក្រងឯកសារជំហានមុនឱ្យបានត្រឹមត្រូវ និងបង្កើតផែនការការងារដែលរួមបញ្ចូលធាតុទាំងអស់ខាងលើ ហើយភ្ជាប់ទៅនឹងសកម្មភាពជាក់លាក់ជាមួយវិធីសាស្ត្រផ្សេងគ្នា ឧបករណ៍ និងធនធានដែលត្រូវការចាំបាច់ (ទាំងហិរញ្ញវត្ថុ និងមនុស្ស) និងផែនការត្រួតពិនិត្យតាមដាននិងវាយតម្លៃ។ ផែនការផ្សព្វផ្សាយលើកកម្ពស់អនាម័យ មិនត្រូវធ្វើដាច់ដោយឡែកពីក្រុមលើកកម្ពស់អនាម័យទេ។ ផែនការនេះកាន់តែមានប្រសិទ្ធភាពនៅពេលអ្នកផ្សព្វផ្សាយអនាម័យធ្វើការរួមគ្នាជាមួយអ្នកដទៃ មានដូចជា វិស្វករ (ដែលកំពុងធ្វើគំរូប្លង់ និងសាងសងសំណង់អនាម័យផ្សេងៗដូចជា បង្គន់ ទឹក និងកន្លែងបោកគក់) សហគមន៍ដែលរងផលប៉ះពាល់ រដ្ឋាភិបាលមូលដ្ឋាន ទីភ្នាក់ងារផ្សេងទៀត បុគ្គលិក សង្គម។ ល។ គោលបំណងអាកប្បកិរិយាអនាម័យត្រូវបានកំណត់ចេញពីបញ្ហាក្រុមគោលដៅផ្សេងគ្នា ជាមួយការលើកទឹកចិត្ត និងការវិភាគឧបសគ្គជាក់លាក់។ គោលបំណងទាំងនេះនឹងក្លាយជាមូលដ្ឋានគ្រឹះនៃការធ្វើផែនការ។ វិធីសាស្ត្រ និងយុទ្ធវិធីត្រូវតែជ្រើសរើសដើម្បីសម្រេចគោលបំណងទាំងនេះ។

ក្រុមអ្នកផ្សព្វផ្សាយលើកកម្ពស់អនាម័យផ្តោតអារម្មណ៍សំខាន់ក្នុងការបង្កើតផែនការលើកកម្ពស់អនាម័យផ្ទាល់ខ្លួនរបស់ពួកគេ ប៉ុន្តែពួកគេក៏ត្រូវចូលរួមក្នុងដំណើរការរៀបចំផែនការផ្សេងទៀតដូចជា:

a. បញ្ចប់ក្របខ័ណ្ឌឬផែនការសកម្មភាព ប្រតិបត្តិការទឹកស្អាត អនាម័យ រួមមានផែនការត្រួតពិនិត្យតាមដាន និងផែនការលើកកម្ពស់អនាម័យ
b. រៀបចំ និងធ្វើការស្ទង់មតិមូលដ្ឋាន
c. ការជ្រើសរើសក្រុមអ្នកផ្សព្វផ្សាយអនាម័យ
d. ការធ្វើគំរូ វិធីសាស្ត្រ ឧបករណ៍ និងសម្ភារៈផ្សេងៗ
e. សាកល្បង និងធ្វើតេស្តសម្ភារៈ និងវិធីសាស្ត្រ

### *a. បញ្ចប់ក្របខ័ណ្ឌឬផែនការសកម្មភាព ប្រតិបត្តិការទឹកស្អាត អនាម័យ រួមមានផែនការត្រួតពិនិត្យតាមដាន និងផែនការលើកកម្ពស់អនាម័យ*

ក្រុមទឹកស្អាត អនាម័យគួរតែរួមគ្នា " ចងក្រង" (ឧ. សម្ភារៈ សំណង់ និងចំណេះដឹង) ឬផែនការសកម្មភាពសម្រាប់កម្មវិធីទឹកស្អាត និងអនាម័យក្នុងពេលមានគ្រោះមហន្តរាយដោយភ្ជាប់បញ្ចូលទាំងសកម្មភាពលើកកម្ពស់អនាម័យ សកម្មភាពសាងសង់សំណង់សម្ភារៈអនាម័យ (ឧ. សំណង់សម្ភារៈទឹកស្អាត និងអនាម័យ) និងសម្ភារៈផ្សេងៗទៀតដែលត្រូវការសម្រាប់កម្មវិធីអនាម័យ។

ផែនការត្រួតពិនិត្យតាមដាន ត្រូវដាក់ជាផ្នែកមួយនៃដំណើរការរៀបចំផែនការ។ សូចនាករនេះបង្កើតបានជាមូលដ្ឋានគ្រឹះក្នុងការឃ្លាំមើល និងផ្តល់ជាគំនិតក្នុងការពិនិត្យមើល តើមានអ្វីខ្លះត្រូវការផ្លាស់ប្តូរ ហើយត្រូវធ្វើដោយអ្នកណា។ បញ្ជីសូចនាករទាំងអស់សូមចុច here.

សូចនាករគួរតែមានៈ ភាពជាក់លាក់ អាចវាស់វែង អាចសម្រេចបាន មានភាពជាប់ពាក់ព័ន្ធ និងអាចកំណត់ពេលវេលាបាន (SMART) ។ សូចនាករត្រូវបានផ្សារភ្ជាប់ជាមួយនឹងលទ្ធផល - មិនមែនគ្រាន់តែមានសកម្មភាពដែលបានដាក់ឱ្យអនុវត្តនោះទេ។ ការជ្រើសរើសសូចនាករ និងវិធីវាស់វែងនឹងផ្លាស់ប្តូរទៅតាមបរិបទប៉ុន្តែសូចនាករនីមួយៗគួរតែមានក្រុមគោលដៅ។ សូចនាករគួរតែផ្អែកលើស្តង់ដារស្វៃនិងបទដ្ឋានជាតិ។ ការត្រួតពិនិត្យត្រូវធ្វើឡើងដើម្បីវាស់វែងការផ្លាស់ប្តូរថាជោគជ័យ ឬបរាជ័យក្នុងការផ្លាស់ប្តូរទម្លាប់ ដូច្នេះការផ្លាស់ប្តូរសកម្មភាពអាចត្រូវបានធ្វើឡើងឱ្យបានឆាប់បំផុតប្រសិនបើចាំបាច់។ ផែនការត្រួតពិនិត្យអាចមានឧបករណ៍សាមញ្ញ ៗ ជាច្រើនដើម្បីតាមដានព័ត៌មាន និងប្រមូលព័ត៌មានបានដោយមធ្យោបាយខុសគ្នាៗ។

| ឧទាហរណ៍ផ្នែកមួយនៃក្របខ័ណ្ឌ (ពីសៀវភៅម៉ូឌែលអនាម័យកាកបាទក្រហមអង់គ្លេស): | | |
|---|---|---|
| លទ្ធផល | សូចនាករ | មធ្យោបាយនៃការផ្ទៀងផ្ទាត់ |
| បុរស ស្ត្រី និងកុមាររួមទាំងជនពិការនៅក្នុងចំនួនប្រជាជនគោល | - តំបន់ដែលមានទំហំ X ម៉ែត្រនៅទីប្រជុំជន និងប្រភពទឹកដែលគ្មានការឆ្លងមេរោគពី | - របាយការណ៍ដើរពិនិត្យ |

| | | |
|---|---|---|
| ដៅ (ចំនួន x) មានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់បង្គន់អនាម័យនិងធ្វើអនាម័យខ្លួនប្រាណល្អបំផុត និងចាត់វិធានការប្រកបដោយប្រសិទ្ធភាពដើម្បីការពារខ្លួនពីការគំរាមកំហែងសុខភាពសាធារណៈ។ | លាមកមនុស្ស នៅចុងបញ្ចប់នៃដំណាក់កាលទី ១<br>- X% នៃចំនួនប្រជាជនគោលដៅ ប្រើប្រាស់បង្គន់អនាម័យនៅចុងបញ្ចប់នៃដំណាក់កាលទី ១<br>- X% នៃបង្គន់អនាម័យស្អាតនៅគ្រប់កន្លែងដែលត្រូវត្រួតពិនិត្យ<br>- X% នៃចំនួនប្រជាជនគោលដៅលាងដៃជាមួយសាប៊ូ / អ្វីផ្សេងៗទៀត នៅចុងបញ្ចប់នៃដំណាក់កាលទី ១ | - ការពិភាក្សាជាមួយក្រុមគោលដៅ<br>- ព័ត៌មានពីអង្គការផ្សេងៗដូចជាអង្គការជនពិការ<br>- ការស្ទង់មតិ<br>- ឧបករណ៍ត្រួតពិនិត្យតាមដានសហគមន៍ |

## ៦. រៀបចំ និងធ្វើការស្ទង់មតិមូលដ្ឋាន

នៅពេលក្រុមគោលដៅ និងផែនការកម្មវិធីត្រូវបានយល់ព្រមក្នុងការស្ទង់មតិមូលដ្ឋានចាំបាច់ត្រូវធ្វើការស្វែងរកស្ថានភាពបច្ចុប្បន្ន និងអាចយកមកធ្វើការវាស់វែងផលប៉ះពាល់នៅក្នុងកម្មវិធីបាន។ ចំណុចចាប់ផ្តើមនៃការត្រួតពិនិត្យតាមដានសកម្មភាពលើកកម្ពស់អនាម័យ។ ការស្ទង់មតិមូលដ្ឋាននឹងត្រូវបានបង្កើតឡើងដោយផ្អែកលើសូចនាករដែលបានកំណត់ក្នុងដំណាក់កាលធ្វើផែនការ។ កម្រងសំណួរស្ទង់មតិមូលដ្ឋាន និងចុងក្រោយបញ្ចប់នៃការស្ទង់មតិ នឹងបង្កើតជាមូលដ្ឋានគ្រឹះក្នុងការវាយតម្លៃតាមដានផលប៉ះពាល់នៅពេលចាប់ផ្តើមពីដំបូង។ ព័ត៌មានមូលដ្ឋានគ្រឹះគួរតែបែងចែកទៅតាម ភេទ អាយុ និងប្រភេទពិការភាព រួមទាំងជនជាតិភាគតិច ឬមនុស្សគ្រប់គ្នាពាក់ព័ន្ធ។

- ការរចនាកម្រងសំណួរសម្រាប់ការសម្ភាសន៍គ្រួសារ :កម្រងសំណួរមូលដ្ឋានត្រូវបានបង្កើតឡើងដោយផ្អែកលើសូចនាក ដោយផ្តោទៅលើចំនុចដែលអ្នកចង់ឃើញឱ្យមានការផ្លាស់ប្តូរ - សំណួរនីមួយៗគួរតែភ្ជាប់ជាមួយនឹងសូចនាករដែលចង់បាន។ ប្រើការសង្កេត (ឧទាហរណ៍កន្លែងស្តុកទឹក កន្លែងលាងដៃ ឬបង្គន់អនាម័យ) នៅកន្លែងណាដែលអ្នកអាចពិនិត្យមើលបាន និងចៀសវាងប្រើសំណួរបិទ (ដោយមានចម្លើយចាស / ទេ) ។ កម្រងសំណួរគួរតែខ្លី និងសាមញ្ញនឹងមានចំនួនប្រមាណពី ១០ ទៅ ១៥សំណួរប៉ុណ្ណោះ។ ត្រូវប្រាកដថាកម្រងសំណួរបានបកប្រែ និងពិនិត្យថាពិតជាត្រឹមត្រូវ។ បើសិនជាមានជាកម្មវិធីក្នុងទូរសព្ទ័អាចធ្វើសំណួរទៅតាមបរិបទរឹតតែល្អបំផុត។
- **ការប្រមូលសំណាក:** សំណាកចៃដន្យ គឺជាវិធីសាស្រ្តល្អបំផុតយកមកប្រើ ដូច្នេះរាល់ប្រធានបទទាំងអស់នៅក្នុងក្របខណ្ឌមានប្រូបាប៊ីលីតេត្រូវបានជ្រើសរើស។ ទំហំប្រជាជន និងសំណាកចៃដន្យប្រហែល ១៥០ គ្រួសារគួរតែគ្រប់គ្រាន់ ប្រសិនបើសំណាកចៃដន្យមិនត្រូវជ្រើសរើស។ វិធីសាស្រ្តសាមញ្ញបំផុតក្នុងការប្រមូលសំណាកត្រូវប្រើចាប់យកតាមកន្លែងដោយចាប់ផ្តើមពីចំនុចសំណាកចៃដន្យទៅមុន។

សម្រាប់ព័ត៌មានបន្ថែម និងការណែនាំអំពីការប្រមូលសំណាកចូលទៅកាន់ the IFRC ERU-MSM sampling document.

- **ការអនុវត្តការស្ទង់មតិ:** ធ្វើការជាមួយសហគមន៍ដើម្បីឱ្យកាត់ទទួលបានព័ត៌មាន និងទទួលបានការយល់ព្រមដោយមានការអនុញ្ញាតពីអាជ្ញាធរ និងក្រុមអាជ្ញាធប្រសិនបើពាក់ព័ន្ធ ធានាថាប្រព័ន្ធការរៀបចំការងារផ្សេងៗ បានរៀបចំ និងមានសុវត្ថិភាព។ ធានាថាអ្នកមិនធ្វើឱ្យអ្នកស្ម័គ្រចិត្ត ឬប្រជាជនគោលដៅប្រឈមនឹងហានិភ័យតាមរយៈភាពជាប់ពាក់ព័ន្ធនឹងការស្ទង់មតិរបស់អ្នក។កម្រងសំណួរគួរតែជាអនាមិក។ ធានាថាក្រុមអ្នកសួរ ត្រូវបានបណ្តុះបណ្តាលទាំងការប្រមូលទិន្នន័យបរិមាណ និងគុណភាពហើយពួកគេក៏ចូលរួមបានល្អ និងស្វែងយល់អំពីដំណើរការនេះ។ ការសម្ភាសន៍តាមគ្រួសារសូមគិតពីមនុស្សដែលអ្នកចង់សួរនៅក្នុងគ្រួសារនិមួយៗ - មេគ្រួសារ អ្នកមើលថែ រឺស្ត្រីអាយុពី១៥ ទៅ ៤៩ឆ្នាំ? សាកល្បងការស្ទង់មតិដើម្បីធានាថាសំណួរមានភាពច្បាស់លាស់ សមស្រប និងវិធីសាស្រ្តប្រមូលសំណាកដំណើរការបានល្អ។ កត់ត្រាវិធីសាស្រ្តដែលបានប្រើរួច ដូច្នេះការស្ទង់មតិចុងក្រោយអាចយកមកប្រើម្តងទៀតនូវវិធីសាស្រ្តដដែលនោះ។ នៅពេលធ្វើការស្ទង់មតិចុងក្រោយ អាចធ្វើដូចគ្នាទៅនឹងអ្វីដែលធ្វើពេលចាប់ផ្តើមដោយប្រើសំណួរ វិធីសាស្រ្ត ដូចគ្នា ដូច្នេះកំហុសឆ្គងក៏អាចកើតមានដដែលៗ។ ចងក្រងឯកសារលទ្ធផល និងមតិយោបល់ត្រឡប់ទៅកាន់ក្រុមការងារ និងអ្នកប្រើប្រាស់សម្ភារៈទឹកស្អាត និងអនាម័យ (ឧទាហរណ៍ ក្រុមអ្នកប្រើប្រាស់ទឹកស្អាត អាជ្ញាធរ និងអង្គការផ្សេងៗ) និងប្រជាជនដែលរងផលប៉ះពាល់។

### *c. ការជ្រើសរើសក្រុមអ្នកផ្សព្វផ្សាយអនាម័យ*

ការកំណត់បុគ្គលិក និងអ្នកស្ម័គ្រចិត្តលើកកម្ពស់អនាម័យដែលសមស្រប មានសារៈសំខាន់សម្រាប់កម្មវិធីលើកកម្ពស់អនាម័យប្រកបដោយប្រសិទ្ធភាព។ ប្រព័ន្ធដែលមានស្រាប់របស់អ្នកស្ម័គ្រចិត្តរបស់សង្គមមានចំនួនគ្រប់គ្រាន់ ប៉ុន្តែបើសិនជាមានការឆ្លើយតបទៅនឹងគ្រោះមហន្តរាយក្រុមការងារត្រូវការបន្ថែមមនុស្សទៀតអាស្រ័យលើបរិបទ។

រចនាសម្ព័នរបស់ក្រុមផ្សព្វផ្សាយអនាម័យ អាស្រ័យទៅលើបរិបទ ដូចជា ទំហំនៃគ្រោះមហន្តរាយ ចំណេះដឹង តម្រូវការ ហានិភ័យ និងវត្តមានរបស់ក្រុម ERU ។ ធានាឱ្យមានតុល្យភាពយេនឌ័រនៅក្នុងក្រុម និងពិការភាព និងអ្វីផ្សេងៗទៀតដែលតែមានប្រសិទ្ធភាពក្នុងការប្រាស្រ័យទាក់ទងជាមួយក្រុមគោលដៅចម្រុះ។ ក្រុមគំរូនោះគឺ:

- **អ្នកសម្របសម្រួលលើកកម្ពស់អនាម័យ**(នេះអាចជាប្រតិភូ ERU ឬនរណាម្នាក់មកពីក្នុងសង្គម)
- **អ្នកផ្សព្វផ្សាយអនាម័យ** - អ្នកគ្រប់គ្រងក្រុម
- **អ្នកប្រមូលផ្តុំសហគមន៍ឬអ្នកធ្វើការផ្សព្វផ្សាយ** ដល់សហគមន៍ដែលរងផលប៉ះពាល់ ដែលធ្វើការជាមួយអ្នកស្ម័គ្រចិត្តកម្រិតសហគមន៍
- **អ្នកស្ម័គ្រចិត្តកម្រិតសហគមន៍** - ធ្វើការជាមួយគណៈកម្មាធិការសហគមន៍ដូចជាគណៈកម្មាធិការទឹកស្អាត និងអនាម័យ

ចំនួនបុគ្គលិក និងអ្នកស្ម័គ្រចិត្តនៅកម្រិតនិមួយៗពឹងផ្អែកលើបរិបទ ឧទាហរណ៍ ប្រសិនបើមានចំនួនប្រជាជនដែលមានហានិភ័យច្រើន អ្នកស្ម័គ្រចិត្តនៅថ្នាក់សហគមន៍ត្រូវការច្រើន។ ប៉ុន្តែការរៀបចំផែនការ និងការត្រួតពិនិត្យតាមដានត្រូវបានគេណែនាំឱ្យមានសមាជិកក្រុមពី៧ ទៅ ១០នាក់។ អាជ្ញាធរខ្លះមានគោលនយោបាយគ្រប់គ្រងអ្នកស្ម័គ្រចិត្ត ហើយគោលនយោបាយទាំងនោះអាចមានផ្នែកពិសេសមួយសម្រាប់ឆ្លើយតបនឹងគ្រោះមហន្តរាយ ប៉ុន្តែជាទូទៅអាជ្ញាធរកំណត់ប្រាក់សម្រាប់ចេញបេសកម្មជាចំនួនថ្ងៃក្នុងមួយសប្តាហ៍ក្រុមគាត់នឹងធ្វើការងារជ្រើសរើសអ្នកស្ម័គ្រចិត្ត ជ្រើសរើសសមាជិកក្រុម បង្ហាត់បង្រៀន និងជម្រុញលើកទឹកចិត្តក្រុមនោះ។

បញ្ហាប្រាក់ឈ្នួល និងការលើកទឹកចិត្តសម្រាប់បុគ្គលិក និងអ្នកស្ម័គ្រចិត្តត្រូវតែព្រមព្រៀងគ្នាមុនពេលជ្រើសរើសសមាជិកក្រុម ហើយមានការសម្របសម្រួលជាមួយនឹង IFRC និងក្រុមកាកបាទក្រហមអឌ្ឍចន្ទក្រហមផ្សេងទៀតដែលកំពុងប្រតិបត្តិការនៅក្នុងតំបន់តែមួយ។ អាជ្ញាធរមូលដ្ឋាន ត្រូវបានដឹកនាំដោយនៅតាមតំបន់ និងអ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀត និងដោយមានការសម្របសម្រួលពីអង្គការដទៃទៀតដែលធ្វើការនៅតំបន់នោះ។ គោលនយោបាយគ្រប់គ្រងអ្នកស្ម័គ្រចិត្ត មានសារៈសំខាន់ក្នុងការកំណត់ប្រាក់ឧបត្ថមសម្រាប់ការរៀបចំក្របខ័ណ្ឌកម្មវិធីលើកកម្ពស់អនាម័យពេលចាប់ផ្តើមពីដំបូង។

គួរតែមានការពិពណ៌នាពីការងារឱ្យបានច្បាស់លាស់មុនពេលប្រកាសជ្រើសរើសបុគ្គលិក និងអ្នកស្ម័គ្រចិត្តដោយមានការព្រមព្រៀងជាមួយអ្នកពាក់ព័ន្ធទាំងអស់។ ការពិពណ៌នាការងារគួរតែរាប់បញ្ចូលបញ្ជីជំនាញ និងសមត្ថភាពសំខាន់ៗហើយអាចត្រូវការការបកប្រែប្រសិនបើធ្វើការក្នុងបរិបទដែលភាសាផ្សេងៗគ្នា ឧទាហរណ៍ ជនភៀសខ្លួនមកពីប្រទេសផ្សេង។

ក្នុងការឆ្លើយតបពេលមានគ្រោះមហន្តរាយអាចមានការពិបាកក្នុងការទទួលបានបុគ្គលិក និងអ្នកស្ម័គ្រចិត្តដែលមានសមត្ថភាពពីសាខាស្ថាប័នជាតិ នៅពេលជ្រើសរើសបុគ្គលិក និងអ្នកស្ម័គ្រចិត្ត ឱ្យក្រុមលើកកម្ពស់អនាម័យ។ គោលការណ៍ណែនាំទូទៅរបស់ IFRC ស្តីពីការស្ម័គ្រចិត្ត និងការចូលរួមរបស់យុវជនអាចត្រូវបានរកបានតាមរយៈចុចនៅត្រង់ here.

## ៨. ការធ្វើគំរូ វិធីសាស្រ្ត ឧបករណ៍ និងសម្ភារៈផ្សេងៗ

| ការជ្រើសរើស របៀបធ្វើ និងវិធីសាស្រ្ត |
|---|
| ការជ្រើសរើសរបៀប និងវិធីសាស្តដែលសមស្របមានសារៈសំខាន់បំផុតសម្រាប់ការលើកកម្ពស់អនាម័យធានាថាក្រុមដែលបានរើសមកសាកសមបំផុតសម្រាប់ក្រុមគោលដៅ បរិបទ និងសំណង់ទឹកស្អាត អនាម័យ។ ការវិភាគឧបសគ្គ និងកត្តាជម្រុញទឹកចិត្តនៅក្នុងជំហានទី៣ ចាំបាច់ត្រូវប្រាប់ពីការជ្រើសរើសរបៀបផ្សព្វផ្សាយ ឬវិធីសាស្រ្តក្នុងការផ្សព្វផ្សាយ ការធ្វើសារដើម្បីផ្សព្វផ្សាយ និងផលិតសម្ភារៈសម្រាប់ផ្សព្វផ្សាយ។<br><br>វិធីសាស្រ្តផ្តោតសំខាន់លើ 'ការធ្វើជម្រុញឱ្យសហគមន៍ និងជួយពួកគាត់ឱ្យយល់ស្របលើសកម្មភាពដែលសហគមន៍ត្រូវធ្វើនិងជួយសម្របសម្រួលឱ្យមានការអនុវត្តសកម្មភាពនេះជាជាងគ្រាន់តែបកប្រែថា" យើងកំពុងធ្វើការផ្សព្វផ្សាយអនាម័យ " ហើយបកប្រែឃ្លានេះទៅក្រុមអ្នកផ្សព្វផ្សាយអនាម័យហើយទៅប្រាប់ |

សហគមន៍នូវអ្វីដែលត្រូវធ្វើ ឬអប់រំអ្នកដទៃតាមរយៈសារផ្សព្វផ្សាយ ហើយក៏ធ្វើដូចជា ពួកគេបានប្រសើរហើយនូវស្ថានភាពអនាម័យ វិធីសាស្ត្រនេះកម្រមានប្រសិទ្ធិភាពណាស់។
ពេលពិគ្រោះយោបល់ជាមួយស្ត្រី និងក្រុមងាយរងគ្រោះត្រូវធ្វើដាច់ដោយឡែកពីគ្នា(ជនពិការ និងអ្នកប្តូរភេទ។ល។) ពីព្រោះពួកគេអាចមិនចង់ឆ្លើយ ឬចូលរួមក្នុងក្រុមធំទេ។ ធានាថា ឱ្យមានអ្នកបកប្រែភាសាសញ្ញាដែលមានគុណភាពល្អសម្រាប់ទំនាក់ទំនងជាមួយមនុស្សថ្លង់និងពិការភ្នែក។

## ចំណុចសំខាន់ៗសម្រាប់វិធីសាស្ត្រធ្វើផែនការដើម្បីលើកកម្ពស់អនាម័យ

- ធានាថាវិធីសាស្ត្រសម្រាប់ការផ្សព្វផ្សាយអនាម័យ**ឆ្លើយតបទៅនឹងគោលបំណងនៃអាកប្បកិរិយាអនាម័យ** (ក្នុង**ជំហានទី៤**) **គោលបំណង**ទូទៅ និងបរិបទដោយផ្អែកលើហានិភ័យដែលបានកំណត់នៅក្នុងការវាយតម្លៃ
- ធានាថាវិធីសាស្ត្រយកមកវិភាគ **ឧបសគ្គ និងកត្តាជម្រុញសមស្របទៅនឹងបរិបទ** (**ជំហានទី៣**) ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃ (ជំហានទី១) ក្នុងគោលបំណងលើកទឹកចិត្តឱ្យមានឥរិយាបថល្អ។
- **ប្រើវិធីសាស្ត្ររួមបញ្ចូលគ្នា** ជាមួយឧបករណ៍ទំនាក់ទំនងប្រភេទផ្សេងៗគ្នា ក្នុងគោលបំណងផ្សេងៗគ្នា (បង្កើនការយល់ដឹង ចែករំលែកចំណេះដឹង មានឥទ្ធិពល និងបំផុសគំនិតអ្នកដទៃ ធ្វើការសម្រេចចិត្ត ។ ល។ ) ។
- **ផ្តោតលើក្រុមគោលដៅដែលបានកំណត់ក្នុងជំហានទី២**:
  - នៅពេលបង្កើត វិធីសាស្ត្រ ឧបករណ៍ និងសម្ភារៈសម្រាប់ផ្សព្វផ្សាយ ត្រូវគិតដល់ក្រុមគោលដៅ និងឱ្យសហគមន៍ចូលរួមក្នុងការជ្រើសរើសវិធីសាស្ត្រ និងឧបករណ៍ដែលសមស្របបំផុតសម្រាប់ស្ថានភាពរបស់ពួកគេ។
  - គិតពីហានិភ័យសុខភាពសាធារណៈ និងជ្រើសរើសវិធីសាស្ត្រសមស្របសម្រាប់ក្រុមគោលដៅផ្សេងៗគ្នា។ ឧទាហរណ៍ កុមារអាយុក្រោម៥ឆ្នាំ ដែលងាយកើតជំងឺរាគ ដែលតម្រូវឱ្យម្តាយ និងអ្នកថែទាំយកចិត្តទុកដាក់លើការលាងដៃឱ្យបានត្រឹមត្រូវនៅពេលវេលាសំខាន់ៗ (ឧទាហរណ៍បន្ទាប់ពីប្រើបង្គន់ មុនពេលបំបៅកូន) ប៉ុន្តែក៏តម្រូវឱ្យកុមារចូលរួមសកម្មភាពផងដែរ (ដូចជាហ្គេម ការសម្តែងអាយ៉ងល្ខោន។ល។ ) ដើម្បីផ្សព្វផ្សាយសកម្មភាព ដូចជាការលាងដៃ។ ហ្គេមដូចជា" ក្តារពស់ និងជណ្តើរ" ក្តារល្បែងឡើងចុះ ពេញនិយមណាស់ជាមួយកុមារ ("ចុះជណ្តើរ" ចំពោះបញ្ហាដូចជាការបន្ទោរបង់ពាសវាលពាសកាលឬ"ឡើងជណ្តើរ" សម្រាប់ឥរិយាបថល្អ ឧទាហរណ៍ ដឹងពីពេលវេលាសំខាន់ៗដើម្បីលាងដៃ) ។ មនុស្សធ្វើតាមអ្វីដែលពួកគេចូលចិត្ត ឬអ្វីដែលពួកគេមាន ជាងអ្វីដែលគេគ្រាន់តែបានលឺ។
- **ផ្តោតលើវិធីសាស្ត្រចូលរួម**:
  - មិនមែនគ្រប់វិធីការផ្សព្វផ្សាយអនាម័យទាំងអស់ ត្រូវបានយកទៅប្រើរហូតនោះទេ "សារសម្រាប់ផ្សព្វផ្សាយអនាម័យ" នោះទេ។ បច្ចេកទេសបែបចូលរួម ឧទាហរណ៍: ការតម្រៀបកាតជាបីក្រុម គឺផ្តោ

តលើការជជែកវែកញែកជាជាងការបង្កើតជាសារអប់រំផ្សព្វផ្សាយ។ គោលបំណង ដើម្បីកំណត់បញ្ហា និងយល់ព្រមលើដំណោះស្រាយសំខាន់ៗដែលទាមទារឱ្យសកម្មភាពសហគមន៍អាចដំណើរការទៅបាន។

- **ជ្រើសរើសមធ្យោបាយទំនាក់ទំនងសមស្រប:**
  - តាមរយៈមធ្យោបាយទំនាក់ទំនងដែលអាចទុកចិត្តបាន តើមានមនុស្សគោលដៅ (អ្នកបើកផ្លូវ / អ្នកមានឥទ្ធិពល) ឬមធ្យោបាយទំនាក់ទំនងដែលក្រុមមនុស្សគោលដៅអាចធ្វើបាន និងមធ្យោបាយដែលក្រុមមនុស្សគោលដៅមិនទុកចិត្ត (ព័ត៌មាននេះត្រូវបានប្រមូលនៅជំហានទី២ នៅពេលយល់ពីទម្លាប់នៃការប្រាស្រ័យទាក់ទងរបស់ក្រុមមនុស្សគោលដៅ) - អាចជាព័ត៌មាន / សកម្មភាពជាក់លាក់ណាមួយដែលក្រុមមនុស្សគោលដៅធ្វើ។
  - ការគិតដល់អ្នកទទួលការផ្សព្វផ្សាយអនាម័យនៅក្នុងការរៀបចំដែលបានគ្រោងទុក ឧទាហរណ៍ៈ គ្រួសារសហគមន៍ភាគច្រើនមានវិទ្យុ ប៉ុន្តែវិទ្យុអាចត្រូវបានប្រើដោយសមាជិកក្នុងគ្រួសារមួយចំនួនប៉ុណ្ណោះ
  - ទាក់ទងនឹងក្រុមគោលដៅ ឧទាហរណ៍ កុមារនៅសាលារៀន - ប្រើអ្វីដែលសមស្របសម្រាប់ពួកគេដូចជាអាយ៉ងឬល្ខោន។
  - ភាពសមស្របទៅតាមវប្បធម៌ បរិបទខ្លះ: អាចរាំ និងច្រៀងបាន ប៉ុន្តែបរិបទខ្លះគឺមិនអាចធ្វើបែបនេះបានទេ ដោយសារអ្នកដទៃគិតថាមិនសមរម្យទេ។
  - រីករាយ / ចូលរួម: គ្រួសារសហគមន៍គួរតែរីករាយនឹងសកម្មភាព និងមានអារម្មណ៍ចង់ចូលរួមពិភាក្សាព័ត៌មាន គឺការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក - មិនគ្រាន់តែផ្សព្វផ្សាយតាមសារប៉ុណ្ណោះទេ។
- **ជ្រើសរើសទីតាំងសមស្រប:**
  - សាលារៀន ក្រុមយុវជនសំរាប់កុមារ
  - កន្លែងប្រជុំសម្រាប់សហគមន៍
  - កន្លែងដែលអាចធ្វើការពិភាក្សាជាក្រុមបាន
- **ធ្វើការជាមួយវិស្វករដើម្បីធានាថាវិធីសាស្ត្រផ្សព្វផ្សាយអនាម័យផ្សារភ្ជាប់ជាមួយផ្នែកសំណង់អនាម័យ:**
  - វិស្វករសូមធ្វើការជាមួយក្រុមសហគមន៍ដូចជាគណៈកម្មាធិការទឹកស្អាតដើម្បីពង្រឹងនិងលើកកម្ពស់ការចូលរួមរបស់សហគមន៍ (ឧទាហរណ៍ការថែរទាំសំណង់អនាម័យ) ឱ្យមានភាពជាម្ចាស់ និងមាននិរន្តរភាព។

វិធីសាស្ត្រលើកកម្ពស់អនាម័យចែកចេញជា ៦ ក្រុម។ ប្រើវិធីសាស្ត្រច្រើនប្រភេទក្នុងការទំនាក់ទំនងដូចជាតាមវិទ្យុ តាមរូបភាព តាមរយៈសរសេរ ដើម្បីធានាថាមនុស្សគ្រប់គ្នាអាចទទួលបានព័ត៌មាន បើទោះជាគាត់ជាអ្នកអក្ខរកម្ម មើលមិនឃើញ ឬស្តាប់មិនលឺក៏ដោយ។

| | |
|---|---|
| ការប្រាស្រ័យទាក់ទងគ្នាតាមរយៈប្រព័ន្ធផ្សព្វផ្សាយធំៗ (ទូរទស្សន៍ វិទ្យុ ប្រព័ន្ធផ្សព្វផ្សាយសង្គមខិត្តប័ណ្ណ។ ល។ ) | គិតថាតើអ្នកណានឹងទទួលព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយ ហើយតើក្រុមណានឹងទទួលបានពត៌មានទាំងនេះ។ បើប្រជាជនទាំងអស់គ្នាអាចប្រើប្រាស់ទូរស័ព្ទចល័តបានទាំងអស់គ្នា គឺមានភាពងាយស្រួលក្នុងការបញ្ជូនសារបានយ៉ាងឆាប់រហ័ស ឧទាហរណ៍ ការកើតឡើងនៅជំងឺអាសន្នរោគ ការផ្សព្វផ្សាយធំៗ មានប្រយោជន៍នៅដំណាក់កាលដំបូងនៃការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ប៉ុន្តែចាំបាច់ត្រូវតែផ្តោតសំខាន់ទៅការការទំនាក់ទំនង ជាមួយសហគមន៍ទៅវិញទៅមក ឧទាហរណ៍ " ការទូរស័ព្ទចូលក្នុងកម្មវិធី" ឆ្លើយសំណួរតាមកម្មវិធីវិទ្យុ។ ឧទាហរណ៍ល្អនៃការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងផ្សព្វផ្សាយធំៗពេលមានគ្រោះមហន្តរាយសូមចុចនៅត្រង់នេះ here. |
| **សកម្មភាពសហគមន៍** (ឧទាហរណ៍ ល្ខោន / ពាក់តុកត្តាក្រណាត់ធ្វើនឹងដៃ ហើយនិយាយ, ចម្រៀង, និទានរឿង, ខ្សែភាពយន្តជាដើម) ដោយផ្តោតលើការអនុវត្តអនាម័យសំខាន់ៗដូចជាការលាងដៃសកម្មភាពពិសេសសម្រាប់កុមារ ឧទាហរណ៍ការបង្ហាញអាយ៉ងតុក្កតល្បែង។ ល។ | ក្រុមមកពីសហគមន៍ត្រូវបាន បង្រៀនតាមរយៈការស្តាប់ភ្លេង និងច្រៀងចម្រៀងជាមួយគ្នា។ គំនិតពីចម្រៀង និងភ្លេងជាច្រើនអាចរកបានតាមការចុចនៅទីនេះ here. |
| **សកម្មភាពជាក្រុម** (ឧទាហរណ៍ រូបភាពដូចជាផ្ទាំងរូបភាព ក្រដាស់ផ្ទាំងធំ និងដ្យាក្រាម ហ្វេស ផ្លូវចម្លងមេរោគរាគ ផែនទីសហគមន៍ ល្បែងរៀបកាតជា ៣ក្រុម ថង់ចាប់សន្លឹកឆ្នោត ក្តារល្បែង ទាំងអស់មានទំនាក់ទំនងជាមួយការពិភាក្សា) | អ្នកផ្សព្វផ្សាយអនាម័យតាមសហគមន៍ និងអ្នកនៅក្នុងសហគមន៍ធ្វើការជាមួយក្រុមៗដែលមានច្រើនក្រុម និងទំហំខុសៗគ្នា អាស្រ័យលើសកម្មភាពនិងបរិបទ។ ភាគច្រើននៃសកម្មភាពជាក្រុម ដកស្រង់ចេញពីឧបករណ៍ការចូលរួមផ្លាស់ប្តូរអនាម័យ (PHAST) និងឧបករណ៍សហគមន៍ដឹកនាំអនាម័យ (CLTS)(សូមមើលនៅខាងក្រោមសម្រាប់ព័ត៌មានបន្ថែម) ប៉ុន្តែឧបករណ៍ទាំងអស់នេះត្រូវឱ្យសមស្របទៅនឹងបរិបទគ្រោះមហន្តរាយ។ |
| **កំណត់រកអត្តសញ្ញាណ និងធ្វើការតាមរយៈសហគមន៍ " ជើងឯក"** | គ្រួសារ / បុគ្គល ដែលមានឥទ្ធិពលនៅក្នុងសហគមន៍ និងអាកប្បកិរិយាអនាម័យវិជ្ជមាននៅក្នុងសហគមន៍ ជាសមាជិក |

| | |
|---|---|
| | សហគមន៍គំរូដល់អ្នកដទៃទៀត។ សហគមន៍ជើងឯកទាំងនេះ អាចយកធ្វើជាអ្នកចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយលើក កម្ពស់ឥរិយាបថវិជ្ជមាន |
| **ការប្រាស្រ័យទាក់ទងផ្ទាល់ខ្លួនៈ** ការទៅលេងផ្ទះ ការពិភាក្សាជាក្រុម | ធ្វើការជាមួយអ្នកស្ម័គ្រចិត្ត (ឧទាហរណ៍អ្នកស្ម័គ្រចិត្តមូលដ្ឋាន) អ្នកប្រមូលផ្ដុំសហគមន៍ អ្នកដឹកនាំសហគមន៍ អ្នកដឹកនាំសាសនា។ ល។ |
| **ការជម្រុញ** | ការជម្រុញ គឺជាកត្តាជម្រុញដល់ដំណើរការសម្រេចចិត្តដោយមិនដឹងខ្លួនដើម្បីផ្លាស់ប្ដូរឥរិយាបថ។ ឧទាហរណ៏នៃការជម្រុញ: (១) បង្កន់អនាម័យមានដាក់ដានស្នាមដើរទៅរកកន្លែងលាងដៃតាមរយៈផ្លូវក្រាលថ្មដែលត្រូវបានលាបពណ៌ភ្លឺ។ (២) គូរគំនូរលើគំនូសប្រអប់ជើងណែនាំអ្នកប្រើប្រាស់ទៅកន្លែងលាងដៃនិងដាក់ស្នាមប្រាមដៃនៅតាមកន្លែងលាងដៃ។ និង (៣) ដាក់កញ្ចក់នៅកន្លែងលាងដៃ |

**វិធីសាស្ត្របច្ចុប្បន្ន / វិធីសាស្ត្រដែលបង្កើតឡើងដោយសង្គម**

មធ្យោបាយងាយស្រួល គឺគ្រាន់តែប្រើវិធីសាស្ត្រលើកកម្ពស់ផ្សព្វផ្សាយអនាម័យ និងធ្វើការជាមួយអាជ្ញាធរសុខាភិបាលមានស្រាប់។ អត្ថប្រយោជន៍នៃការប្រើវិធីសាស្ត្រដែលមានស្រាប់នេះដោយសារថាអ្នកស្ម័គ្រចិត្ត / អាជ្ញាធរ មានចំណេះដឹងក្នុងការប្រើវិធីសាស្ត្រនេះរួចហើយ (កាត់បន្ថយតម្រូវការការបណ្ដុះបណ្ដាលដល់អ្នកស្ម័គ្រចិត្ត) ហើយពួកគេអាចប្រើប្រាស់សម្ភារៈផ្សព្វផ្សាយអនាម័យដែលមានស្រាប់ (សម្របតាមវប្បធម៌សហគមន៍) និង អាចចាប់ផ្ដើមសកម្មភាពបានឆាប់រហ័ស (ដោយត្រូវការពេលវេលាតិចដើម្បីធ្វើតេស្តមុន) ។ ប៉ុន្តែ វិធីសាស្ត្រទាំងនេះប្រើរយៈពេលយូរក្នុងដំណើរការដែលមិនសមស្របប្រើក្នុងពេលមានគ្រោះមហន្តរាយដែលកើតឡើងលឿននោះទេ។ ដូច្នេះឧបករណ៍ត្រូវការបន្សាំក្នុងការប្រើប្រាស់ជាមុន។

- CLTS: អនាម័យដឹកនាំដោយសហគមន៍ (CLTS) គឺជាវិធីសាស្ត្រប្រើដោយថ្នាក់ជាតិ ដើម្បីលុបបំបាត់ការបត់ជើងពាសវាលពាសកាលតាមរយៈការបញ្ឆេះឱ្យសហគមន៍ជនបទភ្ញាក់ផ្អើលដោយសារ 'ការខ្ពើមរអើម'។ គោលនយោបាយរបស់ប្រទេសជាច្រើននៅអាស៊ី និងអាហ្វ្រិក ក៏ប្រើប្រាស់វិធីសាស្ត្រនេះដែរ។ គោលបំណងចម្បងរបស់ CLTS គឺដើម្បីឱ្យមនុស្សភ្ញាក់ផ្អើលតែសកម្មភាពប្រហែលជាមិនសូវពាក់ព័ន្ធ ឬ អត់មានប្រយោជន៍បន្ទាប់ពីមានគ្រោះមហន្តរាយទេ។ ម្យ៉ាងវិញទៀត នៅពេលមានការអនុវត្តបានល្អមុនពេលមានគ្រោះមហន្តរាយ ការប្រើរូបភាព និងគំនិតអវិជ្ជមានត្រូវប្រើដោយប្រុងប្រយ័ត្ន ព្រោះឧបសគ្គចម្បងពាក់ព័ន្ធនឹងនឹងកង្វះខាតសេវាកម្ម។
- PHAST: វិធីសាស្ត្រផ្លាស់ប្ដូរទម្លាប់អនាម័យ (PHAST) មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវអាកប្បកិរិយាអនាម័យ ដើម្បីកាត់បន្ថយជំងឺរាគ និងលើកទឹកចិត្តដល់ការគ្រប់គ្រងសហគមន៍ឱ្យទទួលបានទឹកស្អាត

និងសេវាកម្មអនាម័យគ្រប់គ្រាន់។ គោលការណ៍វិធីសាស្ត្រនេះ គឺការចូលរួមរបស់សហគមន៍នៅក្នុងគម្រោងផ្ទាល់ ផ្តល់សិទ្ធិអំណាច និងលើកទឹកចិត្តឱ្យគាត់ចូលរួមក្នុងការសម្រេចចិត្តអំពីសេវាកម្មដែលពួកគាត់ត្រូវការ ឬចង់កែលម្អរ ឬថែរក្សាទុកដដែល។ ឧបករណ៍ PHAST ត្រូវបានប្រើប្រាស់ដើម្បីការវាយតម្លៃមុនពេលចាប់ផ្តើម និងជាសកម្មភាពក្រុមក្នុងពេលអនុវត្ត។ ផែនការសកម្មភាពសហគមន៍អាចជាឧបករណ៍មានប្រយោជន៍ ដើម្បីឱ្យសហគមន៍ធ្វើការរួមគ្នាក្នុងការកែលម្អស្ថានភាពរបស់ពួកគេ។

**ចែករំលែកព័ត៌មានជាមួយសហគមន៍ដែលរងផលប៉ះពាល់៖**កុំចែករំលែកព័ត៌មាន-ការផ្សព្វផ្សាយ!

ការចែករំលែកព័ត៌មានតាមរយៈការផ្សព្វផ្សាយខ្នាតធំ ដោយប្រើប្រាស់សារមិនសូវមានប្រសិទ្ធិភាពទេ។ ការចែករំលែកពត៌មានតាមមធ្យោបាយពីរផ្លូវ(Two-way communication) មានប្រសិទ្ធភាពខ្ពស់ ធ្វើការជាមួយសហគមន៍ ផ្តល់ឱ្យពួកគាត់មានឱកាសបានចូលរួម និងពិភាក្សា។ បញ្ចូល**សកម្មភាពរួមបញ្ចូលគ្នា (ដូចជាការគូសផែនទី)** ដាក់ទាំងព័ត៌មានជាក់ស្តែង ដើម្បីជួយសហគមន៍ដែលរងផលប៉ះពាល់ ចាត់វិធានការដោះស្រាយហានិភ័យសម្រាប់សុខភាពពួកគាត់។

**សារអនាម័យ៖**

សារអនាម័យ អាចងាយស្រួលយល់ពេលណាសម្ភារៈនោះត្រូវបានបោះពុម្ពមានជារូបភាពផ្សេងៗ (សសេរជាអក្សរ ឬគូរជារូបភាព) ។ សារអនាម័យ គឺមិនត្រឹមតែជាសម្ភារៈបោះពុម្ព រាល់សកម្មភាពផ្សព្វផ្សាយអនាម័យត្រូវបានបង្កើតឡើងឱ្យមានភាពពាក់ព័ន្ធ ហើយបើទោះឧបករណ៍ដែលមានការចូលរួមដូចជាការគូសផែនទីត្រូវបានអនុវត្តជុំវិញប្រធានបទឬសារដែរ (ប្រើបង្គន់អនាម័យកុំបន្ទោរបង់ពាសវាលពាសកាល) ។ សារអនាម័យជាទូទៅបានមកពីតម្រូវការក្នុងការប្រាស្រ័យទាក់ទងខ្លីទៅក្រុមគោលដៅ។

សម្ភារៈផ្សព្វផ្សាយអនាម័យ ជាឯកសារបោះពុម្ព និងជារូបភាពដែលយកទៅប្រើនៅក្នុងពេលមានគ្រោះមហន្តរាយចាំបាច់ត្រូវយល់ពីរបៀបបង្កើតសារច្បាស់លាស់។ សារខ្លះក្រសួងសុខាភិបាលបានធ្វើរួចហើយដូច្នេះអ្នកផ្សព្វផ្សាយអនាម័យមានកន្លែងផ្លាស់ប្តូរតិចតួចបំផុត។ ប៉ុន្តែនៅក្នុងស្ថានភាពបែបនេះ សារអាចត្រូវបានផ្លាស់ប្តូរទៅតាមបរិបទ ហើយត្រូវផ្តល់យោបល់ឱ្យអ្នកផ្សព្វផ្សាយអនាម័យបង្កើតជាសារខ្លី: ដែលអាចជួយបង្កើតជាគំនិត បង្កើតជាសារ និងបង្កើតជាសម្ភារៈសម្រាប់ចុះធ្វើការអនុវត្ត។ ការសង្ខេបសារ មានចំណុចសំខាន់ដូចខាងក្រោម:

**ការសង្ខេបសារ:**

- **សាមញ្ញ** :ប្រើពាក្យសាមញ្ញ និងប្រើពាក្យដែលប្រើជាទូទៅក្នុងភាសា / គ្រាមភាសាក្នុងស្រុកដើម្បីឱ្យមនុស្សអាចយល់បាន។ វិធីដែលអ្នកនិយាយឃ្លាអ្វីមួយអាចមានអត្ថន័យខុសគ្នាពីសារដែលបានសសេរ។ កុំដាក់ព័ត៌មានច្រើនពេកទៅក្នុងសារក្នុងពេលតែមួយ។ សារត្រូវតែសមស្របនឹងបរិបទនិងកាលៈ។
- **ការបញ្ចេញបញ្ចូល:** ត្រូវបានបង្កើតទៅតាមបរិបទ វប្បធម៌ និងបញ្ហាអនាម័យជាក់ស្តែង។ សូមប្រុងប្រយ័ត្នចំពោះសារដែលអ្នកស្តាប់ ស្តាប់ហើយមានអារម្មណ៍ថាមានការជេរប្រមាថ។ បញ្ហាអនាម័យត្រូវតែមាន

លក្ខណៈជាក់លាក់។ ព័ត៌មានចាំបាច់ត្រូវបានដាក់បន្ថែមអត្ថន័យគ្រប់ដំណាក់កាល ដើម្បីឆ្លើយតប និងធ្វើឱ្យស្របគ្នានឹងសំណង់ទឹកស្អាត និងអនាម័យ។

- **ភាពអាចធ្វើបាន៖** សារ និងសកម្មភាពចង់ឱ្យមានផ្លាស់ប្តូរដែលអ្នកចង់បញ្ជេះត្រូវធ្វើទៅតាមអ្វីដែលអាចធ្វើទៅបាន។ ឧទាហរណ៍ អ្នកមិនចាំបាច់លើកទឹកចិត្តឱ្យអ្នកស្តាប់ លាងដៃនឹងសាប៊ូ ឬទឹកគ្រប់ពេលនោះ បើមានអ្វីជំនួសសាប៊ូបានក៏អាចលាងបានដែរ។
- **ភាពត្រឹមត្រូវ និងភាពជាប់លាប់:** ផ្តល់ជូនប្រជាជននូវព័ត៌មានដូចៗគ្នា។ សហការ និងសម្របសម្រួលជាមួយអង្គការដទៃទៀត អាជ្ញាធរសុខាភិបាល។ ល។ ដើម្បីធានាថាគ្មានភាពខុសគ្នាណាមួយកើតមានឡើយ។
- **ព័ត៌មានចម្រុះ និងកត្តារជម្រុញអារម្មណ៍៖** ការភ្ជាប់ទំនាក់ទំនងទៅកត្តាជម្រុញទឹកចិត្តមានឥទ្ធិពលខ្ពស់ជាងសារដែលផ្អែកលើព័ត៌មានដែលមនុស្សបានដឹងរួចហើយ។ CLTS ជាកត្តាជម្រុញអារម្មណ៍ខ្លាំងក្នុងការធ្វើអឱ្យស្អប់ខ្ពើមអ្វីដែលអាចយកមកប្រើប្រាស់បាន។ សារគួរតែងាយយល់ ស្រួលស្តាប់ និងមានឯកជនភាព។
- **ការចូលរួម៖** សមាជិកសហគមន៍ត្រូវចូលរួមក្នុងការរៀបចំសារដើម្បីធានាថាសារទាំងនេះត្រូវបានកំណត់គោលដៅសម្រាប់សហគមន៍ដើម្បីអាចទទួលយកនិងយល់បាន បើសិនមិនសមស្រប សហគមន៍តាមដាននិងតស៊ូមតិក្នុងការកែសំរួលផងដែរ។

## *e. វិធីសាស្ត្រ និងសម្ភារៈអនុវត្តសាកល្បងនិងធ្វើតេស្តមុនពេលចាប់ផ្តើម*

វិធីសាស្ត្រដែលត្រូវបានជ្រើសរើសហើយ ហើយយល់ព្រម និងយកទៅប្រើប្រាស់ ត្រូវរៀបចំបុគ្គលិក / អ្នកស្ម័គ្រចិត្តនិងសម្ភារៈឱ្យរួចរាល់ ឧទាហរណ៍ ការថតសំលេងសំរាប់កម្មវិធីវិទ្យុ ព្រីនរូបភាពសំរាប់ហ្គេម និងរឿងល្ខោន រូបភាពសម្រាប់ដាក់ល្បែងផត់ឃី។ ល។

ការធ្វើតេស្តសាកល្បងរាល់សកម្មភាពមុនពេលចាប់ផ្តើមជាមួយក្រុមគោលដៅនិមួយៗនៅក្នុងជំហានទី២ មានសារៈសំខាន់ណាស់ដើម្បីពិនិត្យឱ្យបានច្បាស់ពីអ្វីដែលត្រូវធ្វើ។ ការធ្វើតេស្តនេះអាចធ្វើជាមួយក្រុមតូចមួយមុនពេលចាប់ផ្តើមប្រើវា។សុំឱ្យក្រុមមនុស្សគោលដៅបានចូលរួមដូចជាក្រុមដែលត្រូវគេមើលរំលងឱ្យគាត់បានចូលរួមធ្វើតេស្តមុនពេលគម្រោងចាប់ផ្តើម (ឧទាហរណ៍ កម្មវិធីវិទ្យុ បទចំរៀង សកម្មភាពក្រុម) អមដោយការពិភាក្សាជាក្រុម (និង / ឬសំភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ) ដើម្បីជួយកំណត់ចំណុចដូចខាងក្រោម:

- **គិតពីចំណុចសំខាន់ៗ :** តើសកម្មភាពងាយស្រួលចងចាំឬទេ? អ្នកត្រូវតែអាចចងចាំនិងបកស្រាយឡើងវិញនូវព័ត៌មានឬអ្វីដែលពួកគេបានយល់ពីសកម្មភាពនោះ។
- **សកម្មភាពបញ្ជេស:**តើសកម្មភាពទាំងអស់នេះ អាចជួយជម្រុញសកម្មភាពផ្សេងដែរឬទេ? សួរក្រុមថាតើពួកគេចង់ធ្វើអ្វីផ្សេង នឹងផ្លាស់ប្តូរបន្ទាប់ពីការធ្វើតេស្តមុនពេលចាប់ផ្តើមដែរឬទេ។

- **បង្ហាញភាពវិជ្ជមាន:** ពិភាក្សាជាមួយសមាជិកសហគមន៍ដើម្បីធានាថារូបភាព ពាក្យ ឬដ្យាក្រាមដែលត្រូវបានប្រើបញ្ជូនសារ និងកំណត់បំណងថាតើចង់ឱ្យសាររបស់យើងមានឥទ្ធិពលក្នុងកម្រិតប៉ុណ្ណានិងជៀសវាងធ្វើឱ្យអ្នកស្តាប់មានអារម្មណ៍ថា ជាការប្រមាថមើលងាយ ឬបំភាន់អ្នកស្តាប់។

ព័ត៌មានដែលប្រមូលបានក្នុងកំឡុងពេលធ្វើតេស្តមុនពេលចាប់ផ្តើម ត្រូវប្រើដើម្បីកែតម្រូវសកម្មភាព។ ធានាថាមានភាពបត់បែននៅគម្រោងថវិកាសម្រាប់រៀបចំសម្ភារៈបន្ថែមព្រោះការធ្វើតេស្តមុនអាចកំណត់ការផ្លាស់ប្តូរតម្រូវការ និងស្ថានភាពភ្លាមៗ។

| Q: មានវិធីសាស្ត្រជាច្រើន តើវិធីសាស្ត្រណាដែលមានប្រសិទ្ធភាពបំផុត? |
|---|
| ការជ្រើសរើសវិធីសាស្ត្រត្រូវជ្រើសឱ្យត្រូវនឹងក្រុមគោលដៅ និងតម្រូវការ។ មិនមាន" វិធីសាស្ត្រល្អបំផុត" អ្នកខ្លះនឹងដំណើរការល្អជាមួយក្រុមនិងបរិបទ វិធីសាស្ត្រខ្លះដំណើរការបានល្អជាមួយកុមារហើយវិធីផ្សេងទៀតគឺល្អសម្រាប់មនុស្សពេញវ័យ។ វិធីសាស្ត្រខ្លះគឺចាំបាច់ប្រើដើម្បីអាចប្រាស្រ័យទាក់ទងជាមួយជនពិការដូចជាសម្ភារៈងាយអាននិងងាយស្រួលសម្រាប់ជនពិការសតិបញ្ញានិងការលូតលាស់។ សូមរើសវិធីសាស្ត្រដែលល្អបំផុតដោយវិធីសាស្ត្រនោះមានអន្តរកម្មល្អជាមួយសហគមន៍។ សាកល្បងវិធីសាស្ត្រជាមុនដើម្បីមើលថាតើវាដំណើរការយ៉ាងដូចម្តេច។ |
| Q: តើខ្ញុំត្រូវអនុវត្តការធ្វើតេស្តជាមុនយ៉ាងដូចម្តេច? |
| អ្នកគួរតែជ្រើសរើសក្រុមតូចមួយពីក្រុមអ្នកដែលបានបម្រុងទុកនៅក្នុងវិធីសាស្ត្រ និងអនុវត្តដូចទៅនឹងជាមេរៀនពិតៗ។ រៀបចំជាមុននូវសំណួរណែនាំមួយចំនួនដែលត្រូវសួរទៅកាន់អ្នកទទួលផលទាក់ទងនឹងការយល់ដឹង និងបញ្ហាអ្វីដែលអាចកើតឡើងនាំឱ្យមានភាពចម្រូងចម្រាស។ សួរសំណួរដូចដែលក្រុមបានពិភាក្សាជាក្រុម ហើយកត់ត្រាចម្លើយទុក។ កុំភ្លេចតាមដាននិងបញ្ចូលក្រុមផ្សេងៗគ្នាក្នុងការធ្វើតេស្តជាមុនពីព្រោះពួកគេអាចមានការយល់ឃើញខុសគ្នា។ |
| Q. តើខ្ញុំត្រូវរង់ចាំរហូតដល់បញ្ចប់ជំហានទី ១-៥ ទើបបង្កើតសារផ្សព្វផ្សាយខ្លីរបស់ខ្ញុំឬ? |
| ដើម្បីបង្កើតសារខ្លី និងបង្កើតសម្ភារៈផ្សព្វផ្សាយបានល្អ ត្រូវបង្កើតសារឱ្យមានចំណុចសំខាន់ៗដែលមាននៅក្នុងជំហានទី១-៥ ទើបមានប្រសិទ្ធិភាពសម្រាប់ការអន្តរាគមន៍ក្នុងការផ្សព្វផ្សាយនៅសហគមន៍។ ទោះបីជាមានសម្ភារៈត្រៀមពីក្រសួងសុខាភិបាលក៏ដោយក៏ក្រុមលើកកម្ពស់អនាម័យគួរតែធានាថាពួកគេបំពេញបានតាមស្តង់ដារដែលមានក្នុងតារាង ៖ សាមញ្ញ ការបញ្ចេញបញ្ចូលភាពអាចធ្វើបាន ភាពត្រឹមត្រូវ និងភាពជាប់លាប់ ការចូលរួម សមស្របតាមលំដាប់លំដោយ ការលើកទឹកចិត្ត និងមានការចូលរួម។ |

## ជំហានទី ៦ : ការអនុវត្តន៍

ការបញ្ចប់ជំហានទី១ ដល់ទី ៥ គឺជាវិធីដើម្បីធានាថាមានផែនការសកម្មភាពលើកកម្ពស់អនាម័យប្រកបដោយប្រសិទ្ធភាព នៅក្នុងពេលមានគ្រោះមហន្តរាយ ការអនុវត្តចាំបាច់ត្រូវចាប់ផ្តើមភ្លាមៗនៅពេល



ដែលអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់យល់ព្រមលើផែនការហើយ។ នៅក្នុងបរិបទភាគច្រើនដែលកាកបាទក្រហមអឌ្ឍចន្ទក្រហមប្រតិបត្តិការមានសម្ពាធយ៉ាងខ្លាំងក្នុងការផ្តួចផ្តើមដំណាក់កាលអនុវត្តពីព្រោះសកម្មភាពបន្ទាន់មួយចំនួនត្រូវបានគេគិតថាជាការចាំបាច់នៅពេលចាប់ផ្តើមមានគ្រោះមហន្តរាយ។ អ្នកផ្សព្វផ្សាយអនាម័យអាចបញ្ចូលរាល់ធាតុសំខាន់ៗមួយចំនួនក្នុងជំហានទី១ ដល់ទី ៥ ហើយឈានទៅរកការអនុវត្ត។ ទោះយ៉ាងណាក៏ដោយ ផែនការចាំបាច់ត្រូវបានពិនិត្យឡើងអនុវត្ត និងកែសំរួលឡើងវិញ។ ការធ្វើតេស្តសម្ភារៈ និងវិធីសាស្រ្តផ្សព្វផ្សាយជាមុនអាចនាំឱ្យមានការកែសំរួលនិងសម្របខ្លួនខ្លះៗដើម្បីធានាថាវាមានភាពប្រាកដនិយម និងសមស្រប។

## *ការបណ្តុះបណ្តាលក្រុមអ្នកផ្សព្វផ្សាយអនាម័យ*

ពេលមានគ្រោះមហន្តរាយ សម្ពាធដ៏ខ្លាំងមួយគឺការឆ្លើយតបយ៉ាងរហ័សទៅនឹងស្ថានការណ៍។ បុគ្គលិក និងអ្នកស្ម័គ្រចិត្តទាំងអស់គួរតែមានការបណ្តុះបណ្តាលជាមូលដ្ឋានអំពីរបៀបធ្វើការ/ របៀបស្ម័គ្រចិត្តសម្រាប់កាកបាទក្រហមអឌ្ឍចន្ទក្រហម នេះរាប់បញ្ចូលទាំងចំណេះដឹង ការយល់ និងរបៀបអនុវត្តពីគោលការណ៍គ្រឹះរបស់កាកបាទក្រហមអឌ្ឍចន្ទក្រហម សីលធម៌ និងបទដ្ឋានមនុស្សធម៌។ ប្រសិនបើបុគ្គលិក / អ្នកស្ម័គ្រចិត្តដែលទើបនឹងជ្រើសរើសថ្មី ដើម្បីឆ្លើយតបនឹងគ្រោះមហន្តរាយត្រូវទទួលបានការបណ្តុះបណ្តាលខ្លីៗប៉ុន្តែឱ្យបានគ្រប់គ្រាន់។

កម្មវិធីបណ្តុះបណ្តាលមិនគួរមានរយៈពេលវែងពេកទេ វគ្គបណ្តុះបណ្តាលគួរមានរយៈពេលតែមួយថ្ងៃទើបល្អ ដោយផ្តោតលើចំណុចសំខាន់ៗ ហើយកសាងជំនាញដោយគ្រាន់តែបន្ថែមមេរៀនដែលចង់ដាក់បញ្ចូលនោះ (ឧទាហរណ៍៖ រៀបចំមេរៀនរយៈ២ម៉ោង / ពិនិត្យឡើងវិញក្នុងមួយសប្តាហ៍ម្តង) ។ ធ្វើការសង្ខេបឡើងវិញជាមួយអ្នកស្ម័គ្រចិត្តជាប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍ជាផ្នែកមួយនៃការបណ្តុះបណ្តាល / ត្រួតពិនិត្យ។ រៀនពីការងារ វិធីសាស្រ្ត គឺមានប្រសិទ្ធភាពណាស់ និងទទួលកោតសរសើរពីអ្នកស្ម័គ្រចិត្ត។ ការបណ្តុះបណ្តាលត្រូវបានបង្រៀនទៅតាមបរិបទ និងការអនុវត្តជាក់ស្តែងដោយផ្អែកលើចំណេះដឹងជំនាញនិងបទពិសោធន៍ដែលមានស្រាប់ហើយផ្តោតលើតម្រូវការជាក់ស្តែង។

បុគ្គលិក និងអ្នកស្ម័គ្រចិត្តទាំងអស់គួរតែដឹងពីគោលបំណងនៃការលើកកម្ពស់អនាម័យ។ សរុបមកៈ

- **អ្នកផ្សព្វផ្សាយអនាម័យ** គួរតែដឹងពីវិធីរៀបចំផែនការនិងអនុវត្តកម្មវិធីលើកកម្ពស់អនាម័យដោយមានប្រព័ន្ធត្រួតពិនិត្យ របៀបក្នុងការជ្រើសរើសវិធីសាស្រ្តសមស្របសម្រាប់ការផ្សព្វផ្សាយអនាម័យប្រកប

ដោយប្រសិទ្ធភាពជាមួយ នឹងការចូលរួមរបស់សហគមន៍រួមទាំងយន្តការគណនេយ្យភាព និងរបៀបផ្តល់ព័ត៌មានត្រលប់។

- **អ្នកផ្សព្វផ្សាយលើកកម្ពស់សហគមន៍ អ្នកស្ម័គ្រចិត្តសហគមន៍ អ្នកប្រមូលផ្តុំសហគមន៍ និងបុគ្គលិកផ្សព្វផ្សាយ**គួរតែដឹងពីវិធីវិធីសាស្រ្តអនុវត្ត ដើម្បីធានាថាសហគមន៍មានសមត្ថភាពប្រើប្រាស់ការសម្របសម្រួលផ្នែកទឹកស្អាត និងអនាម័យបានល្អបំផុត សកម្មភាពបែបនេះស្តែងឱ្យឃើញថា ដើម្បីការពារកុំឱ្យមានជំងឺរាគរូស និងជំងឺដែលទាក់ទងនឹងទឹកមិនស្អាត និងអនាម័យមិនល្អទៀត។

ដោយផ្អែកលើបរិបទ អ្នកសម្របសម្រួលការលើកកម្ពស់អនាម័យ ចាប់ផ្តើមដោយការផ្តល់ការបណ្តុះបណ្តាល / វគ្គបណ្តុះបណ្តាលរំលឹកដល់អ្នកផ្សព្វផ្សាយអនាម័យ ហើយការបណ្តុះបណ្តាលនេះនឹងធ្វើឱ្យអ្នកប្រមូលផ្តុំសហគមន៍និងក្រុមសហគមន៍មានដូចជាគណៈកម្មាធិការទឹកស្អាត។

ក្លឹបទឹកស្អាត និងអនាម័យ WASH Cluster មានបណ្តុំឯកសារបណ្តុះបណ្តាល (ជាមួយបណ្ណាល័យជំនួយ) ដែលអាចប្រើសម្រាប់ការបណ្តុះបណ្តាលក្រុមផ្សព្វផ្សាយអនាម័យដែលសម្របខ្លួនទៅនឹងបរិបទ និងតម្រូវការ។ ឯកសារបណ្តុះបណ្តាលទាំងនេះមាននៅលើអ៊ីនធឺណេតសូមចុចត្រង់នេះ WASH Cluster website.

## គ្រប់គ្រងក្រុមអ្នកផ្សព្វផ្សាយអនាម័យ

បុគ្គលិកនិងអ្នកស្ម័គ្រចិត្តទាំងអស់ត្រូវបានគ្រប់គ្រងបានល្អតាមរយៈ - ឱ្យពួកគេមានតួនាទីច្បាស់លាស់ទៅតាមការមុខនាទីដែលពួកគេទទួលខុសត្រូវ ធ្វើបែបនេះដើម្បីធានាមិនឱ្យមានបន្ទុកការងារច្រើនពេកទេដែលនាំឱ្យពួកគេអាចរងផលប៉ះពាល់ពីគ្រោះមហន្តរាយដែរ។ អាជ្ញាធរ មានគោលនយោបាយគ្រប់គ្រងអ្នកស្ម័គ្រចិត្ត ដែលជាគោលនយោបាយលើកទឹកចិត្តដល់អ្នកស្ម័គ្រចិត្ត ហើយក៏មានគោលនយោបាយជាក់លាក់សម្រាប់គ្រោះមហន្តរាយដែរ។

ក្រុមអ្នកផ្សព្វផ្សាយអនាម័យត្រូវបានគេសម្គាល់ឃើញយ៉ាងងាយស្រួលដោយគ្រាន់តែឃើញ អាវយឺត មួក ឬអាវកាក់ហើយនឹងមានឈ្មោះ ផ្លាកសញ្ញាឬក្រដាស់បិត ដើម្បីជួយឱ្យមានគណនេយ្យភាព។

មានប្រព័ន្ធគណនេយ្យភាពដែលត្រូវបានបង្កើតឡើងបន្ទាប់ពីពិភាក្សាជាមួយសហគមន៍ដែលរងផលប៉ះពាល់ និងអាជ្ញាធរជាតិដូច្នេះវាសមស្របនឹងបរិបទ។ ប្រើក្តារជូនដំណឹងដែលមានការពិពណ៌នាអំពីអ្វីដែលក្រុមការងារទឹកស្អាត និងអនាម័យកាកបាទក្រហមអឌ្ឍចន្ទក្រហមកំពុងធ្វើ បុគ្គលិក កម្មវិធី សកម្មភាពផ្សេងៗ និងកន្លែងដែលសហគមន៍អាចទៅទទួលព័ត៌មានបន្ថែម និងវិធីដែលពួកគាត់អាចផ្តល់មតិដោយអនាមិក - ដូចជាប្រអប់សំបុត្រ (បើគាត់អាចសរសេរបានគួរ មានក្រដាស និងប៊ិច។ ល។ ) លេខទូរស័ព្ទ ឬឈ្មោះជនបង្គោល។ អ្នកសម្របសម្រួលការលើកកម្ពស់អនាម័យគួរតែបង្កើតប្រព័ន្ធមួយសម្រាប់ការគ្រប់គ្រងមតិដូច្នេះរាល់សកម្មភាព និងព័ត៌មានត្រលប់ត្រូវបានផ្តល់ទៅសហគមន៍ដែលរងផលប៉ះពាល់វិញ។

## ការផ្សព្វផ្សាយលើកកម្ពស់អនាម័យជាមួយសហគមន៍

ជម្រើសនៃវិធីសាស្ត្រត្រូវបានពិភាក្សាខាងលើនៅក្នុងជំហានទី៥ : ការធ្វើផែនការ។ ហើយពួកគេគួរតែត្រូវសសេរចំណុចគ្រោងបង្ហាញនៅក្នុងផែនការលើកកម្ពស់អនាម័យ។ ចងចាំឱ្យប្រាកដថា វិធីសាស្ត្រសមស្របនឹងតម្រូវការ (ជំហានទី១) កំណត់ក្រុមគោលដៅដែលបានកំណត់ក្នុងជំហានទី២ និងបរិបទវប្បធម៌។ ពួកគេគួរតែឆ្លើយតបទៅនឹងគោលបំណងដែលបានកំណត់ក្នុងជំហានទី ៤ ហើយឆ្លុះបញ្ចាំងពីការវិភាគឧបសគ្គនិងកត្តាជម្រុញលើកទឹកចិត្តពីជំហានទី៣។

ប្រើវិធីសាស្ត្ររួមបញ្ចូលគ្នាដោយផ្តោតលើអន្តរកម្មតាមដែលអាចធ្វើទៅបានដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមពីសហគមន៍ដោយឱ្យសហមន៍រងផលប៉ះពាល់មានគំនិតធ្វើសកម្មភាពការពារជំងឺទាក់ទងទឹកកខ្វក់ខ្វះបង្គន់អនាម័យ និងកខ្វះអនាម័យផ្ទាល់ខ្លួន។

សហការជាមួយបុគ្គលតាមផ្នែក ដែលកាន់ការផ្នែកសំណង់ទឹកស្អាត ឧទាហរណ៍គ្រឿងបរិក្ខារអនាម័យ វិស្វករ ជាងឈើ ជាងសំណង់ជាដើម ពួកគេក៏ជាផ្នែកមួយនៃសកម្មភាពលើកកម្ពស់អនាម័យនៅក្នុងសហគមន៍។

## ការប្រើប្រាស់ប្រអប់ផ្សព្វផ្សាយអនាម័យ

ប្រអប់ផ្សព្វផ្សាយអនាម័យគឺជាប្រអប់មួយ (ឬសំណុំប្រអប់) ដែលមានជម្រើសមួយចំនួនដែលមានប្រយោជន៍សម្រាប់អ្នកផ្សព្វផ្សាយអនាម័យដើម្បីចាប់ផ្តើមសកម្មភាពផ្សព្វផ្សាយអនាម័យភ្លាមៗបន្ទាប់ពីមានគ្រោះមហន្តរាយ។ ប្រអប់ IFRC មានរបស់របរដែលមានប្រយោជន៍មិនងាយរកបានភ្លាមៗរួមមានសម្ភារៈការិយាល័យ ក្រដាសពណ៌ កន្ត្រៃ ថ្នាំលាប អំពូល ម៉ាស៊ីនថត មេហ្គាហ្វូន សំណុំរូបភាព (៣ ឈុតសម្រាប់តំបន់ផ្សេងៗគ្នា) និងឧបករណ៍សម្រាប់ដេរតុក្កតាអាយ៉ង។ បញ្ជីរាយនាមសម្ភារៈទាំងនេះសូមចុចទីនេះ here អាជ្ញាធរជាតិ និង MSM ERUs បានបង្កើតប្រអប់ផ្សព្វផ្សាយអនាម័យតាមបរិបទផ្ទាល់ខ្លួន។

## ជ្រើសរើសការកំណត់និងពេលវេលាសមស្រប

ការកំណត់នឹងអាស្រ័យលើចំនួនប្រជាជនគោលដៅ និងវិធីសាស្ត្រ។ នៅពេលជ្រើសរើសយកការរៀបចំសូមពិចារណាអំពីមធ្យោបាយពេលវេលា និងទីកន្លែងសូមគិតពិចារណារពីដំណើរការសមស្របបំផុតដើម្បីទៅដល់ក្រុម / សមាជិកសហគមន៍ផ្សេងគ្នាដែលពួកគេអាចចូលរួមសកម្មភាពនិងពិភាក្សាបាន។ ធ្វើការជាមួយគ្រូដើម្បីបញ្ចូលសកម្មភាពមួយចំនួនសម្រាប់កុមារនៅសាលារៀននិងក្លឹបយុវជន។ ដោយផ្អែកលើបរិបទគួរឱ្យសហគមន៍បានពិភាក្សា /ធ្វើសកម្មភាពសហគមន៍ក្នុងការប្រមូលអ្នកដែលស្ថិតនៅក្នុងក្រុមទឹក។ រួមបញ្ចូលការផ្សព្វផ្សាយអនាម័យមួយចំនួនដោយភ្ជាប់ជាមួយការចែកចាយសម្ភារៈអនាម័យ។ គិតអំពីតម្រូវការផ្សេងទៀតនៅលើពេលវេលារបស់ប្រជាជនគោលដៅហើយនៅពេលវេលាដែលអាចទទួលបាននិងអាចចូលរួមសកម្មភាពបានច្រើនបំផុត។

## កិច្ចសន្យានិងកាលវិភាគសម្រាប់ធ្វើប្រព័ន្ធផ្សព្វផ្សាយធំ

ប្រព័ន្ធផ្សព្វផ្សាយអាចត្រូវបានប្រើដើម្បីពង្រីកកម្មវិធីឱ្យបានដល់កម្រិតអតិបរមាក្នុងរយៈពេលពីរបីថ្ងៃដំបូងបន្ទាប់ពីមានគ្រោះមហន្តរាយ។ ប្រព័ន្ធផ្សព្វផ្សាយធំ នឹងអាស្រ័យលើភាពចាំបាច់ (ឧទាហរណ៍ប្រសិនបើការចូលទៅកាន់សហគមន៍មិនងាយស្រួលទេ) និងលើថវិកា កិច្ចសន្យាជាមួយស្ថានីយ៍ទូរទស្សន៍ និងវិទ្យុអាចធ្វើ

ទៅបានដោយមានជំនួយពីអាជ្ញាធរ។ ចំណាំថាមនុស្សពិបាកស្តាប់ប្រហែលជាមិនអាចទទួលបានព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយធំ ៗ ដូចជាទូរទស្សន៍ (លើកលែងតែភាសាសញ្ញាត្រូវបានប្រើ) និងវិទ្យុបានទេ។ ការសម្របសម្រួលជាមួយអ្នកអនុវត្តទឹកស្អាតដទៃទៀតដើម្បីធានាឱ្យបាននូវសារដែលមានភាពស៊ីសង្វាក់ពិតជាមានសារៈសំខាន់ណាស់។ ប៉ុន្តែ បើកម្មវិធីទូរទស្សន៍វី វិទ្យុ ផ្សាយដាច់ដោយឡែកពីអង្គការដទៃទៀតដើម្បីចៀសវាងសារផ្សេងទៀតដែលត្រូវបានសន្មតថាជាសាររបស់កាកបាទក្រហម និងអឌ្ឍចន្ទក្រហម។

### *ធ្វើការរួមគ្នាជាមួយវិស្វករ និងអ្នកដទៃទៀត*

អ្នកផ្សព្វផ្សាយអនាម័យគឺជាផ្នែកមួយនៃក្រុមអ្នកផ្សព្វផ្សាយទឹកស្អាត និងអនាម័យ ហើយក្រុមនេះគួរតែធ្វើការជាមួយគ្នា ហើយគ្មានភាពផ្ទុយគ្នាទេ។ ក្រុមគួរតែមានការប្រជុំក្រុមទៀងទាត់និងធ្វើរបាយការណ៍រួមគ្នា។

**គាំទ្រដល់ការជ្រើសរើស ការរចនា ប្រតិបត្តិការ និងការថែរទាំគ្រឿងបរិក្ខារទឹកស្អាត និងអនាម័យ - ផ្នែករឹង**

អ្នកផ្សព្វផ្សាយអនាម័យគួរតែធ្វើការរួមគ្នាជាមួយវិស្វករកាកបាទក្រហមអឌ្ឍចន្ទក្រហម និងបុគ្គលិករដ្ឋាភិបាលមូលដ្ឋានក្នុងការចូលរួមមកសាងសង់សម្ភារៈអនាម័យដើម្បីធានាថាការឆ្លើយតបសមស្របទៅនឹងតម្រូវការរបស់ប្រជាជនដែលរងផលប៉ះពាល់ ហើយអ្វីដែលពួកគេទទួលបាន គឺពួកគាត់អាចប្រើបានល្អបំផុត។ អ្នកផ្សព្វផ្សាយអនាម័យទទួលខុសត្រូវក្នុងការបកប្រែចំណង់ចំណូលចិត្តសេចក្តីប៉ងប្រាថ្នារបស់ប្រជាជនទាក់ទងនឹងការរចនា និងការដាក់សម្ភារៈប្រើប្រាស់ទឹកស្អាត និងអនាម័យដល់វិស្វករ។ ក្រុមលើកកម្ពស់អនាម័យគួរតែជួយសម្រួលដល់ការពិភាក្សាជាមួយគ្រប់ផ្នែកនៃសហគមន៍រួមមានបុរស ស្ត្រី កុមារ និងជនពិការដើម្បីធានាថា ទស្សនៈរបស់ពួកគេត្រូវបានគេចាប់អារម្មណ៍ទាក់ទងនឹងការរចនា និងការជ្រើសរើសកន្លែងប្រើប្រាស់ទឹកស្អាតអនាម័យ។ ឧទាហរន៍ តើមានកន្លែងបោកគក់សម្រាប់បោកខោអាវត្រឹមត្រូវតាមខ្នាតដែរឬទេ? តើកុមារឈដល់កន្លែងក្បាល់រ៉ូប៊ីនេដែរឬទេតើមានការរៀបចំអនាម័យសម្រាប់កុមារដែរឬទេ? គ្រប់ផ្នែកទាំងអស់នៃសហគមន៍គួរតែចូលរួមក្នុងការធ្វើតេស្តសាកល្បងរាល់សំណង់ទឹកស្អាតអនាម័យសមល្មមអាចប្រើប្រាស់បាន បើមិនល្អទេត្រូវធ្វើការជាមួយវិស្វករដើម្បីផ្លាស់ប្តូរកន្លែងដែលខ្វះខាតនោះ។ គួរមានផែនការសម្រាប់ប្រតិបត្តិការ និងថែទាំ។ ដោយផ្អែកលើបរិបទក្រុមអ្នកផ្សព្វផ្សាយលើកកម្ពស់អនាម័យជួយបង្កើតគណៈកម្មាធិការប្រើប្រាស់ទឹកស្អាតដែលអាចទទួលខុសត្រូវក្នុងការថែរក្សាសំណង់ទឹកស្អាត និងអនាម័យទាំងនោះមានដូចជា ម៉ាស៊ីនបូមទឹក រ៉ូប៊ីនេជាដើម។

ក្រុមអ្នកផ្សព្វផ្សាយលើកកម្ពស់អនាម័យធ្វើការជាមួយវិស្វករដើម្បីធានាថាមានៈ

- **ភាពអាចទទួលយកបាន** - រាល់សំណង់ទឹកស្អាត និងអនាម័យត្រូវនឹងការចង់បាន និងបទដ្ឋានក្នុងតំបន់។ ឧទាហរណ៍ ប្រភេទបង្គន់និងសម្ភារៈប្រើប្រាស់ សម្ភារៈសំរាប់សំអាតគូថ។
- **ភាពអាចប្រើប្រាស់បាន** - សម្រាប់គ្រប់ផ្នែកទាំងអស់នៅសហគមន៍ ទាំងនាក់ដែលមាន កុមារតូចត្រូវទទួលបានបង្គន់អនាម័យសមស្របតម្រូវជាចាំបាច់។
- **សុវត្ថិភាព** - ហានិភ័យនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រអាចកើនឡើងគួរឱ្យកត់សម្គាល់បន្ទាប់ពីមានគ្រោះមហន្តរាយ។ ពិភាក្សាជាមួយសហគមន៍សួរថាតើមានកង្វល់អ្វីទេពីសំណង់ទឹកស្អាត និងអនាម័យ

ទាំងនោះ ត្រូវពិនិត្យមើលថាមានភ្លើងបំភ្លឺគ្រប់គ្រាន់នៅជិតបង្គន់ មានចាក់សោរនៅលើទ្វារបង្គន់ដែរឬទេ។

- **បរិយាបន្ន** - តើរាល់សំណង់ទឹកស្អាត និងអនាម័យដែលបានបែងចែកទៅតាមក្រុមមនុស្សផ្សេងៗគ្នា ការរចនារបស់សំណង់ក្នុងពេលមានគ្រោះមហន្តរាយ តើមានបងប្អូនជនជាតិណាខ្លះដែលកំពុងត្រូវបានគេមើលងាយ ហើយអាចមិនមានលទ្ធភាពទទួលបានសេវាកម្មទឹកស្អាត ឬសំណង់ទឹកស្អាត អនាម័យដែរឬទេ?

## ការទទួលបានទឹកផឹកប្រកបដោយសុវត្ថិភាព

អ្នកផ្សព្វផ្សាយអនាម័យក៏អាចសហការជាមួយវិស្វករដើម្បីធានាថាប្រជាជនអាចទទួលបានទឹកស្អាត។ អាស្រ័យលើបរិបទប្រសិនបើចាំបាច់ក្រុមអ្នកផ្សព្វផ្សាយអនាម័យនឹងលើកកម្ពស់ ធ្វើការផ្សព្វផ្សាយពីវិធីបន្សុទ្ធទឹកតាមគ្រួសារទៅមសហគមន៍ និងគ្រួសារសហគមនន៍ តាមរយៈការគាំទ្រពីវិស្វកររបស់កាកបាទក្រហមអឌ្ឍចន្ទក្រហម ក្នុងការបណ្តុះបណ្តាលសហគមន៍ ពីរបៀបប្រើប្រាស់សម្ភារៈបន្សុទ្ធទឹក និងធ្វើការតាមដានដើម្បីធានាថាសហគមន៍ប្រើប្រាស់ផលិតផលបន្សុទ្ធទឹកបានត្រឹមត្រូវ និងទឹកមានសុវត្ថិភាពសម្រាប់ផឹក ហើយរក្សាទុកទឹកផឹកក្នុងធុងស្អាតយ៉ាងមានសុវត្ថិភាពនៅតាមគ្រួសារ ។

## ការទទួលបានសម្ភារៈអនាម័យសមស្របៈការចែកចាយជំនួយ

ការចែកជំនួយរបស់កាកបាទក្រហម និងអឌ្ឍចន្ទក្រហមជាធម្មតាត្រូវបានធ្វើឡើងដោយក្រុមជួយសង្គ្រោះបន្ទាន់។ អ្នកផ្សព្វផ្សាយអនាម័យមិនធ្វើការចែកចាយផលិតផលដែលទាក់ទងនឹងអនាម័យទេ (ឧបករណ៍ សម្ភារៈធ្វើអនាម័យ សាប៊ូ ធុងជាដើម) ប៉ុន្តែពួកគេអាចចូលរួមក្នុងការចែកសម្ភារៈខ្លះដែលជាផ្នែកមួយនៃការបណ្តុះបណ្តាលដូចជាសកម្មភាពធ្វើបង្ហាញ ឬសកម្មភាពផ្សព្វផ្សាយនានា។ រកភាពខ្វះចន្លោះដែលមិនអាចទទួលបានសម្ភារៈសំខាន់ៗ (សាប៊ូ ធុងទឹក សម្ភារៈអនាម័យពេលមានរដូវ) ចាំបាច់ត្រូវរាយការណ៍ទៅក្រុមផ្តល់ជំនួយដែលកំពុងធ្វើប្រតិបត្តិការដោយអាជ្ញាធរ / ឬ IFRC ។ អ្នកផ្សព្វផ្សាយអនាម័យមានតួនាទីសំខាន់ក្នុងការធានាថាសមាជិកសហគមន៍ទាំងអស់ (បុរសស្រ្តី និងកុមាររួមទាំងជនពិការ) ទទួលបានសម្ភារៈអនាម័យដែលសមស្របនឹងតម្រូវការរបស់ពួកគេ។ ពួកគេគួរតែជួយភ្ជាប់ទំនាក់ទំនងរវាងការស្តាប់សហគមន៍និងការទំនាក់ទំនងជាមួយក្រុមផ្តល់ជំនួយ។ អ្នកផ្សព្វផ្សាយក៏គួរតែជួយក្នុងការផ្លាស់ប្តូរព័ត៌មានរវាងក្រុមផ្តល់ជំនួយនិងសហគមន៍ផងដែរ។ ផ្តល់ការឆ្លើយតបពីសហគមន៍បន្ទាប់ពីការចែកចាយឧបករណ៍អនាម័យ។ អ្នកផ្សព្វផ្សាយអនាម័យគួរតែពាក់ព័ន្ធជាមួយព័ត៌មានសម្ភារៈអនាម័យ ដើម្បីធានាថាសហគមន៍ទាំងអស់យល់ដឹងអំពីសិទ្ធិរបស់ពួកគេ ហើយព័ត៌មាន និងសារស្តីអំពីអនាម័យ គឺសមរម្យ។ ប្រព័ន្ធបញ្ជរសម្រាប់ដាក់សម្ភារៈអនាម័យ (កន្លែងដែលមនុស្សអាចជ្រើសរើស និងយកសម្ភារៈអនាម័យដែលពួកគេត្រូវការ) ប្រហែលជាសមរម្យជាងការចែកចាយឧបករណ៍អនាម័យ។

## *ការទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់*

*ការអនុវត្តផែនការលើកកម្ពស់អនាម័យគិតពីការសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធសំខាន់ៗឱ្យបានល្អ៖*

- អនុក្រុមអ្នកផ្សព្វផ្សាយលើកកម្ពស់អនាម័យទឹកស្អាតអាចផ្តល់នូវការផ្សារភ្ជាប់ទៅនឹងដៃគូដទៃទៀតដែលធ្វើការនៅក្នុងវិស័យនេះហើយក៏អាចបង្កើតនូវអនុសាសន៍បច្ចេកទេសដែលចាំបាច់ត្រូវពិចារណាផងដែរ។
- សហគមន៍ដែលរងផលប៉ះពាល់មានធនធានដើម្បីគាំទ្រសកម្មភាពផ្សេងៗ។អាជ្ញាធរជាតិក៏មានធនធានសម្រាប់គាំទ្រដូចគ្នា ឧទាហរណ៍ តើពួកគេមានប្រអប់ផ្សព្វផ្សាយអនាម័យ សម្ភារៈ IEC ឬប្រអប់ឧបករណ៍ដែរឬទេ? អង្គការដែលមានអាណត្តិគាំទ្រជនពិការអាចផ្តល់ជំនាញបច្ចេកទេសលើសកម្មភាពលើកកម្ពស់អនាម័យបែបបរិយាបន្ន ដែលអាចឱ្យអ្នកគ្រប់គ្នាចូលរួមក្នុងសហគមន៍បាន។ រដ្ឋាភិបាលក៏អាចមានស្តង់ដារផ្ទាល់ខ្លួនផងដែរ (ឧទាហរណ៍គោលនយោបាយជាតិអាចបញ្ជាក់ពីវិធីសាស្រ្តជាក់លាក់ក្នុងការប្រើប្រាស់) ។

| Q: ហេតុអ្វីចាំបាច់ចែកសាប៊ូក្នុងពេលមានមហន្តរាយ? |
| --- |
| សាប៊ូគឺសំខាន់ណាស់ព្រោះសាប៊ូជួយជំរះធាតុបង្កជំងឺ និងបាក់តេរីនៅលើស្បែកដែលទឹកមិនអាចលាងជំរះបានទេ។ ព័ត៌មានបន្ថែមអំពីសាប៊ូ និងអនាម័យដៃសូមចុចទីនេះ here. |
| Q :ការគ្រប់គ្រងអនាម័យពេលមករដូវ តើអ្នកផ្សព្វផ្សាយអនាម័យមានតួនាទីយ៉ាងដូចម្តេច? |
| វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការរួមបញ្ចូលការគ្រប់គ្រងអនាម័យពេលមករដូវក្នុងសកម្មភាពអប់រំផ្សព្វផ្សាយអំពីអនាម័យ។ តួនាទីរបស់អ្នកផ្សព្វផ្សាយអនាម័យ គឺត្រូវពិភាក្សាជាមួយស្រ្តីក្នុងសហគមន៍ដើម្បីរកឱ្យឃើញនូវអ្វីដែលជាទម្លាប់ដែលមាន និងសម្ភារៈចាំបាច់សម្រាប់អនាម័យពេលមករដូវ ហើយប្រើព័ត៌មានទាំងនោះ ដើម្បីរៀបចំជាសម្ភារៈអប់រំទៅដល់គ្រួសារនោះវិញ (អាចហៅថា ជាសម្ភារៈការពារសេចក្តីថ្លៃថ្នូរពេលមករដូវ ឬជាសម្ភារៈសម្រាប់ស្រ្តី) ដោយផ្តល់មតិយោបល់ដល់ក្រុមសង្គ្រោះ។ ព័ត៌មានបន្ថែមស្តីពីការគ្រប់គ្រងអនាម័យពេលមករដូវសូមចុចត្រង់ចំនុចនេះ here. |
| Q. តើមានអ្វីកើតឡើង បើសិនជាឱ្យជាលុយជំនួសឱ្យការចែកចាយសម្ភារៈអនាម័យ - តើអ្នកផ្សព្វផ្សាយអនាម័យត្រូវពាក់ព័ន្ធដែរឬទេ? |
| កម្មវិធីផ្ទេរប្រាក់ទទួលបានការចូលចិត្តកាន់តែច្រើនហើយក្នុងមានគ្រោះមហន្តរាយ សាច់ប្រាក់ (ប័ណ្ណទូទាត់គូប៉ុង ឬមូលប្បទានប័ត្រ) អាចត្រូវបានចែកចាយជំនួសសម្ភារៈអនាម័យ។ ការងាររបស់អ្នកផ្សព្វផ្សាយអនាម័យនឹងនៅតែមានសារៈសំខាន់។ វាចាំបាច់ណាស់ក្នុងការពិគ្រោះយោបល់ជាមួយសហគមន៍ដើម្បីស្វែងយល់ពីតំរូវការ និងចំណង់ចំណូលចិត្តរបស់ពួកគេហើយប្រសិនបើប្រព័ន្ធទូទាត់ប្រាក់ / ប័ណ្ណទូទាត់នឹងមានប្រសិទ្ធិភាពសម្រាប់ពួកគេ ដើម្បីធានាថាប្រជាជនយល់ពីដំណើរការ និងតាមដានពីរបៀបដែល |

ពួកគេធ្វើការសម្រេចចិត្ត (ឧទាហរណ៍ ទិញសម្ភារៈសម្អាតសម្រាប់គ្រួសារ) ដើម្បីកាត់បន្ថយការប្រឈមនឹងហានិភ័យសុខភាពសាធារណៈក្នុងពេលមានគ្រោះមហន្តរាយ និងអនុវត្តតាមរបៀបការប្រើប្រាស់បានត្រឹមត្រូវ។

## ជំហានទី៧ : ការត្រួតពិនិត្រ និងការវាយតំលៃ



**ការត្រួតពិនិត្យ** គឺមានសារៈសំខាន់ដើម្បីបង្ហាញវឌ្ឍនភាព - ថាតើគោលបំណងកំពុងត្រូវបានសម្រេចហើយមតិយោបល់ត្រូវបានស្តាប់និងអនុវត្ត។ ក្រុមទាំងអស់ (រួមទាំងវិស្វករ) គួរតែចូលរួមហើយត្រូវតែយល់ពីដំណើរការត្រួតពិនិត្យ ដែលគួរតែជាផ្នែកមួយនៃកម្មវិធីបណ្តុះ បណ្តាលសម្រាប់អ្នកស្ម័គ្រចិត្តតាមសហគមន៍ផងដែរ។ ចូលរួមជាមួយសហគមន៍ដែលរងផលប៉ះពាល់ក្នុងការត្រួតពិនិត្យប្រមូលព័ត៌មានថែមទាំងចូលរួមក្នុងការវិភាគដើម្បីជួយធានាថាកម្មវិធីនេះសមស្របនឹងតម្រូវការរបស់ពួកគេ - ពួកគេនឹងដឹងច្បាស់នូវអ្វីដែលបានកើតឡើង ហើយហេតុអ្វីបានជាគ្រប់ផ្នែកទាំងអស់នៃសហគន៍ត្រូវចូលរួមព្រោះជួយផ្តល់អំណាចដល់ពួកគេ។ ដើម្បីឱ្យមានការគ្រប់គ្រងនិងភាពជាម្ចាស់កម្មវិធីកាន់តែច្រើនមនុស្សផ្សេងគ្នានៅក្នុងសហគមន៍នឹងមានតម្រូវការផ្សេងៗគ្នាហើយប្រហែលជាមានលទ្ធភាពប្រើប្រាស់មធ្យោបាយផ្សេងៗគ្នាដូច្នេះវាសំខាន់ណាស់ដែលមានការចូលរួមពីក្រុមមនុស្សទាំងអស់ក្នុងការឃ្លាំមើល ឧទាហរណ៍ បុរស ស្ត្រី កុមារ និងក្រុមងាយរងគ្រោះ។ ល។

សូចនាករនៅក្នុងក្របខ័ណ្ឌមូលដ្ឋាន ត្រូវបានប្រើដើម្បីធានាថាពួកគេបានផ្សាភ្ជាប់សូចនាករទឹកស្អាត និងអនាម័យផងដែរ WASH Indicators.។ ក្រុមត្រូវការតាមដានវឌ្ឍនភាព និងផលប៉ះពាល់នៃកម្មវិធីលើកកម្ពស់អនាម័យដើម្បីកំណត់និន្នាការ ឧទាហរណ៍ ការប្រើប្រាស់បង្គន់អនាម័យ និងតម្រូវការបន្សាំ សកម្មភាព និងវិធីសាស្ត្រអនុវត្តឡើងវិញ។ សំណួរសំខាន់មួយដែលត្រូវសួរគឺថា តើផ្នែកទាំងអស់នៃសហគមន៍ពេញចិត្តនឹងសម្ភារៈប្រើប្រាស់ទឹកស្អាត ហើយកំពុងប្រើប្រាស់វាដែរឬទេ។

វិធីសាស្ត្រសម្រាប់ការត្រួតពិនិត្យរួមមាន:

- ការដើរកាត់ភូមិ ការសង្កេត ការនិយាយ ជាមួយសហគមន៍ដែលរងផលប៉ះពាល់
- ពិភាក្សាក្រុម
- ការសង្កេត
- បោះឆ្នោតជាសន្លឹកតាមផក់ឃើត
- ការធ្វើផែនទី
- ប្រជុំជាមួយសហគមន៍
- ប្រជុំជាមួយក្រុម

របាយការណ៍ និងការធ្វើបច្ចុប្បន្នភាពពីព័ត៌មានបានមកពីការត្រួតពិនិត្យ ហើយត្រូវបានចងក្រង និងចែករំលែក។ ព័ត៌មានគួរតែត្រូវបានពិភាក្សា និងវិភាគ។ ឧទាហរណ៍ ការពិចារណាមិនត្រឹមតែគិតថាតើគោលដៅត្រូវបានសម្រេច ឬអត់នោះទេ ប៉ុន្តែត្រូវគិតថា តើគោលបំណងសមស្របទៅនឹងតម្រូវការដែរទេ។ ពេលវេលា និងការត្រួតពិនិត្យឱ្យបានញឹកញាប់ គឺអាស្រ័យលើបរិបទ។ ឧទាហរណ៍ ទំហំនៃគ្រោះមហន្តរាយ។
ការត្រួតពិនិត្យមិនត្រឹមតែផ្តោតលើសូចនាករបរិមាណ (ដូចជា ចំនួនបង្គន់) ប៉ុន្តែក៏គួរតែបញ្ចូលសូចនាករគុណភាពផងដែរ (ដោយមានការឆ្លើយតបពីប្រជាជនដែលរងផលប៉ះពាល់មិនថាគ្រប់ផ្នែកទាំងអស់នៃសហគមន៍កំពុងប្រើប្រាស់បង្គន់អនាម័យហើយពេញចិត្តនឹងបង្គន់ទាំងនោះដែរឬទេ) ។ ស្តាប់អ្នកស្ម័គ្រចិត្ត និងអាជ្ញាធរមូលដ្ឋាន ធ្វើកំណត់ត្រា និងតាមដានការនិយាយពីការប្រើបង្គន់ផងដែរ។ សូមចូលមើលទម្រង់ត្រួតពិនិត្យដែលត្រូវបានកែសម្រួលរួចហើយដោយចុចត្រង់ចំនុចនេះ here.

| សូចនាករ | មធ្យោបាយនៃការផ្ទៀងផ្ទាត់ | ភាពញឹកញាប់ |
|---|---|---|
| បរិស្ថានស្អាត គ្មានលាមក | ការដើរមើលកាត់ភូមិ | រាល់ថ្ងៃ រាល់២ថ្ងៃម្តង |
| អ្នកប្រើប្រាស់ទទួលខុសត្រូវចំពោះការគ្រប់គ្រង និងថែទាំសំណង់អនាម័យដោយខ្លួនឯង | ដើរសង្កេតមើលបង្គន់សហគមន៍ | រាល់ថ្ងៃ រាល់២ថ្ងៃម្តង |
| ភាគរយនៃប្រជាជនលាងដៃជាមួយសាប៊ូឬផេះក្រោយពេលប៉ះពាល់ជាមួយលាមក ឬ ភាពកខ្វក់ផ្សេងៗ | ដើរសង្កេតមើលកន្លែងលាងដៃ | រាល់ថ្ងៃ រាល់២ថ្ងៃម្តង |
| មានទឹកស្អាតសម្រាប់ផឹក | ចុះពិនិត្យនៅត្រង់កន្លែងផឹក | រាល់ថ្ងៃ រាល់២ថ្ងៃម្តង |
| ទឹកត្រូវបានស្តុកទុកដោយសុវត្ថិភាពនៅក្នុងផ្ទះ (ធុងស្អាត និងមានគ្រប) | ចុះពិនិត្យតាមគ្រួសារ | មួយសប្តាហ៍ម្តង |
| ស្ត្រី ទទួលបានការដោះស្រាយបញ្ហាអនាម័យក្នុងពេលមានរដូវជាឯកជនភាព និងភាពថ្លៃថ្នូរ | ការពិភាក្សាជាក្រុម | មួយខែម្តង |
| កន្លែងផឹកទឹក និងបង្គន់អនាម័យ អាចប្រើប្រាស់បានគ្រប់កន្លែងទាំងអស់នៅក្នុងសហគមន៍ | ចុះពិនិត្យនៅត្រង់កន្លែងផឹកទឹក និងសំណង់ទឹកស្អាត និងអនាម័យ | រាល់ថ្ងៃ រាល់២ថ្ងៃម្តង |
| | ការពិភាក្សាជាក្រុម | មួយខែម្តង |

| | | |
|---|---|---|
| អ្នកផ្សព្វផ្សាយអនាម័យត្រូវបានបណ្តុះបណ្តាលយ៉ាងមានប្រសិទ្ធភាព | យោបល់ត្រឡប់របស់បុគ្គលិកលើគុណភាព និងចូលរួមវគ្គបណ្តុះបណ្តាល | មួយសប្តាហ៍ម្តង មួយខែម្តងក្រោយពីវគ្គបណ្តុះបណ្តាល |
| មធ្យោយបាយផ្តល់យោបល់របស់សហគមន៍ ត្រូវបានយកទៅអនុវត្តនិងឆ្លើយតប | ទម្រង់កត់ត្រា, ប្រជុំក្រុម | មួយសប្តាហ៍ម្តង |
| គ្រប់ផ្នែកទាំងអស់នៃសហគមន៍ រួមទាំងក្រុមងាយរងគ្រោះ ដូចជាជនពិការ ត្រូវបានពិគ្រោះយោបល់ និងចូលរួមជាតំណាងនៅគ្រប់ដំណាក់កាលនៃគម្រោង | ការពិភាក្សាជាក្រុម | មួយខែម្តង |

ការត្រួតពិនិត្យមានសារៈប្រយោជន៍ណាស់ ដើម្បីរក្សាទុកកំណត់ហេតុ សេចក្តីសម្រេចចិត្ត ចងក្រងឯកសារ និងមូលហេតុក្នុងការសម្រេចចិត្តចំពោះកម្មវិធីក្នុងបរិបទមានគ្រោះមហន្តរាយ ព្រោះថាបុគ្គលិកអាចផ្លាស់ប្តូរចំនួន និងហេតុផលក្នុងការសម្រេចចិត្តអាចងាយនឹងភ្លេចយ៉ាងឆាប់រហ័ស។

**ការវាយតំលៃ**

គោលបំណងសំខាន់នៃការវាយតម្លៃ គឺដើម្បីធ្វើការវិនិច្ឆ័យលើតម្លៃនៃសកម្មភាព និងលទ្ធផលរបស់ពួកគេ។ តើកម្មវិធីនេះមានភាពខុសប្លែកគ្នាទេ តើវាបានជួយសង្គ្រោះជីវិត និងកាត់បន្ថយការលំបាកដែរឬទេ?

មានគោលបំណងសំខាន់ពីរដែលជាហេតុផលនៃការធ្វើការវាយតម្លៃ - ផ្តោតលើការរៀនសូត្រ (ចងក្រងឯកសារមេរៀនដែលបានរៀន) និងអ្នកដែលផ្តោតលើគណនេយ្យភាព (រាយការណ៍ទៅអ្នកជំនួយអ្វីដែលបានសម្រេច)។ មានការវាយតម្លៃជាច្រើនប្រភេទដែលអាចប្រើបានអាស្រ័យលើតម្រូវការ និងបរិបទ (ឧទាហរណ៍ ការវាយតម្លៃពេលវេលាជាក់ស្តែងក្នុងកំឡុងពេលបង្កើតកម្មវិធី) ។ ការវាយតម្លៃអាចធ្វើឡើងជាលក្ខណៈខាងក្នុងឬដោយក្រុមខាងក្រៅ អាស្រ័យលើបរិបទ និងទំហំនៃកម្មវិធី ការវាយតំលៃតែកម្មវិធីទឹកស្អាត និងអនាម័យឬ វាយតម្លៃលើកម្មវិធីទាំងអស់។

លក្ខណៈវិនិច្ឆ័យសំខាន់ៗដែលជាទូទៅត្រូវបានប្រើសម្រាប់វាយតម្លៃសកម្មភាពមនុស្សធម៌គឺ[1]:

| | |
|---|---|
| **ភាពពាក់ព័ន្ធ / ភាពសមស្រប** | - តើកម្មវិធីលើកកម្ពស់អនាម័យទាក់ទងនឹងអាទិភាពគោលនយោបាយរបស់អ្នកពាក់ព័ន្ធសំខាន់ៗ - ប្រជាជនដែលរងផលប៉ះពាល់ អាជ្ញាធរមូលដ្ឋាន ឬរដ្ឋាភិបាលដែរ |

[1] OECD, DAC criteria

| | |
|---|---|
| | ឬទេ?<br><br>- តើសកម្មភាព និងលទ្ធផលនៃកម្មវិធីលើកកម្ពស់អនាម័យមានភាពស៊ីចង្វាក់គ្នានឹងគោលដៅទូទៅនិងការសម្រេចឱ្យបានគោលបំណងដែរឬទេ? |
| **ប្រសិទ្ធភាព** | - គោលបំណងនៃកម្មវិធីលើកកម្ពស់អនាម័យត្រូវបានសម្រេចដែរឬទេ?<br>- តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលដល់ការសម្រេចគោលដៅ? |
| **ប្រសិទ្ធពល** | - ការវាស់វែងលទ្ធផលថាមាន (បរិមាណនិងគុណភាព) ទាក់ទងនឹងសមាសធាតុដែលបានដាក់បញ្ចូលដែរឬទេ<br>- សកម្មភាពលើកកម្ពស់អនាម័យត្រូវចំណាយអស់តិច-មានប្រសិទ្ធភាព?<br>- ត្រង់កន្លែងណាខ្លះដែលគោលបំណងអាចសំរេចបានទាន់ពេល?<br>- តើកម្មវិធីត្រូវបានអនុវត្តតាមរបៀបណាដែលមានប្រសិទ្ធពលបំផុត? |
| **លទ្ធដែលទទួលបាន** | - តើមានចំនុចអ្វីខ្លះដែលមានការផ្លាស់ប្តូរវិជ្ជមាន និងអវិជ្ជមានដោយសារកម្មវិធី (ដោយផ្ទាល់ឬដោយប្រយោលបំណងឬដោយអចេតនា)?<br>- អ្វីដែលបានកើតឡើងដោយសារតែកម្មវិធី?<br>- តើកម្មវិធីលើកកម្ពស់អនាម័យបានធ្វើឱ្យមានភាពខុសគ្នាយ៉ាងដូចម្តេចចំពោះអ្នកទទួលផល? |

ក្របខ័ណ្ឌសកម្មភាពនឹងបង្កើតការវាយតម្លៃពិចារណាជាមូលដ្ឋានទៅលើសកម្មភាពដែលបានដាក់បញ្ចូល (ថាតើធនធានត្រូវបានគេយកទៅប្រើឬទេ) សកម្មភាព (អ្វីខ្លះដែលត្រូវបានធ្វើហើយ) លទ្ធផល (អ្វីដែលត្រូវបានកំពុងធ្វើ) លទ្ធផល (អ្វីដែលសម្រេចបាន) និងផលប៉ះពាល់ដែលទទួលបាន (ការផ្លាស់ប្តូររយៈពេល)។

ទាំងទិន្នន័យបរិមាណនិងគុណភាពគួរតែត្រូវបានប្រមូលជាផ្នែកមួយនៃការវាយតម្លៃចុងក្រោយ។ ដូចដែលបានពិពណ៌នានៅក្នុងជំហានទី ៥ ការស្ទង់មតិមូលដ្ឋានគួរតែត្រូវបានធ្វើឡើងនៅដើមកម្មវិធី។ ដោយប្រើវិធីសាស្ត្រនិងសំណួរដូចគ្នាការស្ទង់មតិចុងក្រោយ ដែលជាផ្នែកមួយនៃការវាយតម្លៃពីការផ្លាស់ប្តូរ ប្រសិនបើការស្ទង់មតិមូលដ្ឋានមិនត្រូវបានធ្វើឡើងហើយមិនមានក្របខ័ណ្ឌត្រួតពិនិត្យត្រឹមត្រូវលទ្ធផលដែលទទួលបានមានការពិបាកណាស់ដើម្បីធ្វើការបង្ហាញ និងវាស់វែងភាពជោគជ័យ។

ការវាយតម្លៃគួរតែត្រូវបានចងក្រងជាឯកសារដោយមានរបាយការណ៍ខ្លីៗ ច្បាស់លាស់ និងត្រូវបានចែករំលែកដល់អ្នកពាក់ព័ន្ធទាំងអស់ ហើយអ្វីដែលសំខាន់បំផុតនោះ គឺត្រូវតែប្រើប្រាស់ការផ្តល់យោបល់ត្រឡប់ពីសហគមន៍និងសេចក្តីយោងនៅពេលរៀបចំផែនការអន្តរាគមន៍នាពេលអនាគត។

ការត្រួតពិនិត្យនិងវាយតម្លៃដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ហាញវឌ្ឍនភាពប៉ុន្តែក៏សម្រាប់ការរៀនសូត្រនិងការកែលម្អរផងដែរ។

| Q. តើខ្ញុំអាចចូលរួមក្នុងការត្រួតពិនិត្យជាមួយសហគមន៍យ៉ាងដូចម្តេច? |
| --- |
| យើងជួយប្រជាជនដែលរងផលប៉ះពាល់ ដូច្នេះកម្មវិធីរបស់យើងសំខាន់ត្រូវតែស្តាប់ទស្សនៈរបស់ប្រជាជនក្នុងសហគមន៍។ ការត្រួតពិនិត្យតាមដានដំណើរការរបស់កម្មវិធី និងគោលបំណងរបស់លទ្ធផលដើម្បីស្វែងយល់ថា តើកម្មវិធីនេះមានឥទ្ធិពលអ្វីខ្លះទៅលើអ្នកដែលរងផលប៉ះពាល់ដូចដែលពួកគេបានឃើញខ្លួនឯងផ្ទាល់។ សហគមន៍ដឹងច្បាស់ និងយល់ពីអ្វីដែលបានកើតឡើង ហើយក៏មានការលំបាកដែលឱ្យសហគមន៍កំណត់គោលបំណងដោយខ្លួនឯង ហើយគាត់អាចខ្វះជំនាញ ចំណេះដឹងក្នុងការត្រួតពិនិត្យវាយតំលៃលើកម្មវិធីផងដែរ។ ទោះយ៉ាងណាក៏មានការលំបាកសម្រាប់សហគមន៍ក្នុងការកំណត់គោលបំណងហើយពួកគេអាចខ្វះជំនាញនិងចំណេះដឹងដើម្បីអនុវត្តការត្រួតពិនិត្យ។ ទោះយ៉ាងណាក៏នៅមានវិធីជាច្រើនផ្នែកផ្សេងៗគ្នាដែលពាក់ព័ន្ធនឹងសហគមន៍ចូលរួមជាមួយគ្នា ដូចជាការសង្កេត ការផ្តល់មតិយោបល់ត្រឡប់លើលទ្ធផល និងការបកស្រាយនៅពេលប្រជុំសហគមន៍ ការកត់ត្រាចំនុចផ្សេងក្នុងតារាង សន្លឹកឆ្នោតជក់ឃីត ការគូសផែនទី ការធ្វើតេស្តទឹកជាដើម អ្នកស្ម័គ្រចិត្តកម្រិតសហគមន៍ដែលមកពីសហគមន៍រងផលប៉ះពាល់អាចដើរតួនាទីយ៉ាងសំខាន់ក្នុងត្រួតពិនិត្យវាយតំលៃ។ |

## ជំហានទី៨ : ពិនិត្យ និងកែតម្រូវឡើងវិញ

ដំណើរការនេះគឺមានលក្ខណៈដូចទៅនឹងរាល់វដ្តនៃគម្រោងដែរ អ្នកនឹងត្រឡប់ទៅធ្វើការសន្ទត់ និងធ្វើយុទ្ធសាស្រ្តចាប់ពីដំបូងដើម្បីបង្វែរអន្តរាគមន៍របស់អ្នកឡើងវិញដើម្បីឱ្យកាន់តែមានប្រសិទ្ធភាពនិងគ្រប់ជ្រុងជ្រោយ។ ត្រូវចងចាំថាកម្មវិធីលើកកម្ពស់អនាម័យគឺពាក់ព័ន្ធនឹងតម្រូវការ។ ក្នុងស្ថានភាពគ្រោះមហន្តរាយច្រើនតែស្មុគស្មាញដោយមានការផ្លាស់ប្តូរស្ថានភាពជាញឹកញាប់។ ការបន្តវាយតម្លៃ ការធ្វើផែនការឡើងវិញ និងការកែសម្រួលសកម្មភាពឡើងវិញគឺចាំបាច់។ មើលជុំវិញ! តើមានបញ្ហាទឹកស្អាតផ្សេងទៀតនៅក្នុងសហគមន៍ដែលរងផលប៉ះពាល់ដែលមិនបានដោះស្រាយដែរឬទេ? តើបញ្ហាបានផ្លាស់ប្តូរហើយឬនៅ? មានបញ្ហាថ្មីកើតឡើងទេ? បើដូច្នេះសូមត្រឡប់ទៅជំហានទី១ ហើយចាប់ផ្តើមម្តងទៀត Annex IFRC Guidelines to Hygiene



Promotion in Emergencies Quick Fix ផ្តល់ការណែនាំជាជំហានៗ ដល់ការលើកកម្ពស់អនាម័យក្នុងពេលមានគ្រោះមហន្តរាយដោយមានសកម្មភាពសំខាន់ៗចូលរួមនិងភ្ជាប់ព័ត៌មានបន្ថែម។

## ការធ្វើកំណត់ត្រាឯកសារនិងកាប្រគល់ឱ្យឯកសារ

ការរៀបចំឯកសារ ត្រូវឱ្យឆ្លើយតប ERUs និងសហការជាមួយអាជ្ញាធរមូលដ្ឋាន(ឧទាហរណ៍ក្នុងពេលមានគ្រោះមហន្តរាយធ្ងន់ធរធ្វើការជាមួយក្រុម RDRT និងក្រុម ERU និងសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីជួយពង្រឹងសមត្ថភាពរបស់ពួកគេតាមតម្រូវការ) ។ ការងារទាំងអស់គួរតែត្រូវបានចងក្រងជាឯកសារ និងចែករំលែកជាមួយអាជ្ញាធរមូលដ្ឋាន IFRC និង RDRTs និង ERU ផ្សេងទៀតដែលកំពុងធ្វើការឆ្លើយតបនឹងគ្រោះមហន្តរាយ។ ធ្វើបែបនេះដើម្បីជួយជៀសវាងការងារជាន់គ្នា២ដង និងងាយស្រួលក្នុងការរៀបចំផែនការការងារតាមដានជាបន្តរបន្ទាប់។

បទពិសោធន៍ដែលបានរៀនសូត្រពីគម្រោងសកម្មភាព គួរត្រូវបានចងក្រងជាឯកសារ និងចែករំលែក។ ការចងក្រងឯកសារមិនចាំបាច់ត្រូវសសេរតែជាអក្សរតែម្យ៉ាងទេ អាចជារូបភាព ឬឈុតវីដេអូខ្លី ការបង្ហាញវិធីក្នុងការធ្វើការផ្សព្វផ្សាយលើកកម្ពស់អនាម័យដែលត្រូវបានអនុវត្ត និងសកម្មភាពដែលរៀនបានពីការអនុវត្តទាំងនោះ។

## References


WASH CLUSTER. (2007). "Hygiene Promotion in Emergencies - A briefing paper" available online from: http://www.unicefinemergencies.com/downloads/eresource/docs/WASH/WASH%20Hygiene%20Promotion%20in%20Emergencies.pdf

Sphere. (2011). "*Humanitarian Charter and Minimum Standards in Humanitarian Response"* from http://www.sphereproject.org/handbook

The Core Humanitarian Standards 2016, https://corehumanitarianstandard.org/the-standard

WASH Accountability Resources 2009, Global WASH Cluster, https://ifrcwatsanmissionassistant.files.wordpress.com/2018/12/06-wash-cluster-wash-accountability-handbook.pdf

Ferron, S., Morgan, J and O'Reilly, M. (2007). *Hygiene Promotion: A Practical Manual for Relief and Development*, Practical Action Publishing.

British Red Cross (2016), *Mass Sanitation Module (MSM) Handbook*, a general reference for MSM deployments. https://ifrcwatsanmissionassistant.files.wordpress.com/2018/10/msm-detailed-tor-final-23082013.docx

Community, Engagement and Accountability (CEA), https://ifrcwatsanmissionassistant.files.wordpress.com/2018/12/cea-guide-2401-high-resolution-1.pdf

WASH CLUSTER (2013). "Training Material" available online from: http://washcluster.net/training-resources/

OEDC 2017, DAC Criteria for Evaluating Development Assistance, OEDC website, http://www.oecd.org/dac/evaluation/daccriteriaforevaluatingdevelopmentassistance.htm

Seven Fundamental Principles. http://www.ifrc.org/who-we-are/vision-and-mission/the-seven-fundamental-principles/

Code of Conduct, http://media.ifrc.org/ifrc/who-we-are/the-movement/code-of-conduct/

Gender in Water, Sanitation and Hygiene Promotion - Guidance Note, https://ifrcwatsanmissionassistant.files.wordpress.com/2018/10/guidance-note-gender-in-water-and-sanitation-en_lr1.pdf

Minimum Standard Commitments to Gender and Diversity in Emergency Programming **(**2015**)**, Gender and Diversity in Emergencies - WASH Programming Standards, page 23, https://ifrcwatsanmissionassistant.files.wordpress.com/2018/10/1-ifrc-guidelines-assessments.pdf

ICRC, IFRC (2008), Guidelines to Assessment in Emergencies, IFRC website, http://www.ifrc.org/Global/Publications/disasters/guidelines/guidelines-emergency.pdf, accessed on 7 March 2

Groce, Nora, et al. (2011). Water and sanitation issues for persons with disabilities in low- and middle-income countries: a literature review and discussion of implications for global health and international development. Journal of Water and Health, vol. 9, No. 4, pp. 617-627.

## ឧបសម្ព័ន្ធ

## ១.១ សេចក្ដីសង្ខេបនៃគោលការណ៍ណែនាំរបស់ IFRC ក្នុងការផ្សព្វផ្សាយលើកកម្ពស់អនាម័យនៅពេលមានគ្រោះមហន្តរាយ

### *តើឯកសារនេះមានអ្វីខ្លះ?*

ឯកសារនេះផ្ដល់នូវសេចក្ដីសង្ខេបអំពីវិធីអនុវត្តការលើកកម្ពស់អនាម័យក្នុងករណីមានគ្រោះមហន្តរាយនៅក្នុងបរិបទកាកបាទក្រហម និងអឌ្ឍចន្ទក្រហម។ ប្រការនេះលើកទឹកចិត្តដល់អ្នកគ្រប់គ្រងកាកបាទក្រហម និងអឌ្ឍចន្ទក្រហមដែលគម្រោងនឹងកំពុងអនុវត្តការអន្តរាគមន៍លើកកម្ពស់អនាម័យឱ្យដើរតាមមាគ៌ាច្បាស់លាស់ដោយប្រើដំណើរការជាជំហាន ៗ ដោយមិនប្រើផ្លូវកាត់ហើយក្នុងការបញ្ជូនសារអនាម័យ។ការចងក្រងផ្ដល់ជូនអាជ្ញាធរមូលដ្ឋាននូវវិធីសាស្ត្រស្ដង់ដារសម្រាប់ការធានាគុណភាពចាប់តាំងពីវាផ្ដល់នូវឱកាសសម្រាប់ការបណ្ដុះបណ្ដាលនិងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។ ជំហានទាំងនេះមានសារៈសំខាន់សម្រាប់ការទទួលខុសត្រូវ និងតួនាទីពិសេសរបស់យើងក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយដែលត្រូវបានសសេរនៅក្នុង "គោលការណ៍ណែនាំរបស់ IFRC ក្នុងការលើកកម្ពស់អនាម័យនៅពេលមានគ្រាអាសន្ន" ។

### *តើឯកសារនេះសម្រាប់អ្នកណា?*

ទស្សនិកជនគោលដៅសម្រាប់ឯកសារនេះ គឺបុគ្គលិក និងអ្នកស្ម័គ្រចិត្តកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ដែលទទួលខុសត្រូវក្នុងការរៀបចំផែនការអនុវត្ត និងតាមដានការលើកកម្ពស់អនាម័យ (រួមទាំងការបណ្ដុះបណ្ដាលអ្នកស្ម័គ្រចិត្តនៅតាមសហគមន៍) ដែលជាផ្នែកមួយនៃការឆ្លើយតបក្នុងពេលមានគ្រោះមហន្តរាយ។ ឧទាហរណ៍ សមាជិកក្រុមគ្រោះមហន្តរាយ ដូចជា ERU modules, RDRT, NDRT បុគ្គលិកកាកបាទ និងក្រហមអឌ្ឍចន្ទក្រហម និងបុគ្គលិកស្ម័គ្រចិត្តនៅក្នុងមូលដ្ឋាន និង IFRC ។

### *ហេតុអ្វីបានជាឯកសារនេះសំខាន់?*

វាមានសារៈសំខាន់ណាស់ក្នុងការបញ្ចូលកម្មវិធីលើកកម្ពស់អនាម័យប្រកបដោយប្រសិទ្ធភាពទៅជាផ្នែកមួយនៃការអន្តរាគមន៍ទឹក បង្គន់អនាម័យ និងអនាម័យផ្ទាល់ខ្លួន (WASH) ពេលឆ្លើយតបគ្រោះមហន្តរាយ។

### *និយមន័យ ដែលកាកបាទក្រហម និងអឌ្ឍចន្ទក្រហមបានឱ្យសម្រាប់ការផ្សព្វផ្សាយរបស់ អនាម័យពេលមានគ្រោះមហន្តរាយ*

ការលើកកម្ពស់អនាម័យក្នុងពេលមានគ្រោះមហន្តរាយកាកបាទក្រហម និងអឌ្ឍចន្ទក្រហមត្រូវបានកំណត់ថា ជាការគ្រោងទុក និងមានលក្ខណៈជាប្រព័ន្ធដែលផ្ដល់ដោយបុគ្គលិកនិងអ្នកស្ម័គ្រចិត្តកាកបាទក្រហមនៃអឌ្ឍចន្ទក្រហមដើម្បីឱ្យប្រជាជនមានសកម្មភាពការពារទឹកឱ្យស្អាត មានអនាម័យល្អ និងទប់ស្កាត់ជំងឺទាក់ទងកខ្វះ អនាម័តាមរយៈការកៀងគរ និងការចូលរួមរបស់ប្រជាជនដែលរងផលប៉ះពាល់តាមរយៈចំណេះដឹង និងធនធានរបស់ពួកគេដើម្បីទទួលបានការប្រើប្រាស់ និងទទួលបានផលប្រយោជន៍ច្រើនបំផុតពីទឹកនិងសំណង់អនាម័យ។

សកម្មភាពលើកកម្ពស់អនាម័យធានាថា ប្រជាជនដែលរងផលប៉ះពាល់ ដឹងពីហានិភ័យសុខភាពសាធារណៈសំខាន់ៗ ហើយត្រូវចាប់ផ្តើមអនុវត្តអនាម័យប្រកបដោយសុវត្ថិភាព និងប្រើប្រាស់នូវសំណង់ទឹកស្អាត អនាម័យ និងសេវាកម្មអនាម័យល្អបំផុត (រួមទាំងប្រតិបត្តិការ និងថែទាំ) ។ សមាសធាតុសំខាន់ៗនៃការផ្សព្វផ្សាយអនាម័យគឺៈ

- ការចូលរួមរបស់សហគមន៍
- ការប្រើប្រាស់និងថែទាំសំណង់អនាម័យ
- ការជ្រើសរើសនិងការចែកចាយរបស់របរអនាម័យ
- សកម្មភាពសហគមន៍ និងសមាជិកម្នាក់ៗ
- ការទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ
- ការត្រួតពិនិត្យ

ក្នុងកំឡុងពេលឆ្លើយតបគ្រោះមហន្តរាយកាកបាទក្រហមអឌ្ឍចន្ទក្រហមជាទូទៅបានប្រើវិធី "យុទ្ធនាការ" សម្រាប់ការលើកកម្ពស់អនាម័យដោយសង្កត់ធ្ងន់លើការផ្តល់សារ។ ទោះយ៉ាងណាការចូលរួមរបស់សហគមន៍ចាំបាច់ណាស់ដើម្បីធ្វើឱ្យការឆ្លើយតបមានប្រសិទ្ធភាពជាងមុន។ ដោយសារសម្ពាធនៃការឆ្លើយតបទៅនឹងភាពអាសន្នក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយ និងកាកបាទក្រហមអឌ្ឍចន្ទក្រហម (RDRTs ឬ ERUs) ជាដើម (បានបង្កើតសម្ភារៈ ព័ត៌មាន អប់រំដោយមិនបានធ្វើការវិភាគពីបរិបទ ការយល់ដឹងទម្លាប់នាំឱ្យកើយហានិភ័យឱ្យបានត្រឹមត្រូវ និងច្បាស់លាស់នោះទេ។ កំណត់សមត្ថភាព និងឧបសគ្គរបស់សហគមន៍ ដើម្បីអនុវត្តអនាម័យដែលមានសុវត្ថិភាព។ ការចូលរួមរបស់សហគមន៍គឺចាំបាច់ដើម្បីធានាថាសម្ភារៈទំនាក់ទំនងដែលផលិតបានតំណាងឱ្យឥរិយាបថដែលពាក់ព័ន្ធ និងការចង់បានរបស់ សហគមន៍។

.

បុគ្គលិក និងអ្នកស្ម័គ្រចិត្តកាកបាទក្រហម និងអឌ្ឍចន្ទក្រហមដែលចូលរួមក្នុងការលើកកម្ពស់អនាម័យជាផ្នែកមួយនៃការឆ្លើយតបគ្រោះមហន្តរាយចាំបាច់ត្រូវមានការយល់ដឹងកាន់តែច្បាស់អំពីឥរិយាបថ និងជំនឿដែលជះឥទ្ធិពលលើឥរិយាបទរបស់ប្រជាជនដែលរងផលប៉ះពាល់។ ប្រជាជនទម្លាប់អនុវត្តសកម្មភាពទឹកស្អាតរៀងៗខ្លួនមុនពេលមានគ្រោះមហន្តរាយ(ឧទាហរណ៍ការលាងដៃមុនពេលញ៉ាំ) ប៉ុន្តែបន្ទាប់ពីមានគ្រោះមហន្តរាយការអនុវត្តទាំងនេះអាចធ្វើទៅបានលុះត្រាតែមានសម្ភារៈផ្សេងៗ(ឧទាហរណ៍ ទឹកនិងសាប៊ូ) ។ បុគ្គលិក និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមអឌ្ឍចន្ទក្រហមត្រូវការចំណេះដឹង និងព័ត៌មានស៊ីជម្រៅអំពីកត្តានានាដែលជះឥទ្ធិពលដល់ទស្សនៈរបស់ប្រជាពលរដ្ឋ និងអ្វីដែលមនុស្សធ្វើនៅពេលពួកគេប្រឈមមុខនឹងភាពលំបាកនៃគ្រោះមហន្តរាយ (ឧទាហរណ៍ ប្រជាជនអាចជឿថា ជំងឺរាគ គឺជារឿងធម្មតារបស់កុមារ ដូច្នេះពួកគាត់មិនបានចាត់វិធានការណាមួយដើម្បីការពារឬព្យាបាលវាទេ)។ វាចាំបាច់ណាស់ក្នុងការនិយាយជាមួយប្រជាជនដែលរងផលប៉ះពាល់ដើម្បីធានាថាពួកគេបានចូលរួមគ្រប់ដំណាក់កាលនៃកម្មវិធី។

*ភាពអាចទទួលយកបាន*

> ភាពអាចទទួលយកបានមានសារៈសំខាន់ណាស់ដែលយើងត្រូវធ្វើឱ្យវាកើតមានឡើង។

រាល់សកម្មភាពទឹកស្អាត អនាម័យ របស់កាកបាទក្រហម និងអឌ្ឍចន្ទក្រហមត្រូវតែផ្តោតដល់៖ ការផ្តល់ព័ត៌មាន ការស្តាប់យ៉ាងសកម្មពីអ្នកដែលរងផលប៉ះពាល់ អាកប្បកិរិយាគោរព និងការយល់ចិត្តដល់អ្នកដែលយើងជួយ។

ចងចាំ:

- តើយើងកំពុងមានភាពបើកចំហ និងមានតម្លាភាពទេ?
- តើយើងកំពុងស្តាប់សហគមន៍ទេ?
- តើពួកគាត់ចូលរួមជាមួយយើងឬទេ?
- តើមតិយោបល់របស់សហគមន៍កំពុងត្រូវបានយកមកពិចារណាយ៉ាងដូចម្តេចខ្លះ?
- តើមានយន្តការផ្តល់យោបល់ត្រឡប់ដែលមានប្រសិទ្ធភាពឬទេ?
- តើសហគមន៍មានព័ត៌មានគ្រប់គ្រាន់សម្រាប់ការឆ្លើយតបទេ?
- តើបុគ្គលិកដែលត្រូវបានជ្រើសរើសមានជំនាញនិងឥរិយាបថត្រឹមត្រូវដែរឬទេ?

បុគ្គលិក និងអ្នកស្ម័គ្រចិត្តកាកបាទក្រហម និងអឌ្ឍចន្ទក្រហមទាំងអស់ដែលចូលរួមក្នុងសកម្មភាពលើកកម្ពស់អនាម័យចាំបាច់ត្រូវស្គាល់ និងប្រកាន់ខ្ជាប់នូវគោលការណ៍និងស្តង់ដារមនុស្សធម៌រួមមាន:

- គោលការណ៍គ្រឹះកាកបាទក្រហម និងអឌ្ឍចន្ទក្រហម
- ចលនាកាកបាទក្រហម និងអឌ្ឍចន្ទក្រហម និងក្រមសីលធម៌របស់អង្គការ
- ស្តង់ដារនៅក្នុងសៀវភៅណែនាំ Sphere
- បទដ្ឋានមនុស្សធម៌ស្នូល
- ស្តង់ការប្តេជ្ញាចិត្តរបស់ IFRC ចំពោះយេនឌ័រ និងភាពចម្រុះភាពក្នុងពេលមានគ្រោះមហន្តរាយ
- គណនេយ្យភាពចំពោះអ្នកទទួលផល

អាជ្ញាធរមូលដ្ឋានគួរបញ្ចូលចំណុចនេះនៅក្នុងវគ្គបណ្តុះបណ្តាលសម្រាប់អ្នកស្ម័គ្រចិត្តនិងបុគ្គលិកថ្មីដែលចូលរួមក្នុងការឆ្លើយតបគ្រោះមហន្តរាយ។ ហើយអ្នកដែលគ្រប់គ្រងកម្មវិធីលើកកម្ពស់អនាម័យត្រូវការធានាថាបុគ្គលិក និងអ្នកស្ម័គ្រចិត្តស្គាល់ច្បាស់ពីគោលការណ៍ និងការណែនាំទាំងនេះហើយពួកគេត្រូវបានពិចារណា និងប្រកាន់ខ្ជាប់នូវគ្រប់ដំណាក់កាលទាំងអស់នៃកម្មវិធី។

## ៨ ជំហានសម្រាប់ការផ្សព្វផ្សាយអំពីអនាម័យនៅពេលមានគ្រោះមហន្តរាយ

ការលើកកម្ពស់អនាម័យក្នុងពេលមានគ្រោះមហន្តរាយរបស់កាកបាទក្រហម និងអឌ្ឍចន្ទក្រហមមាន

### ៨ ជំហានធំ:

1. កំណត់រកបញ្ហា
2. កំណត់ក្រុមគោលដៅ
3. ការវិភាគឧបសគ្គ និងកត្តាជម្រុញលើកទឹកចិត្តសម្រាប់ការផ្លាស់ប្តូរអាកប្បកិរិយា
4. ការបង្កើតគោលបំណងឱ្យមានការផ្លាស់ប្តូរឥរិយាបថអនាម័យ
5. ការធ្វើផែនការ
6. ការអនុវត្ត

7. ការត្រួតពិនិត្យនិងវាយតម្លៃ
8. ការពិនិត្យ និងការកែសំរួលឡើងវិញ

## ការផ្លាស់ប្តូរសហគមន៍

សូមចងចាំថាកត្តាដែលបញ្ឈប់មនុស្សលែងឱ្យមានឥរិយាបទមិនល្អនឹងមកអនុវត្តឥរិយាបទដែលមានសុវត្ថិភាពមិនទាក់ទងនឹងកង្វះចំណេះដឹងអំពីទ្រឹស្តីនៃមេរោគ ឬផ្លូវឆ្លងជំងឺនោះទេ។ ភាគច្រើនឧបសគ្គទាំងនោះទាក់ទងទៅនឹងកត្តាវប្បធម៌សង្គម (ឧទាហរណ៍នៅក្នុងសហគមន៍ខ្លះស្ត្រីមិនអាចប្រើបង្គន់ជាមួយឪពុកក្មេកបានទេ) សាសនា (ឧទាហរណ៍អង្គុយចោងហោង) ឬរូបវន្ត (ឧទាហរណ៍គ្មានកន្លែង រឺគ្មានលទ្ធភាពរបស់ពួកគេ) ។ កុំធ្វើការសន្និដ្ឋានថាប្រជាជនគ្មានចំណេះដឹង - ពួកគាត់គ្រាន់តែមានការយល់ខុសគ្នា! វាជាភារកិច្ចរបស់អ្នកផ្សព្វផ្សាយអនាម័យដើម្បីពិភាក្សាជាមួយសហគមន៍ និងវិភាគពីរបៀបដែលប្រជាជនគិតរួមជាមួយអ្វីដែលពួកគេដឹង។

*ជំហានទី ១ :ការកំណត់រកបញ្ហា*

ក្រុមនេះបង្កើតតាមរយៈសកម្មភាពវាយតម្លៃព័ត៌មានបានមកពីឥរិយាបទអនាម័យបច្ចុប្បន្នរបស់សហគមន៍ និងផលប៉ះពាល់ពីគ្រោះមហន្តរាយមកលើសហគមន៍។ ចំណុចសំខាន់ៗដែលត្រូវពិចារណាគឺ:

- ផលប៉ះពាល់នៃគ្រោះមហន្តរាយ
- ហានិភ័យចំពោះសុខភាព
- ឥរិយាបថអនាម័យបច្ចុប្បន្ន និងការផ្លាស់ប្តូររបស់សហគមហន៍ដោយសារគ្រោះមហន្តរាយ តើមួយណាអាចបង្កគ្រោះថ្នាក់ជាង
- អ្វីដែលសហគមន៍ ដឹង ធ្វើ យល់ និងចង់បានអំពីទឹកស្អាត និងអនាម័យ
- ទឹកស្អាត និងអនាម័យទាក់ទងនឹងអត្រាឈឺ និងមរណភាព
- ការទទួលបានទឹកស្អាតនិងអនាម័យ

ក្រុមលើកកម្ពស់អនាម័យធ្វើការជាមួយសហគមន៍ដែលរងផលប៉ះពាល់ វិស្វករ រដ្ឋាភិបាល និងក្រុមកាកបាទក្រហមអឌ្ឍចន្ទក្រហម (ឧទាហរណ៍ RDRTs, ERUs ជាដើម) ដើម្បីបញ្ចប់ការវាយតម្លៃ។ ពួកគេគួរតែប្រើវិធីសាស្ត្រដែលមានការចូលរួមអន្តរកម្មជាមួយគ្រប់ផ្នែកទាំងអស់នៃសហគមន៍ ៖ មានដូចជាបុរស ស្ត្រី និងកុមារ (មិនត្រូវភ្លេចក្រុមជនងាយរងគ្រោះក្រុមដែលគេមើលរំលងរួមទាំងជនពិការផងដែរ) ដើម្បីប្រមូលព័ត៌មាន និងចូលរួមជាមួយសហគមន៍ក្នុងការធ្វើការជាមួយពួកគេដើម្បីកំណត់រកបញ្ហា ជួយពួកគេរកដំណោះស្រាយ។

*ជំហានទី ២: ការកំណត់ក្រុមគោលដៅ*

ក្រុមកំណត់អត្តសញ្ញាណក្រុមគោលដៅអាទិភាពដែលពួកគេចង់បាន។ ចំណុចសំខាន់ៗក្នុងការពិចារណានៅពេលជ្រើសរើសក្រុមគោលដៅគឺ:

- តើអ្នកណាដែលប្រឈមនឹងគ្រោះថ្នាក់ជាងគេបំផុត?
- តើអ្នកណាជាអ្នកមានឥទ្ធិពលនៅក្នុងសហគមន៍? ឧទាហរណ៍អ្នកដឹកនាំសហគមន៍ ឬអ្នកដឹកនាំសាសនា

- ធានាថា គ្រប់ផ្នែកទាំងអស់នៃសហគមន៍ដែលរងផលប៉ះពាល់ត្រូវបានដាក់បញ្ចូល (ឧទាហរណ៍ កុមារ មនុស្សចាស់ ជនពិការ) និងអ្នកពាក់ព័ន្ធផ្សេងទៀត។
- ការសង្កត់ធ្ងន់ពិសេសទៅលើតម្រូវការរបស់ទារក និងកុមារតូចៗ (ដោយសារពួកគេត្រូវការសម្ភារៈទឹកស្អាតផ្សេងៗគ្នា)។

ការសម្រេចចិត្តរបស់ប្រជាជន គឺអាស្រ័យលើព័ត៌មានដែលពួកគេមានសមត្ថភាពចូលរួម និងការលើកទឹកចិត្តឱ្យចូលរួមក្នុងកម្មវិធីនេះ។ការនេះមិនអាចសំរេចបានទេបើនៅពេលចាប់ផ្តើមគ្រោះមហន្តរាយដែលមានកំរិតនៃការបំផ្លាញខ្លាំង ការបាត់បង់មនុស្ស និងរបួស ប៉ុន្តែយ៉ាងហោចយើងអាចធ្វើក្នុងកំរិតមូលដ្ឋាននៃការពិគ្រោះយោបល់ និងផ្តល់ព័ត៌មានចាំបាច់តាំងពីការចាប់ផ្តើមដំបូងនៃប្រតិបត្តិការ។

### ជំហានទី ៣: ការវិភាគឧបសគ្គ និងកត្តាលើកទឹកចិត្តក្នុងការផ្លាស់ប្តូរឥរិយាបទ

ក្រុមប្រមូលព័ត៌មានពីការលើកទឹកចិត្តផ្សេងៗគ្នាដែលអាចឱ្យមានការផ្លាស់ប្តូរឥរិយាបទប្រជាជនដែលរងផលប៉ះពាល់។ ឧទាហរណ៍ ក្មេងតូចងចាំនូវអ្វីដែលម្តាយរបស់គេធ្វើតាំងពីបានចិញ្ចឹមបីបាច់ពួកគេពេលដែលពួកគេនៅក្មេង ឬ នៅក្នុងសង្គមចំពោះបុរសអាចជានិមិត្តរូបនៃភាពទាក់ទាញបំផុត។ ព័ត៌មានដែលប្រមូលបានតាមរយៈការវាយតំលៃពីសេចក្តីត្រូវការ ដែលជាភស្តុតាងស្តីពីអ្វីដែលបញ្ឈប់ប្រជាជនពីការធ្វើសកម្មភាពដោយខ្លួនឯង:

តើដោយសារតែកង្វះចំណេះដឹង (ឧទាហរណ៍ពួកគេប្រហែលជាមិនស៊ាំនឹងជំងឺគ្រុនចាញ់ទេ ប្រសិនបើពួកគេត្រូវបានផ្លាស់ទីលំនៅមកពីតំបន់ដែលមិនមានជំងឺគ្រុនចាញ់)?

- តើដោយសារតែជាការយល់ដឹងខុសពីគ្នាៗ (ឧទាហរណ៍ពាក្យរាគអាចត្រូវបានបកប្រែដោយអត្ថន័យខុសគ្នា)?
- តើដោយសារមានការគិតខុសគ្នា (ឧទាហរណ៍ ពួកគេអាចគិតថាលាមករបស់ទារកមិនមានគ្រោះថ្នាក់ទេ)
- តើដោយសារខ្វះខាតធនធាន (កង្វះទឹក សាប៊ូ អនាម័យ បង្គន់អនាម័យជាដើម)

ការវិភាគលើកត្តាដែលរារាំងដែលនាំឱ្យសហគមន៍ និងអ្នកពាក់ព័ន្ធអនុវត្តសកម្មភាពមិនមានសុវត្ថិភាព។ ការវាយតំលៃគួរតែរួមបញ្ចូលសកម្មភាពបែបការចូលរួម (ការពិភាក្សាក្រុមផ្តោតការគូសផែនទី ការបោះឆ្នោតសកម្មភាពជាចំណាត់ថ្នាក់ជាដើម) ។ ទាំងនេះប្រហែលជាមិនងាយធ្វើទេនៅដំណាក់កាលដំបូងនៃការឆ្លើយតបគ្រោះមហន្តរាយ។ ប៉ុន្តែការចូលរួមជាមួយសហគមន៍គឺមានសារៈសំខាន់ ហើយព័ត៌មានដែលមានប្រយោជន៍អាចត្រូវបានប្រមូលដោយប្រើបច្ចេកទេសអន្តរកម្មផ្សេងៗគ្នា។ សកម្មភាពទាំងនេះអាចត្រូវបានពង្រីកនៅពេលដែលស្ថានភាពមានស្ថេរភាព។ សំណួរអំពីឧបសគ្គ និងកត្តាលើកទឹកចិត្តដែលជាផ្នែកមួយនៃការវាយតម្លៃដំបូងជាការរៀនស្ថានភាពរបស់ប្រជាជន និងយកចំនុចដែររៀនបានមកធ្វើពិភាក្សាបើកចំហ។

## *ជំហានទី៤ ៖ការបង្កើតគោលបំណងទាក់ទាញឱ្យមានការផ្លាស់ប្តូរឥរិយាបទអនាម័យ*

ក្រុម និងអ្នកពាក់ព័ន្ធសំខាន់ៗរួមទាំងសហគមន៍ បានកំណត់គោលបំណងឱ្យហានិភ័យនីមួយៗ ដែលបានកំណត់ក្នុងដំណាក់កាលវាយតម្លៃ។ គោលបំណងអាចទាក់ទងទៅនឹងអាកប្បកិរិយាអនាម័យ (ឧទាហរណ៍ការបង្កើនការលាងដៃនៅពេលវេលាសំខាន់ៗ) ឬកត្តាជម្រុញនាំឱ្យធ្វើទៅបាន (ឧទាហរណ៍ កន្លែងលាងដៃមានសាប៊ូអាចយកមកប្រើបាន) ។

គោលបំណងប្រតិបត្តិការ និងការថែទាំត្រូវបានដាក់បញ្ចូលនៅក្នុងផែនការ (ឧទាហរណ៍ការចូលរួមរបស់ប្រជាជនដែលរងផលប៉ះពាល់ក្នុងការថែរក្សាបង្គន់អនាម័យ និងប្រព័ន្ធទឹក) ។

*ចាប់ផ្តើមគិតពីគោលបំណងជាមួយអ្នកដទៃទៀត*

ដើម្បីបញ្ចប់ការងារនេះក្រុមត្រូវការរៀបចំគោលបំណងជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀត (ឧទាហរណ៍ រដ្ឋាភិបាល) ។ តាមរយៈការធ្វើឱ្យអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់ចូលរួមក្នុងការធ្វើផែនការ និងការធ្វើសេចក្តីសម្រេចចិត្តធានាថាគោលបំណងគឺពាក់ព័ន្ធនឹងតម្រូវការនិងបរិបទ។

ការចូលរួមរបស់វិស្វករកាកបាទក្រហមអន្តរជាតិក្រហម (និងបុគ្គលិកបច្ចេកទេសរបស់រដ្ឋាភិបាល) ទទួលបន្ទុកក្នុងសកម្មភាពសាងសង់សំណង់ទឹកស្អាត និងអនាម័យមានសារៈសំខាន់ណាស់ការកំណត់គោលបំណង គឺជាធាតុសំខាន់សម្រាប់ការផ្លាស់ប្តូរឥរិយាបថ។ ក្រុមទាំងអស់ដូចជាអ្នកផ្សព្វផ្សាយអនាម័យ និងវិស្វករទាំងអស់គួរតែធ្វើជំហាននេះជាមួយគ្នា។

## *ជំហានទី៥:ការធ្វើផែនការ*

ក្រុមការងារអនុវត្តសកម្មភាពលើកកម្ពស់អនាម័យក្នុងពេលឆ្លើយតបគ្រោះមហន្តរាយត្រូវការផែនការការងារដែលបញ្ជាក់ពីបញ្ហា គោលបំណងសកម្មភាព ហើយបង្ហាញពី ឧបករណ៍ ធនធានដែលត្រូវការ (ទាំងហិរញ្ញវត្ថុ និងមនុស្ស) និងផែនការត្រួតពិនិត្យ និងវាយតម្លៃ។

ផែនការនេះមានប្រសិទ្ធភាពនៅពេលអនុវត្តជាមួយអ្នកដទៃ (វិស្វកររដ្ឋាភិបាលសហគមន៍ដែលរងផលប៉ះពាល់ ភ្នាក់ងារផ្សេងទៀតបុគ្គលិកសង្គម អង្គការជនពិការ។ល។) និងមិនធ្វើដោយក្រុមអ្នកផ្សព្វផ្សាយលើកកម្ពស់អនាម័យតែឯងនោះទេ។

ចាំបាច់ណាស់ដែលវិធីសាស្ត្រត្រូវផ្តោតធ្វើយ៉ាងណាឱ្យសហគមន៍ "ជួយខ្លួនពួកគាត់ឱ្យយល់ស្របលើសកម្មភាពសហគមន៍ និងសម្របសម្រួលការអនុវត្តសកម្មភាពនេះជាជាងនិយាយថា"យើងកំពុងធ្វើការផ្សព្វផ្សាយអនាម័យ តែបែជាក្រុមអ្នកផ្សព្វផ្សាយអនាម័យប្រាប់សហគមន៍អំពីអ្វីដែលគួរធ្វើ ឬអប់រំអ្នកដទៃជាមួយសារស្តង់ដារ - វិធីសាស្ត្រនេះកម្រមានប្រសិទ្ធិភាពណាស់។

ផែនការការងារគួរបញ្ចូលវិធីសាស្ត្ររួមបញ្ចូលគ្នា ដែលប្រើឧបករណ៍ទំនាក់ទំនងប្រភេទផ្សេងៗគ្នា ដែលអាចប្រើសម្រាប់គោលបំណងផ្សេងៗគ្នា (ចែករំលែកចំណេះដឹងឥទ្ធិពលនិងជម្រុញអ្នកដទៃធ្វើការសម្រេចចិត្ត។ ល។ ) ។ មិនមែនគ្រប់វិធីទាំងអស់សម្រាប់ការផ្សព្វផ្សាយអនាម័យតម្រូវឱ្យមានការប្រើប្រាស់"សារអនាម័យ" នោះទេ ។ បច្ចេកទេសចូលរួមឧទាហរណ៍ ការតម្រៀបកាតជាជាបីក្រុមផ្តោតលើការការជជែកវែកញែកជាជាងការបញ្ជូនសារនោះ។ គោលបំណង គឺដើម្បីកំណត់បញ្ហា និងយល់ព្រមលើដំណោះស្រាយដែលសាកសមបំផុតដើម្បីទាមទារសកម្មភាពដែលកើតពីសហគមន៍។ រាល់វិធីសាស្ត្រ និងព័ត៌មានអប់រំនិងសម្ភារៈទំនាក់ទំនងគួរតែត្រូវសាកល្បងជាមុន និងដើម្បីធានាថាពួកគេយល់ និងធ្វើឱ្យសមស្របទៅនឹងបរិបទ។

*ការជ្រើសរើសនិងការបណ្តុះបណ្តាលក្រុមការផ្សព្វផ្សាយអនាម័យ*

ការជ្រើសរើស ការបណ្តុះបណ្តាល និងការរក្សាអ្នកស្ម័គ្រចិត្តកាកបាទក្រហមអឌ្ឍចន្ទក្រហម គឺជាទិដ្ឋភាពសំខាន់នៃកម្មវិធីលើកកម្ពស់អនាម័យ។ ការពិពណ៌នាការងារសម្រាប់អ្នកស្ម័គ្រចិត្តកាកបាទក្រហមអឌ្ឍចន្ទក្រហមទាំងអស់ ដែលឆ្លើយតបក្នុងនាមជាអ្នកផ្សព្វផ្សាយអនាម័យគួរត្រូវបានព្រមព្រៀងជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ រួមទាំងអ្នកគ្រប់គ្រងថ្នាក់មូលដ្ឋានក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយ។ បុគ្គលិក និងអ្នកស្ម័គ្រចិត្តត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងសាខាតាមមូលដ្ឋានដូច្នេះនៅពេលជ្រើសរើសបុគ្គលិក និងអ្នកស្ម័គ្រចិត្តសម្រាប់ក្រុមលើកកម្ពស់អនាម័យការយកចិត្តទុកដាក់ត្រូវតែផ្តោតទៅលើអ្នកដែលអាចចូលរួមសហគមន៍បានយ៉ាងងាយស្រួល (ជំនាញទំនាក់ទំនងល្អ ទទួលបានការគោរពពីសហគមន៍)។ អ្នកស្ម័គ្រចិត្តកាកបាទក្រហមអឌ្ឍចន្ទក្រហម គឺជាសកម្មភាពតំណាងឱ្យការនុវត្តផែនការលើកកម្ពស់អនាម័យ។ ការទទួលស្គាល់ និងការកសាងលើជំនាញដែលមានស្រាប់។ អ្នកស្ម័គ្រចិត្តដែលធ្វើការក្នុងកម្មវិធី WASH រយៈពេលវែងនឹងកាន់តែមានជំនាញក្នុងការកៀងគរ និងជួយសម្របសម្រួលបានល្អ។ ពួកគេច្រើនស្គាល់វិធីសាស្ត្រលើកកម្ពស់អនាម័យបែបមូលដ្ឋានសង្គម។ ឧទាហរណ៍ PHAST អ្នកស្ម័គ្រចិត្តដែលទទួលការបណ្តុះបណ្តាលក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយ (ឧទាហរណ៍៖

សមាជិកនៃ NDRT ) មានវិធីសាស្រ្តរហ័ស និងបត់បែនដែលត្រូវការប្រើពេលភាពបន្ទាន់ ។

## ជំហានទី៦:ការអនុវត្ត

ចំណុចសំខាន់ៗដែលត្រូវពិចារណានៅពេលអនុវត្តផែនការលើកកម្ពស់អនាម័យរួមមានការសម្របសម្រួល និងការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់៖ សហគមន៍ដែលរងផលប៉ះពាល់អាចមានធនធានដើម្បីគាំទ្រសកម្មភាពទាំងនេះ:

- អាជ្ញាធរមូលដ្ឋានមានធនធានដែលអាចរកបាន - ឧទាហរណ៍ តើពួកគេមានប្រអប់ផ្សព្វផ្សាយអនាម័យ សម្ភារអប់រំ ព័ត៌មាន ឬប្រអប់ឧបករណ៍ផ្សេងដែរឬទេ?
- រដ្ឋាភិបាលមានស្តង់ដារផ្ទាល់ខ្លួនផងដែរ ឧទាហរណ៍ គោលនយោបាយជាតិដែលបញ្ជាក់ពីវិធីសាស្រ្តដែលត្រូវយកមកប្រើប្រាស់) ។
- អនុក្រុមលើកកម្ពស់អនាម័យបានភ្ជាប់ទំនាក់ទំនង ជាមួយដៃគូដទៃទៀតដែលធ្វើការក្នុងវិស័យនេះ និងរៀបចំអនុសាសន៍បច្ចេកទេសសម្រាប់យកមកប្រើផងដែរ។
- ទីភ្នាក់ងារផ្សេងទៀតដែលឆ្លើយតបនឹងសកម្មភាពលើកកម្ពស់អនាម័យក៏អាចចែករំលែកធនធាន និងគំនិតរបស់ពួកគេក្នុងការសម្របសម្រួលចាំបាច់ក្នុងការចៀសវាងជាន់មេរៀនគ្នា: សម្របសម្រួល ចែករំលែក និងបង្រៀន! អង្គការជនពិការអាចផ្តល់ជំនាញអំពីតម្រូវការជនពិការ និងធនធានសម្រាប់ជំនាញបច្ចេកទេសលើភាពងាយស្រួលលើមធ្យោបាយ និងលទ្ធភាពទទួលបានព័ត៌មាន។

**ធ្វើការជាមួយវិស្វករ៖** វិស្វករកាកបាទក្រហមអន្តរជាតិ និងកាកបាទក្រហមកម្ពុជាចូលរួមក្នុងការសាងសង់ និងថែទាំសំណង់អនាម័យ (ឧទាហរណ៍ បង្គន់ ប្រព័ន្ធទឹក កន្លែងលាងដៃ) គួរតែចូលរួមគ្រប់ដំណាក់កាលនៃកម្មវិធីលើកកម្ពស់អនាម័យ និងជាពិសេសដំណាក់កាលវាយតម្លៃ និងការធ្វើផែនការ។ សកម្មភាពសាងសង់ និងការផ្សព្វផ្សាយត្រូវផ្សារភ្ជាប់គ្នា។ ឧទាហរណ៍ សង់បង្គន់តាមលក្ខណៈបច្ចេកទេស ប៉ុន្តែតាមទស្សនៈរបស់ប្រជាជនមិនចូលចិត្តដោយសារមិនសមស្របសម្រាប់ការប្រើប្រាស់របស់គាត់ - ដោយសារនៅក្នុងទីតាំងដែលមិនមានសុវត្ថិភាពឬមិនមែនជាប្រភេទបង្គន់ដែល

ពួកគេទម្លាប់ប្រើប្រាស់។ អ្នកផ្សព្វផ្សាយអនាម័យទទួលខុសត្រូវក្នុងការពិគ្រោះយោបល់ និងបញ្ជូនបន្តនូវចំណង់ចំណូលចិត្តបំណងប្រាថ្នា និងសេចក្តីប្រាថ្នារបស់ប្រជាជនទាក់ទងនឹងការរចនាប្លង់បង្គន់ និងការដាក់សម្ភារៈប្រើប្រាស់ទឹកស្អាតដល់វិស្វករ។ អ្នកផ្សព្វផ្សាយអនាម័យក៏អាចចូលរួមក្នុងសម្អាតទឹកផឹកក្នុងគ្រួសារគាំទ្រដល់វិស្វករកាកបាទក្រហមអឌ្ឍចន្ទក្រហម ក្នុងការបណ្តុះបណ្តាល និងតាមដានការប្រើប្រាស់ផលិតផលសម្អាតទឹក។ សកម្មភាពទាំងនេះអាចត្រូវបានផ្សំជាមួយនឹងសកម្មភាពផ្សព្វផ្សាយអនាម័យនៅកម្រិតគ្រួសារ និងសហគមន៍។

ក្រុមជួយសង្គ្រោះរបស់កាកបាទក្រហមនិងអឌ្ឍចន្ទក្រហមធ្វើការចែកអំណោយក្នុងពេលឆ្លើយតបគ្រោះមហន្តរាយ។ អ្នកផ្សព្វផ្សាយអនាម័យមិនចែកចាយផលិតផលដែលទាក់ទងនឹងអនាម័យទេ (ឧបករណ៍ សាប៊ូ ធុងជាដើម) ប៉ុន្តែពួកគេអាចចូលរួមក្នុងការចែកចាយសម្ភារៈអនាម័យតិចតួចដែលជាផ្នែកមួយនៃការបណ្តុះបណ្តាល ការបង្ហាញឬសកម្មភាពផ្សព្វផ្សាយ។ ប្រសិនបើខ្វះចន្លោះទាក់ទងនឹងការទទួលបានរបស់សំខាន់ៗ (សាប៊ូ និងធុងទឹក) នេះចាំបាច់ត្រូវរាយការណ៍ទៅក្រុមផ្តល់ជំនួយដែលកំពុងប្រតិបត្តិការនៅក្នុងមូលដ្ឋាន និង IFRC ។

អ្នកផ្សព្វផ្សាយអនាម័យមានតួនាទីសំខាន់ក្នុងការធានាថាសមាជិកទាំងអស់នៃសហគមន៍ (បុរស ស្ត្រី កុមារ និងជនពិការ) មានសិទ្ធិទទួលបានសម្ភារៈអនាម័យដែលសមស្របសម្រាប់តម្រូវការរបស់ពួកគេ។ ពួកគេគួរតែជួយភ្ជាប់ទំនាក់ទំនងរវាងការស្តាប់ពីសហគមន៍ និងការទំនាក់ទំនងជាមួយក្រុមផ្តល់ជំនួយ រួមទាំងការផ្តល់មតិយោបល់ពីសហគមន៍លើការចែកចាយសម្ភារៈអនាម័យ។

ការគ្រប់គ្រងអនាម័យពេលមានរដូវមិនគួរភ្លេចទេ។ តួនាទីរបស់អ្នកផ្សព្វផ្សាយអនាម័យ គឺត្រូវពិភាក្សាជាមួយស្ត្រីដើម្បីរកឱ្យឃើញនូវអ្វីដែលនាំពួកគាត់បានអនុវត្ត អ្វីដែលពួកគាត់ចង់ធ្វើ ហើយធនធានអ្វីខ្លះដែលពួកគាត់ត្រូវការ និងឧបសគ្គចំពោះអនាម័យពេលមានរដូវ។ ហើយត្រូវប្រើព័ត៌មាននោះដើម្បីយកមកធ្វើឧបករណ៍ផ្សព្វផ្សាយតាមគ្រួសារ (ហៅថាឧបករណ៍សេចក្តីថ្លៃថ្នូរ ឧបករណ៍ មករដូវ ឧបករណ៍ ស្ត្រីជាដើម) ។

***ជំហានទី៧:*** ការត្រួតពិនិត្យ និងការវែកញែក

ការស្ទង់មតិមូលដ្ឋានចាំបាច់ត្រូវបញ្ចប់នៅដើមកម្មវិធី។ ឧបករណ៍ ស្ថិតិទំនើបមិនចាំបាច់ប្រើទេប៉ុន្តែវិធីសាស្ត្រប្រមូលសំណាកស្តង់ដាត្រូវតែប្រើជាចាំបាច់។ វិធីសាស្ត្ររហ័ស និងសាមញ្ញប្រើសម្រាប់ការផ្លាស់ប្តូរសំខាន់ៗនៅក្នុងស្ថានភាពជាក់ស្តែង និងឥរិយាបទជាក់លាក់មួយ។ ទិន្នន័យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (ដូចជា ការពិភាក្សាជាក្រុមការផ្តោតលើការបោះឆ្នោត) គួរត្រូវបានកត់ត្រារួមជាមួយព័ត៌មានមូលដ្ឋានបរិមាណ។

ក្រុមត្រូវការតាមដានវឌ្ឍនភាព និងផលប៉ះពាល់នៃកម្មវិធីលើកកម្ពស់អនាម័យ។ រាប់ការបញ្ចូលកំណត់ត្រានិន្នាការ ឧទាហរណ៍ ការប្រើប្រាស់បង្គន់អនាម័យ។ ការត្រួតពិនិត្យមិនមែនគ្រាន់តែអំពីតួលេខទេ ប៉ុន្តែការសួរសំណួរដូចជា:តើប្រជាជន

ទទួលបានអត្ថប្រយោជន៍ពីកម្មវិធីដែរឬទេ? ហេតុអ្វីបានជាពួកគេមិនប្រើប្រាស់ (រួមទាំងកុមារ)សំណង់សម្ភារៈទឹកស្អាតទាំងនោះ តើការផ្តល់ព័ត៌មានត្រឡប់ និងកាឆ្លើយតបរបស់ពួកគេត្រូវបានគេដឹង និងយកមកអនុវត្តដែរឬទេ?

ក្រុមការងារបង្កើតសូចនាករកំណត់ប្រព័ន្ធត្រួតពិនិត្យ (ភ្ជាប់ជាមួយឥរិយាបថអនាម័យ និងបរិបទ) ដោយលម្អិតពីវិធីសាស្ត្រ និងភាពញឹកញាប់ (អាស្រ័យលើបរិបទ)របស់ប្រព័ន្ធ ។

ព័ត៌មានទាំងអស់គួរតែបញ្ចូលទៅក្នុងដំណើរការរៀបចំផែនការ (ជំហានទី៥) ហើយគួរតែត្រូវបានប្រើសម្រាប់ការកែប្រែសកម្មភាពនិងវិធីសាស្ត្រឡើងវិញ។

ការវាយតម្លៃគួរតែត្រូវបានធ្វើឡើង (ទាំងការវាយតំលៃតាមពេលវេលាជាក់ស្តែងនិង / ឬនៅចុងបញ្ចប់នៃកម្មវិធីដើម្បីកត់ត្រាសមិទ្ធផលបញ្ហាប្រឈម និងមេរៀនដែលបានរៀនពីការស្ទង់មតិចុងក្រោយ (ដោយប្រើសំណួរដូចគ្នានឹងពេលចាប់ផ្តើមសួរពីដំបូងមូលដ្ឋាន) ធ្វើជាផ្នែកមួយនៃការវាយតំលៃដើម្បីវាយតម្លៃការផ្លាស់ប្តូរ។An

## *ជំហានទី៨: ការពិនិត្យ និងកែសំរួលឡើងវិញ*

ត្រូវចងចាំថាកម្មវិធីលើកកម្ពស់អនាម័យគឺពាក់ព័ន្ធនឹងតម្រូវការ។ ពេលមានគ្រោះមហន្តរាយស្ថានភាពតែងតែស្មុគស្មាញដោយមានការផ្លាស់ប្តូរស្ថានភាពជាញឹកញាប់។ ការវាយតម្លៃឥតឈប់ឈរការធ្វើផែនការឡើងវិញ និងការកែសំរួលសកម្មភាពឡើងវិញគឺចាំបាច់ណាស់។ មើលជុំវិញ! តើមានបញ្ហាទឹកស្អាតផ្សេងទៀតនៅក្នុងសហគមន៍រងផលប៉ះពាល់ដែលមិនបានដោះស្រាយបានដែរឬទេ? តើបញ្ហាបានផ្លាស់ប្តូរហើយឬនៅ? មានបញ្ហាថ្មីកើតឡើងទេ? បើដូច្នេះសូមត្រឡប់ទៅជំហានទី១ ហើយចាប់ផ្តើមម្តងទៀត។

លើសពីនេះទៀតឯកសារត្រួតពិនិត្យ និងវាយតម្លៃ រូបថត និងវីដេអូដែលបានផលិតរួចគួរតែបានចែករំលែកជាមួយសមភាគីមូលដ្ឋាន និងអង្គភាព IFRC ដើម្បីកំណត់អត្តសញ្ញាណ និងបន្តការគាំទ្រ (បើត្រូវការ) ដល់សហគមន៍ និងចាប់បាននូវចំណុចដែលត្រូវយកមករៀនសូត្រ។

## ១.២. គោលការណ៍ណែនាំរបស់ IFRC ក្នុងការលើកកម្ពស់អនាម័យ - ការដោះស្រាយបញ្ហាភ្លាមៗ

**ការផ្សព្វផ្សាយលើកកម្ពស់អនាម័យក្នុងពេលគ្រោះមហន្តរាយនៅកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ត្រូវបានកំណត់ដូចខាងក្រោម:**
វិធីសាស្ត្រដែលបានគ្រោងទុក និងមានលក្ខណៈជាប្រព័ន្ធដោយបុគ្គលិក និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា ដើម្បីឱ្យប្រជាជនមានសកម្មភាពក្នុងការការពារជំងឺទាក់ទងនឹងទឹក បង្គន់ និងអនាម័យផ្ទាល់ខ្លួនតាម រយៈការកៀងគរ និងការចូលរួមរបស់ប្រជាជនដែលរងផលប៉ះពាល់ ចំណេះដឹង និងធនធានរបស់ពួកគេ ឱ្យពួកគេបានប្រើប្រាស់ និងទទួលសម្ភារៈបរិក្ខា និងសំណង់ទឹកស្អាត និងអនាម័យឱ្យបានច្រើនបំផុត។

| ការផ្សព្វផ្សាយអនាម័យ ពេលមានគ្រោះមហន្តរាយ | | | |
|---|---|---|---|
| **ជំហាន** | **ការពិពណ៌នា** | **អ្នកទទួលខុសត្រូវ** | **ប្រភពព័ត៌មាន** - all documents available at [https://ifrcwatsanmissionassistant.wordpress.com/hygiene-promotion/watsanmissionassistant - Software hygiene promotion](https://ifrcwatsanmissionassistant.wordpress.com/hygiene-promotion/watsanmissionassistant) |
| **ជំហានទី១:**<br>ការកំណត់រកបញ្ហា | ប្រមូលព័ត៌មានបរិមាណ និងគុណភាព ដើម្បីយល់ពីអ្វីដែលសហគមន៍ដឹង និងធ្វើ តើអ្វីជាតម្រូវការហានិភ័យក្នុងការអនុវត្ត និងរចនាសម្ព័ន្ធសហគមន៍ និងផលប៉ះពាល់នៃគ្រោះមហន្តរាយដោយការប្រើប្រាស់:<br>-ទិន្នន័យបន្ទាប់បន្សំដែលមានស្រាប់<br>- ការគូរផែនទី<br>- ការសង្កេត និងការដើរកាត់ភូមិ<br>- សម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋានភ្នាក់ងារដទៃទៀត ក្រុមទឹកស្អាត និងអនាម័យ បុគ្គលិក | វិស្វករផ្នែកសម្ភារៈអនាម័យ សហគមន៍ផ្នែកផ្សេងៗ ដែលធ្វើការក្នុងសហគមន៍តែមួយ ស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត | • IFRC Minimum Standard Commitments to Gender and Diversity in Emergency Programmes<br>• IFRC Guidelines for Emergency Assessment in English, French, Spanish, Arabic |

| | | | |
|---|---|---|---|
| | -ការពិភាក្សាជាក្រុមសហគមន៍ កាកបាទក្រហមអឌ្ឍចន្ទក្រហម (ការតម្រៀបកាតនិងសកម្មភាព និងបុគ្គលិកស្ម័គ្រចិត្ត គំនូសតាងបោះឆ្នោតតាមផត់ឃីត) | | • Sphere Project Water and Sanitation Initial Need Assessment Checklist<br>• Transect walk<br>• Working with communities: a toolbox |
| **ជំហានទី២:**<br><br>ការកំណត់រកក្រុមគោលដៅ | កំណត់ក្រុមគោលដៅរួមគ្នាជាមួយសហគមន៍។ ក្រុមគោលដៅត្រូវរាប់បញ្ចូលៈ អ្នកដែលមានហានិភ័យខ្ពស់នៅក្នុងសហគមន៍គ្រប់ផ្នែកទាំងអស់នៃសហគមន៍ (កុមារមនុស្សចាស់ និងជនពិការ) និងក្រុមដែលត្រូវយកចិត្តទុកដាក់ពិសេស (ឧទាហរណ៍ទារក / កុមារតូច) ដែលមានតម្រូវការផ្សេងៗគេ។ | អ្នកដឹកនាំសហគមន៍ និងបុគ្គលិកសុខាភិបាល វិស្វករសំណង់ ជាងសំណង់ ភ្នាក់ងារដទៃទៀតដែលធ្វើការនៅតំបន់នោះនិងអង្គការជនពិការ | • Target group selection<br>• Gender checklist for WASH<br>• Inclusive WASH learning portal (WaterAid) |
| **ជំហានទី៣:**<br>ការវិភាគឧបសគ្គរារាំងនិងកត្តាជម្រុញលើកទឹកចិត្ត ដើម្បីផ្លាស់ប្តូរទម្លាប់ | ការប្រមូលព័ត៌មានស្តីពីការលើកទឹកចិត្ត និងឧបសគ្គផ្សេងៗដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា និងលុបបំបាត់ / កាត់បន្ថយឧបសគ្គ។<br><br>សិក្សាពីប្រតិកម្ម ការបញ្ឈេះ និងវប្បធម៌ ហើយនិងផ្លាស់ប្តូរដោយយោងទៅតាមការសង្កេត និងការផ្តល់យោបលត្រឡប់។ | វិស្វករផ្នែកសម្ភារៈអនាម័យ អ្នកទទួលផល បុគ្គលិកមន្ទីរសុខាភិបាល រដ្ឋាភិបាល អង្គការជនពិការ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត | • Transmission route<br>• Good and bad behaviours |

| | | | |
|---|---|---|---|
| **ជំហានទី៤:** គោលបំណងក្នុងការបង្កើតទម្លាប់អនាម័យ | ការកំណត់គោលបំណងទៅតាមហានិភ័យនិមួយៗអាចទាក់ទងទៅនឹងការផ្លាស់ប្តូរអាកប្បកិរិយាអនាម័យ ឬកត្តាដែលអាចធ្វើទៅបាន។ | អ្នកដឹកនាំសហគមន៍ និងបុគ្គលិកសុខាភិបាល បុគ្គលិកបណ្តុះបណ្តាល និងអ្នកស្ម័គ្រចិត្តអនាម័យ ក្រុមបណ្តុះបណ្តាលសហគមន៍ត្រូវបានជ្រើសរើសសម្រាប់ការធ្វើតេស្តមុនពេលចាប់ផ្តើម | • IFRC PoA template – indicators<br>• Outcomes, outputs and activities view |
| **ជំហានទី៥:** ការធ្វើផែនការ | ធ្វើការជាមួយវិស្វករសំណង់ និងអ្នកដទៃទៀតដើម្បីបង្កើតផែនការការងារចេញពីគោលដៅដែលបានកំណត់ និងជ្រើសរើសលទ្ធផល និងសូចនាករដោយប្រើរូបភាព (ការស្ទង់មតិ និងវិធីសាស្ត្រផ្សេងទៀត) នៃស្ថានភាពជាក់ស្តែង ដែលមានដូចខាងក្រោម:<br>• ការជ្រើសរើសវិធីសាស្ត្រ និងរបៀបទំនាក់ទំនងទៅក្រុមគោលដៅផ្សេងៗគ្នា រួមមានការទំនាក់ទំនងជាជនពិការភ្នែក ពិបាកក្នុងការស្តាប់ និងពិការសតិបញ្ញា និងអ្នកមានការលូតលាស់ខ្សោយ។<br>• រៀបចំសម្ភារៈសម្រាប់សកម្មភាពផ្សព្វផ្សាយអនាម័យ (ប្រើប្រអប់ផ្សព្វផ្សាយអនាម័យ)<br>• ការជ្រើសរើសអ្នកស្ម័គ្រចិត្តសំរាប់អន្តរាគមន៍ក្នុងការលើកកម្ពស់អនាម័យ<br>• សាកល្បង និងធ្វើមុនពេលចាប់ផ្តើមសកម្មភាព ជាមួយសមាជិកក្រុមមួយចំនួនតូច<br>• ធ្វើការផ្លាស់ប្តូរ និងចាប់ផ្តើមអនុវត្ត | បណ្តុះបណ្តាលបុគ្គលិកផ្សព្វផ្សាយអនាម័យ និងបុគ្គលិកស្ម័គ្រចិត្ត សមាជិកសហគមន៍គោលដៅ និងវិស្វករសំណង់ | • Volunteer management toolkit<br>• PHAST<br>• CLTS<br>• Sampling |

| | | | |
|---|---|---|---|
| | • រៀបចំផែនការតាមដាន និងរបាយការណ៍សកម្មភាព<br>• រៀបចំពេលវេលា និងអនុវត្តសកម្មភាពលើកកម្ពស់អនាម័យ | | |
| **ជំហានទី៦:**<br>ការអនុវត្តន៍ | អនុវត្តតាមផែនការនិងអនុវត្តសកម្មភាពតាមការគ្រោងទុក។<br>សកម្មភាពសំខាន់ៗគឺៈ<br>ធ្វើការជាមួយវិស្វករសំណង់ និងអ្នកដទៃទៀត ដើម្បីបង្កើតការទំនាក់ទំនងឱ្យមានផ្លាស់ប្តូរអាកប្បកិរិយាដោយប្រើសម្ភារៈទឹកស្អាតនិងអនាម័យ<br>រៀបចំពេលវេលា និងអនុវត្តសកម្មភាពលើកកម្ពស់អនាម័យ<br>• ជ្រើសរើស និងបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្ត និងបុគ្គលិក<br>• ធ្វើការរួមគ្នាជាមួយក្រុមផ្តល់ជំនួយដើម្បីផ្តល់យោបល់ត្រឡប់ពី/ដល់សហគមន៍ចំពោះការចែកចាយរបស់របរអនាម័យ | ធ្វើការបណ្តុះបណ្តាលបុគ្គលិកផ្សព្វផ្សាយអនាម័យនិងបុគ្គលិកស្ម័គ្រចិត្តនិងសហគមន៍គោលដៅ | • Watsan & Health NFI guidelines<br>• WASH Cluster training material<br>• IEC materials |
| **ជំហានទី៧:**<br>ការត្រួតពិនិត្យ និងវាយតំលៃ | • ប្រើទម្រង់ត្រួតពិនិត្យលើកកម្ពស់អនាម័យដែលបានរៀបចំក្នុងជំហានទី៥<br>• ប្រមូលទិន្នន័យម្តងទៀតបន្ទាប់ពី៣ខែ ដើម្បីប្រៀបធៀបជាមួយទិន្នន័យមូលដ្ឋានដំបូងពីជំហានទី១ និងវាយតម្លៃ<br>• ធ្វើការផ្លាស់ប្តូរផែនការការងារផ្សព្វផ្សាយលើកកម្ពស់អនាម័យដើម្បីកំណត់ពីគោលបំណងដើម្បីឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយាអនាម័យពីសេណារីយ៉ូថ្មី | ធ្វើការបណ្តុះបណ្តាលបុគ្គលិកផ្សព្វផ្សាយអនាម័យនិងបុគ្គលិកស្ម័គ្រចិត្តនិងសហគមន៍គោលដៅ | • Monitoring and evaluation |
| **ជំហានទី៨:**<br>ការពិនិត្យ និងកែតម្រូវឡើងវិញ | អនុវត្តតាមការផ្លាស់ប្តូរស្ថានភាព និងរៀបចំផែនការឡើងវិញ និងកែសម្រួលផែនការឡើងវិញ ដើម្បីកំណត់រកដំណោះស្រាយបញ្ហាបច្ចុប្បន្ន។ | ធ្វើការបណ្តុះបណ្តាលបុគ្គលិកផ្សព្វផ្សាយអនាម័យនិងបុគ្គលិកស្ម័គ្រចិត្តសហគមន៍គោលដៅ និងវិស្វករ | |